# ខ្សែស្រឡាយ អ្នកលួចជាតិ

## ការកាប់ឈើខុសច្បាប់ និងការពុះច្រៀកទ្រព្យសម្បត្តិសាធារណៈ ដោយអ្នកដឹកនាំរបស់ប្រទេសកម្ពុជា

global witness



របាយការណ៍រៀបចំឡើងដោយអង្គការ Global Witness ខែ មិថុនា ឆ្នាំ២០០៧

# មាតិកា


អក្សរកាត់............................................................................................................................................................៤
អនុសាសន៍............................................................................................................................................................៥
សង្ខេប................................................................................................................................................................៨
តារាង ១ : បញ្ហាដែលអាជ្ញាធរយុត្តិធម៌របស់ប្រទេសកម្ពុជា ត្រូវតែស៊ើបអង្កេតនាពេលនេះ ..................................... ១២

ជំពូក I – ព្រៃឈើ និងស្ថានភាពមានតែឈ្មោះរបស់ប្រទេសកម្ពុជា..........................................................................១៤
១. ការច្រៀកទ្រព្យសម្បត្តិរបស់ប្រទេសកម្ពុជា ...........................................................................................................១៤
២. វិស័យព្រៃឈើរបស់ប្រទេសកម្ពុជា..........................................................................................................................១៧
ប្រអប់ទី ១ : ការផ្តល់ឱ្យសភាជាតិ ..........................................................................................................................២០
ប្រអប់ទី ២ : ការវាស់វែងគម្របព្រៃឈើ និងការបំផ្លិចបំផ្លាញព្រៃឈើក្នុងប្រទេសកម្ពុជា.................................................. ២២
៣. ម្ចាស់ជំនួយអន្តរជាតិរបស់ប្រទេសកម្ពុជា - ផ្តល់ជំនួយដល់ប្រជាជនកម្ពុជា ឬសមគំនិតជាមួយរដ្ឋាភិបាល ........................២៣

ជំពូក II – ការរក្សាឱ្យក្នុងគ្រួសារ ......................................................................................................................២៥
១. ការណែនាំទៅកាន់ក្រុមកាប់ឈើលេខមួយរបស់ប្រទេសកម្ពុជា..............................................................................២៥
១.១ ឌី ចូច ក៏ត្រូវបានស្គាល់ថាជា ហ៊ុន ចូច ផងដែរ ..............................................................................................២៥
១.២ សេង គាង ..................................................................................................................................................២៦
សម្ព័ន្ធភាព និងចំណងទាក់ទងរបស់ក្រុមហ៊ុនកាប់ព្រៃឈើកម្ពុជា .......................................................................... ២៧
១.៣ ឃុន ថុង....................................................................................................................................................... ២៧
២. ក្រុមហ៊ុន Kingwood – ការបង្កើត និងការលុបចោលសម្បទានិកឈើ.................................................................២៨
២.១ ការកាប់ឈើខុសច្បាប់ ..................................................................................................................................២៩
២.២ បំណុលដែលមានបញ្ហា .................................................................................................................................២៩
ប្រអប់ទី ៣ : គី តិច ............................................................................................................................................ ៣០
២.៣ ការគ្រប់គ្រងដែលមានអវិភាពខ្លាំង.....................................................................................................................៣១
២.៤ បណ្តឹងប្រជែង ............................................................................................................................................ ៣៥
ប្រអប់ទី ៤ : ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន Kingwood – ទ្រព្យសម្បត្តិរបស់ប្រជាជនកម្ពុជា ? ........................................ ៣៦
៣. ចំការកៅស៊ូទីរីង – មុខមាត់ថ្មីនៃការកាប់ឈើទ្រង់ទ្រាយឧស្សាហកម្មក្នុងប្រទេសកម្ពុជា..............................................៣៧
៣.១ សហគ្រាសទ្រង់ទ្រាយគ្រួសារ ...........................................................................................................................៣៧
ប្រអប់ទី ៥ : ការយកជ័រ.........................................................................................................................................៣៩
ប្រអប់ទី ៦ : ព្រៃឡង់នៅផ្លូវបំបែក........................................................................................................................ ៤០
៣.២ "អត្ថប្រយោជន៍នៃការផ្លាស់ប្តូរ".....................................................................................................................៤២
៣.៣ ការលាងឈើកខ្វក់ ....................................................................................................................................... ៤៣
៣.៤ ការប្រមូលអុស .............................................................................................................................................. ៤៤
៣.៥ អត្ថប្រយោជន៍បន្ថែមទៀត ............................................................................................................................. ៤៥
៣.៦ ឈើចាស់ៗ និងការបាត់បង់ការចងចាំរបស់ម្ចាស់ជំនួយ .................................................................................... ៤៦
៤. ការវិភាគប្រតិបត្តិការកាប់ឈើខុសច្បាប់ ...............................................................................................................៤៧
៤.១ សមត្ថភាពកែច្នៃ............................................................................................................................................. ៤៨
៤.២ ការគាំទ្ររោងចក្រ ......................................................................................................................................... ៤៩
ប្រអប់ទី ៧ : ក្រុមហ៊ុន Colexim – ក្រុមហ៊ុនសម្បទានគំរូរបស់ប្រទេសកម្ពុជា.............................................................. ៥០
៤.២ អ្នកផ្គត់ផ្គង់ ..................................................................................................................................................៥១
៤.៤ ការដឹកជញ្ជូន ..............................................................................................................................................៥២
៤.៥ ទីផ្សារ.......................................................................................................................................................... ៥៣
ប្រអប់ទី ៨ : ការនាំចេញឈើដែលមិនអាចមើលឃើញរបស់ប្រទេសកម្ពុជា................................................................... ៥៤

៤.៦ ទិន្នផល និងចំណូលហិរញ្ញវត្ថុ ..... ៥៦
ការបំផ្លិចបំផ្លាញព្រៃឈើ និងរចនាសម្ព័ន្ធចាត់តាំងក្នុងអំពើពុករលួយ ..... ៥៨
៥. ដីស្រោបរ៉ែជនបទ ..... ៦០
៥.១ ការលួចកាប់ដើមច្បោះ ..... ៦០
៥.២ ការដោះស្រាយជាមួយការខ្វែងយោបល់ ..... ៦០
ប្រអប់ទី ៩ : រឿងរ៉ាវការបាញ់ប្រហារថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៥ ..... ៦២
ប្រអប់ទី ១០ : ក្នុងការស្រាវជ្រាវរកលោក ៩៥ ..... ៦៤
៦. ចាត់វិធានការណ៍បញ្ឈប់ ឬផ្អាក ? ..... ៦៦
ប្រអប់ទី ១១ : ពិធុំធំបន្ទាប់របស់ក្រុមកាប់ឈើ ..... ៦៧
ប្រវត្តិខ្លីពីការគ្រប់គ្រងព្រៃឈើក្នុងប្រទេសកម្ពុជា ..... ៦៩

ជំពូក III – អំពើពុករលួយតាមស្ថាប័នក្នុងព្រៃឡង់ ..... ៧១
១. រដ្ឋបាលព្រៃឈើ ..... ៧១
ប្រអប់ទី ១២ : ការដាក់ដេញថ្លៃការងាររដ្ឋបាលព្រៃឈើរបស់លោក ចាន់ សារុន និងលោក ទី សុគន្ធ ..... ៧២
២. កងរាជអាវុធហត្ថ ..... ៧៥
៣. ប្រតិបត្តិការសឹករងខេត្តកំពង់ធំរបស់កងយោធពលខេមរភូមិន្ទ ..... ៧៦
៤. យោធភូមិភាគ II របស់កងយោធពលខេមរភូមិន្ទ ..... ៧៦
៥. ភ្នាក់ងារសម្ងាត់យោធា ..... ៧៦
ប្រអប់ទី ១៣ : រែកបន្ទុកពុករលួយ ..... ៧៧
៦. ប៉ូលីស ..... ៧៨
៧. រដ្ឋាភិបាលថ្នាក់មូលដ្ឋាន ..... ៧៩

ជំពូក IV – ទំនាក់ទំនងកងពលតូចលេខ ៧០ ..... ៨០
១. កងពលតូចលេខ ៧០ និងកងអង្គរក្ស - ទ័ពផ្ទាល់ខ្លួនសម្រាប់នាយករដ្ឋមន្ត្រី ..... ៨០
ប្រអប់ទី ១៤ : ឧត្តមសេនីយ៍ គន់ គីម និងឧត្តមសេនីយ៍ឯក ហ៊ីង ប៊ុនហៀង ..... ៨១
ប្រអប់ទី ១៥ : ស្រឡាយអាវុធ - ការកាប់ឈើខុសច្បាប់ និងកងយោធពលខេមរភូមិន្ទដែលស្មោះត្រង់ជាមួយ ហ៊ុន សែន ..... ៨២
២. ហាក់ ម៉ៅ ..... ៨៣
៣. ការជួញដូរឈើ ..... ៨៤
ប្រអប់ទី ១៦ : កងយោធពលខេមរភូមិន្ទ ទទួលជំនួយពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ..... ៨៥
៣.១ ការនាំចេញ ..... ៨៧
៣.២ អតិថិជន ..... ៨៧
៤. ការដឹកជញ្ជូនទំនិញរត់ពន្ធដោយកងពលតូចលេខ ៧០ ..... ៩៥
ប្រអប់ទី ១៧ : ក្រុមហ៊ុន Attwood Import Export Co., Ltd. ..... ៩៦
៤.១ ការរត់ពន្ធតាមកំពង់ផែស្រែអំបិល ..... ៩៦
៤.២ ការរត់ពន្ធតាមកំពង់ផែឧកញ៉ា ម៉ុង ..... ៩៧
ប្រអប់ទី ១៨ : ម៉ុង ឫទ្ធី ..... ៩៨
ប្រអប់ទី ១៩ : ការដឹកជញ្ជូនបែងចែកពិសេស ..... ១០០
កងពលលេខ ៧០ សណ្ឋាគារ Intercontinental និងក្រុមហ៊ុន Attwood Import Export ..... ១០១
៥. ផលិតផលសម្រេច – ចំណូល និងចំណាយរបស់ ហាក់ ម៉ៅ ..... ១០២
ប្រអប់ទី ២០ : ក្រុមហ៊ុន Long Meng Group ..... ១០៣
សន្និដ្ឋាន ..... ១០៤
ឧបសម្ព័ន្ធ ១ : សេដ្ឋី-ព្រឹទ្ធសមាជិករបស់ប្រទេសកម្ពុជា / ឯកសារយោង Cronyometer ..... ១០៥
ឯកសារយោង ..... ១០៨




## អក្សរកាត់

| | |
|---|---|
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CG | ក្រុមពិគ្រោះយោបល់ |
| CPP | គណបក្សប្រជាជនកម្ពុជា |
| DFW | នាយកដ្ឋានរុក្ខាប្រមាញ់ និងសត្វព្រៃ (ត្រូវបានប្តូរឈ្មោះជារដ្ឋបាលព្រៃឈើ ក្នុងឆ្នាំ ២០០៣) |
| ELC | សម្បទានដីសេដ្ឋកិច្ច |
| ESIA | ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម |
| FA | រដ្ឋបាលព្រៃឈើ |
| FAO | អង្គការស្បៀងអាហារ និងកសិកម្ម |
| FLEG | ដំណើរការអនុវត្ត និងអភិបាលកិច្ចច្បាប់ព្រៃឈើ |
| ha | ហិកតា |
| IFM | ការត្រួតពិនិត្យព្រៃឈើដោយឯករាជ្យ |
| IFSR | ការវាយតម្លៃវិស័យព្រៃឈើដោយឯករាជ្យ |
| km | គីឡូម៉ែត្រ |
| $m^3$ | ម៉ែត្រគីប |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MP | កងរាជអាវុធហត្ថ |
| MRII | យោធភូមិភាគ II |
| MRIII | យោធភូមិភាគ III |
| MRIV | យោធភូមិភាគ IV |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| RCAF | កងយោធពលខេមរភូមិន្ទ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស |
| SFMP | ផែនការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព |
| UN | អង្គការសហប្រជាជាតិ |
| UNOHCHR | ការិយាល័យស្នងការជាន់ខ្ពស់សិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ |
| WGNRM | ក្រុមការងារគ្រប់គ្រងធនធានធម្មជាតិ |

# អនុសាសន៍

## អាជ្ញាធរយុត្តិធម៌របស់ប្រទេសកម្ពុជាគួរតែ :

### ១. រៀបចំទំនួលខុសត្រូវឱ្យអ្នកទាំងឡាយ ដែលទទួលខុសត្រូវចំពោះការកាប់ឈើខុសច្បាប់ និងបទល្មើសពាក់ព័ន្ធ

- ស៊ើបអង្កេត និងកាត់ទោសរាល់អ្នកទាំងអស់ដែលទទួលខុសត្រូវចំពោះករណីកាប់ឈើខុសច្បាប់ អំពើពុករលួយ ការរត់ពន្ធ ការធ្វើឃាត និងការចាប់ពង្រត់ដែលបានគ្រោងទុក ដូចមានរៀបរាប់លំអិតក្នុងរបាយការណ៍នេះ ។
- កំណត់អាទិភាពការស៊ើបអង្កេតផ្នែកខាងក្រោមនេះ : ចាន់ សារុន[១] រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ទី សុគន្ធ[២] ប្រធានរដ្ឋបាលព្រៃឈើ (FA), ឧត្តមសេនីយ៍ឯក ហ៊ីង ប៊ុនហៀង[៣] មេបញ្ជាការ កងអង្គរក្ស ហ៊ុន សែន, ឧត្តមសេនីយ៍ត្រី ហាក់ ម៉ៅ[៤] កងពលតូចលេខ ៧០, ឌី ចូច[៥] អ្នកដឹកនាំក្រុមកាប់ឈើ, សេង គាង[៦], ឃុន ថុង[៧], និង សេង កុកហ៊ាង[៨] ។

## រាជរដ្ឋាភិបាលកម្ពុជា (RGC) ត្រូវតែ :

### ១. រៀបចំទំនួលខុសត្រូវឱ្យអ្នកទាំងឡាយ ដែលទទួលខុសត្រូវចំពោះការកាប់ឈើខុសច្បាប់ និងបទល្មើសពាក់ព័ន្ធ

- គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរយុត្តិធម៌ ដើម្បីស៊ើបអង្កេត និងកាត់ទោសអ្នកទាំងឡាយណា ដែលទទួលខុសត្រូវចំពោះសកម្មភាពខុសច្បាប់ដូចមានរៀបរាប់លំអិតក្នុងរបាយការណ៍នេះ ។
- បណ្តេញចេញនូវរដ្ឋមន្ត្រីរបស់រដ្ឋាភិបាល មន្ត្រី នាយទាហានទាំងឡាយ ដែលទទួលខុសត្រូវចំពោះសកម្មភាពខុសច្បាប់ទាំងនេះ ។

### ២. ការពារព្រៃឈើនៅព្រៃឡង់

- ដកព្រៃឡង់ដែលជាព្រៃឈើបៃតងទំនាបធំជាងគេបំផុតរបស់អាស៊ីអាគ្នេយ៍ដីគោកចេញពីផលិតកម្ម ។ បង្កើតរបបគ្រប់គ្រងឆ្លាស់សម្រាប់ព្រៃឡង់ដោយផ្អែកតាមការពិគ្រោះយោបល់ជាមួយប្រជាជនមូលដ្ឋាន ដែលកំណត់អាទិភាពដល់ការអភិរក្ស និងការរក្សាសុវត្ថិភាពដល់សិទ្ធិប្រើប្រាស់របស់ប្រជាជនដែលរស់នៅក្នុង និងជុំវិញព្រៃ ។

### ៣. កែទម្រង់ការគ្រប់គ្រងព្រៃឈើ

- ដាក់ឱ្យដូចដើមនូវការត្រួតពិនិត្យព្រៃឈើដោយឯករាជ្យ (IFM) ដោយផ្អែកតាមក្របខណ្ឌស្ថាប័នរឹងមាំ និងលក្ខខណ្ឌសំអាង បន្ទាប់ពីការពិគ្រោះយោបល់ជាសាធារណៈមួយរយៈពេលរួចមក ។ តែងតាំងអង្គការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយផ្អែកតាមមូលដ្ឋាននៃដំណើរការស្នើសុំជាចំហ ដែលធ្វើឡើងស្របតាមការអនុវត្តប្រសើរបំផុតជាអន្តរជាតិ ។
- បញ្ឈប់រាល់ប្រព័ន្ធផ្តល់សម្បទានកាប់ឈើ ស្របជាមួយអនុសាសន៍របស់ការវាយតម្លៃវិស័យព្រៃឈើដោយឯករាជ្យ (IFSR) ឆ្នាំ ២០០៤[៩] ។
- លុបចោលផែនការណែនាំប្រព័ន្ធថ្មី នៃការផ្តល់ឱ្យការដេញថ្លៃ (កាប់ឈើ) ប្រចាំឆ្នាំ ។
- បញ្ឈប់រាល់សម្បទានដីសេដ្ឋកិច្ច (ELCs) និងសម្បទានរ៉ែដែលមានទីតាំងនៅតំបន់ព្រៃ ឬបើពុំនោះទេ ផ្ទុយទៅនឹងច្បាប់ដែលមានស្រាប់ ។
- បង្កើតរបបគ្រប់គ្រងព្រៃឈើថ្មីមួយដោយផ្អែកលើអនុសាសន៍របស់ IFSR ។ នេះត្រូវផ្តោតលើព្រៃសហគមន៍ ពង្រីកព្រៃភាពជាដៃគូ និងកម្មវិធីអភិរក្សទស្សនីយភាព[i] ។
- ទទួលស្គាល់ការអះអាងបញ្ជាក់ពីមុនរបស់ជនជាតិភាគតិចតាមតម្រូវដោយច្បាប់ភូមិបាលក្នុងការកំណត់ស្ថានភាព និងការប្រើប្រាស់តំបន់ព្រៃ ។
- ធានាថាការកាប់ឈើ និងការបណ្តាក់ទុនដាំដើមឈើនាពេលអនាគត បំពេញតាមបទដ្ឋានក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើ (FSC) ឬសមមូល ហើយស្របតាមការពិគ្រោះយោបល់ជាមួយសហគមន៍ដែលប៉ះពាល់ ។
- បំពេញ និងអនុម័តច្បាប់តំបន់ការពារថ្មី និងរាល់អនុក្រឹត្យ និងប្រកាស (សេចក្តីប្រកាសថ្នាក់ក្រសួង) ដែលមានទាំងអស់ដែលតម្រូវស្ថិតក្រោមច្បាប់ព្រៃឈើឆ្នាំ២០០២ ។ ធានាថា ពង្រាងត្រូវបានធ្វើឡើងឱ្យអាចទទួលបានជាសាធារណៈមុនពេលអនុម័ត ដែលអនុញ្ញាតឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការផ្តល់យោបល់ជាសាធារណៈ ។
- ដាក់កំណត់ការបញ្ឈប់សាងសង់ផ្លូវតាមរយៈតំបន់ព្រៃ ស្របជាមួយអនុសាសន៍របស់ IFSR ឆ្នាំ ២០០៤ ។

[i] ព្រៃភាពជាដៃគូ ជាគំរូថ្មីមួយ ដែលស្នើដោយការពិនិត្យវិស័យព្រៃឈើដោយឯករាជ្យឆ្នាំ ២០០៤ ។ វានឹងផ្តល់ឱ្យសិទ្ធិកាន់តែទូលំទូលាយក្នុងការធ្វើសេចក្តីសម្រេចចិត្តគ្រប់គ្រងព្រៃឈើចំពោះក្រុមប្រឹក្សាឃុំ ដែលបានជ្រើសរើសដោយរដ្ឋបាលព្រៃឈើដើរតួនាទីចេញច្បាប់ ។

## ៤. ចាត់វិធានការណ៍បន្ទាន់ ដើម្បីបង្កើនតម្លាភាព ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ

- ធានាថា មានការបង្ហាញព័ត៌មានពេញលេញ និងជាបន្តបន្ទាប់ ពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ ដូចជា ព្រៃឈើ ដីធ្លី ប្រេង និងឧស្ម័ន ស្រទាប់រ៉ែ មច្ឆា តំបន់កៀមរតក និងអាគារគ្រប់គ្រងដោយរដ្ឋ ។
- ធានាថា ព័ត៌មាននេះ រួមមានដូចខាងក្រោមនេះ : កិច្ចព្រមព្រៀងវិនិយោគ លក្ខខណ្ឌកិច្ចសន្យា និងស្ថានភាពអនុវត្តតាម (ការបំពេញការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមតាមតម្រូវចិត្ត[ESIAs] ការបង់សួយសារ ។ល ។) ការរុករក ការធ្វើអាជីវកម្ម ការដឹកជញ្ជូន និងប័ណ្ណអនុញ្ញាតនាំចេញដែលបានផ្តល់ឱ្យ ឈ្មោះ និងលំអិតពីម្ចាស់ទទួលប្រយោជន៍របស់ក្រុមហ៊ុនពាក់ព័ន្ធ ។

## ៥. ពង្រឹងក្របខណ្ឌច្បាប់គ្រប់គ្រង ការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ

- បញ្ចូលក្នុងពង្រាងច្បាប់ប្រឆាំងអំពើពុករលួយនូវ ៥ ចំណែង ដូចខាងក្រោមនេះ :
  - មាត្រាដែលធានាសិទ្ធិពលរដ្ឋខ្មែរ ក្នុងការទទួលបានប្រភេទព័ត៌មានស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ ដែលមានរាយខាងលើ ។
  - ការហាមប្រាមបុគ្គល ឬក្រុមហ៊ុនដែលមានកំណត់ត្រាសកម្មភាពខុសច្បាប់ពីការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈគ្រប់ប្រភេទ ។
  - តម្រូវការថា គ្រប់កិច្ចសន្យាទាំងអស់រវាងរដ្ឋាភិបាល និងក្រុមហ៊ុនពាក់ព័ន្ធការគ្រប់គ្រង ការរុករក ឬការធ្វើអាជីវកម្មធនធានធម្មជាតិ និងទ្រព្យសម្បត្តិសាធារណៈផ្សេងទៀត ប្រព្រឹត្តតាមដំណើរការ ស្នើសុំជាចំហ ដែលធ្វើឡើងស្របតាមការអនុវត្តប្រសើរបំផុតជាអន្តរជាតិ ។
  - តម្រូវការដែលថារាល់ប្រតិបត្តិករវិស័យឯកជនទាំងអស់ដែលគ្រប់គ្រងសម្បទានទ្រព្យសម្បត្តិសាធារណៈ បង្ហាញជាប្រចាំឆ្នាំនូវការចំណាយ ដែលពួកគេបង់ឱ្យរដ្ឋាភិបាល ក្នុងទម្រង់ជា ពន្ធដារ សួយសារ ប្រាក់រង្វាន់ពីការចុះហត្ថលេខា ។ល ។
  - តម្រូវការដែលថា រាជរដ្ឋាភិបាលកម្ពុជា បង្ហាញជាប្រចាំឆ្នាំនូវលំអិតរាល់ពន្ធអាករ សួយសារ ប្រាក់រង្វាន់ពីការចុះហត្ថលេខាទាំងអស់ ។ល ។ ដែលទទួលពីការផ្តល់សម្បទានទ្រព្យសម្បត្តិសាធារណៈ ។
  - តម្រូវការដែលថា រដ្ឋាភិបាលរក្សាការចុះបញ្ជីផលប្រយោជន៍អាជីវកម្ម និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់មន្ត្រីជាន់ខ្ពស់ ដែលមានការផ្លាស់ប្តូរឱ្យបានទៀងទាត់ និងទទួលបានជាសាធារណៈ ក៏ដូចជារបស់សមាជិកគ្រួសាររបស់ពួកគេផងដែរ ។
- អនុម័ត និងអនុវត្តពង្រាងច្បាប់នេះ ដោយមិនមានការពន្យារបន្ថែមទៀត ។

## ៦. ធានាពីការគ្រប់គ្រងមានតម្លាភាពនៃប្រាក់ចំណូល ប្រេង និងឧស្ម័ន

- អនុវត្តវិធានការណ៍គ្រប់គ្រងប្រាក់ចំណូលដែលបានកំណត់ ក្នុងទិសដៅណែនាំរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ស្តីពីតម្លាភាពប្រាក់ចំណូលពីធនធាន[១០] ។
- ចូលរួមជាមួយគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មចម្រាញ់[១១] ។

## ៧. កែទម្រង់កងយោធពលខេមរភូមិន្ទ (RCAF)

- ដកចេញនូវកងយោធាទាំងអស់ ដែលមានទីតាំងនៅក្នុង ឬលើព្រំដែនតំបន់ការពារ ។
- បង្ហាញពីទីតាំង និងស្ថានភាពច្បាប់របស់តំបន់អភិវឌ្ឍន៍យោធាទាំងអស់ ។ បញ្ឈប់រាល់តំបន់ទាំងឡាយណាដែលមានទីតាំងនៅលើព្រៃក្នុងតំបន់ការពារ ឬបើពុំនោះផ្ទុយនឹងច្បាប់ដែលមានស្រាប់ ។
- បដិសេធច្បាប់កេណ្ឌទ័ណដែលបានណែនាំនាពេលថ្មីៗនេះ និងបន្តរៀបចំរចនាសម្ព័ន្ធកងយោធពលខេមរភូមិន្ទឡើងវិញឱ្យបានទូលំទូលាយ ដើម្បីបង្កើតកម្លាំងយោធាជំនាញដែលបំពេញតាមតម្រូវការការពាររបស់ប្រទេសកម្ពុជា ។

# ម្ចាស់ជំនួយអន្តរជាតិរបស់ប្រទេសកម្ពុជា ត្រូវតែ :

## ១. ប្រើប្រាស់ឥទ្ធិពលរបស់ពួកគេឱ្យបានសកម្ម ដើម្បីធានាថា ជំនួយផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនខ្មែរសាមញ្ញ

- ម្ចាស់ជំនួយគួរតែភ្ជាប់ការចំណាយជំនួយមិនមែនមនុស្សធម៌ ទៅនឹងការរីកចម្រើន ដែលអាចពន្យល់បង្ហាញបានក្នុងការអនុវត្តវិធានការណ៍ដែលបានកំណត់ខាងលើ ស្របតាមគម្រោងពេលវេលាដែលបានបង្កើតឡើង ។

## ២. ដកការផ្តល់ជំនួយពីស្ថាប័នរដ្ឋដែលពាក់ព័ន្ធសកម្មភាពល្មើសធ្ងន់ធ្ងរ

- ដោយឡែកម្ចាស់ជំនួយមិនត្រូវផ្តល់មូលនិធិ ឬទម្រង់នៃជំនួយផ្សេងទៀត ឱ្យកងយោធពលខេមរភូមិន្ទ រហូតដល់កងយោធពលខេមរភូមិន្ទបញ្ឈប់ការចូលរួមរបស់ខ្លួនក្នុងបទល្មើសដែលបានរៀបចំឡើងក្នុងទ្រង់ទ្រាយធំ ។

## ៣. គាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់សង្គមស៊ីវិលកម្ពុជា ដើម្បីបង្កើនទំនួលខុសត្រូវរដ្ឋាភិបាល

- ផ្តល់ជំនួយបន្ថែមដល់អង្គការកម្ពុជា ដែលធ្វើការបង្កើតទំនួលខុសត្រូវរដ្ឋាភិបាលពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ ។ ជាពិសេស បង្កើតសមត្ថភាពសង្គមស៊ីវិលក្នុងមូលដ្ឋាន ដើម្បីកត់ត្រា ត្រួតពិនិត្យ និងពិចារណាការគ្រប់គ្រងធនធានធម្មជាតិ និងទ្រព្យសម្បត្តិសាធារណៈផ្សេងទៀត និងធានាថា ការចំណាយវិស័យសាធារណៈមានតម្លាភាព ។

## ៤. ជួយការពារព្រៃឈើរបស់ប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការផ្លាស់ប្តូរបរិយាកាស

- អនុវត្តតាមសេចក្តីសន្និដ្ឋានរបស់ការវាយតម្លៃហ្វត់ចត់ ដែលរៀបចំដោយរដ្ឋាភិបាលអង់គ្លេសនាពេលថ្មីៗនេះ ស្តីពីសេដ្ឋកិច្ចនៃការផ្លាស់ប្តូរបរិយាកាសដែលកិច្ចខិតខំប្រឹងប្រែងអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងការផ្លាស់ប្តូរបរិយាកាសត្រូវតែផ្តល់អាទិភាពដល់ការថែរក្សាព្រៃធម្មជាតិដែលមានស្រាប់[១២] ។
- ស្របជាមួយប្រទេសកម្ពុជាផ្តល់មូលនិធិ និងជំនាញដល់ការបង្កើតការលើកទឹកចិត្តថ្មី និងក្របខណ្ឌស្ថាប័នសម្រាប់រក្សាតំបន់សំខាន់ៗ ដូចជា ព្រៃឡង់ ជាដើម ។



ព្រៃឈើព្រៃឡង់របស់ប្រទេសកម្ពុជា

# សង្ខេប [ii]

របាយការណ៍នេះ ធ្វើឱ្យមានកិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំងដោយរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិ ដើម្បីពង្រឹងអភិបាលកិច្ចព្រៃឈើ និងទ្រព្យសម្បត្តិសាធារណៈផ្សេងទៀត ដែលប្រជាជនកម្ពុជាពឹងផ្អែកលើ ។ របាយការណ៍នេះ ត្រូវបានពឹងផ្អែកលើការស៊ើបអង្កេតស៊ីជម្រៅក្នុងការកាប់ឈើខុសច្បាប់ និងបទល្មើសពាក់ព័ន្ធ ដែលធ្វើឡើងដោយ Global Witness ក្នុងរវាងពីចុងឆ្នាំ ២០០៤ និងដើមឆ្នាំ ២០០៧ ។

លទ្ធផលចម្បងៗរបស់របាយការណ៍ មានដូចខាងក្រោមនេះ :

## ១. អ្នកដឹកនាំបែបលួចប្លន់ កំពុងច្រៀកព្រៃឈើរបស់ប្រទេសកម្ពុជា

- ប្រទេសកម្ពុជាត្រូវបានដឹកនាំដោយអ្នកដឹកនាំបែបលួចប្លន់ ដែលធ្វើឱ្យមានទ្រព្យសម្បត្តិរបស់ខ្លួនច្រើន តាមរយៈការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ជាពិសេសធនធានធម្មជាតិ ។ វិស័យព្រៃឈើផ្តល់ឱ្យនូវរូបភាពរស់រវើក ជាពិសេសពីដំណើរការពុះច្រៀកទ្រព្យសម្បត្តិនេះនៅកន្លែងធ្វើការ ។
- ការកាប់ឈើខុសច្បាប់ កំពុងបណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់ព្រៃឈើដែលនៅសល់របស់ប្រទេសកម្ពុជា ។ ការអង្កេតស្រាវជ្រាវគម្របព្រៃឈើជាសកលលើកចុងក្រោយដោយអង្គការ ស្បៀងអាហារ និងកសិកម្ម (FAO) បានរកឃើញថាប្រទេសកម្ពុជា បានបាត់បង់ព្រៃឈើត្រូពិចធំជាងគេរបស់ខ្លួនចំនួន ២៩% ក្នុងអំឡុងពេលប្រាំឆ្នាំ ។
- កងទ័ព កងរាជអាវុធហត្ថ ប៉ូលីស និងរដ្ឋបាលព្រៃឈើ (FA) របស់ប្រទេសកម្ពុជា ចូលរួមពាក់ព័ន្ធយ៉ាងខ្លាំងទាំងអស់គ្នាក្នុងការកាប់ឈើខុសច្បាប់ ។
- ក្នុងករណីជាច្រើន ការកាប់ឈើខុសច្បាប់កំពុងកើតឡើង ដោយស្ថិតក្រោមរបៀបអភិវឌ្ឍន៍ចំការគួរឱ្យសង្ស័យស្របច្បាប់ និងការផ្តល់លិខិតអនុញ្ញាតឱ្យប្រមូលផល ។ ការដាំដើមឈើ និងលិខិតអនុញ្ញាតជាច្រើនក្នុងចំណោមនេះ កំពុងត្រូវបានផ្តល់ឱ្យក្រុមបុគ្គលមួយចំនួន ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយអ្នកនយោបាយជាន់ខ្ពស់ ។
- ការព្រួយបារម្ភជាពិសេស គឺអន្តរាយដែលអ្នកកាប់ឈើខុសច្បាប់កំពុងធ្វើចំពោះព្រៃឡង់ ដែលជាព្រៃបៃតងទំនាបធំបំផុតក្នុងអាស៊ីអគ្នេយ៍ដីគោក ។ រដ្ឋាភិបាលកម្ពុជា បច្ចុប្បន្នកំពុងបង្កើតផែនការកាប់ព្រៃឡង់រាប់ម៉ឺនហិកតា ដើម្បីធ្វើផ្លូវដាំដើមឈើ ។

## ២. ក្រុមកាប់ឈើដ៏មានអំណាចបំផុតរបស់ប្រទេសកម្ពុជា ត្រូវបានដឹកនាំដោយសាច់ញាតិរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន[១៣] និងមន្ត្រីជាន់ខ្ពស់ផ្សេងទៀត

- ក្រុមកាប់ឈើដែលមានអំណាចបំផុតក្នុងប្រទេសកម្ពុជា ដឹកនាំដោយ ឌី ចូច ក៏ត្រូវបានស្គាល់ថាជា ហ៊ុន ចូច ផងដែរ អតីតភរិយារបស់គាត់ សេង គាង និង ឃុន ថុង ដែលជាដៃគូអាជីវកម្មរបស់ពួកគេ ។ ក្រុមនេះប្រតិបត្តិការដោយស្ថិតក្រោមឈ្មោះក្រុមហ៊ុន Seng Keang Company ។
  - ឌី ចូច គឺជាប្អូនជីដូនមួយរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។
  - សេង គាង គឺជាមិត្តភក្តិរបស់ ប៊ុន រ៉ានី ភរិយារបស់ ហ៊ុន សែន ។
  - ឃុន ថុង គឺជាបងថ្លៃរបស់ ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និងជាឪពុកក្មេករបស់លោក ទី សុគន្ធ ប្រធានរដ្ឋបាលព្រៃឈើ (FA) ។
  - ប្អូនប្រុសរបស់ សេង គាង ឈ្មោះ សេង កុកហ៊ាង ដែលដឹកនាំប្រតិបត្តិការសម្រាប់ក្រុមហ៊ុន Seng Keang Company គឺជាមន្ត្រីក្នុងកងឯកភាពយោធាកងពលតូចលេខ ៧០ នៃកងយោធពលខេមរភូមិន្ទ (RCAF) ។



ហ៊ុន សែន ស្វាគមន៍មន្ត្រីជាន់ខ្ពស់

[ii] ចំណុចយោងសម្រាប់ចំណុចជាច្រើនដែលមានក្នុងផ្នែកនេះ អាចរកបានក្នុងផ្នែកខាងក្នុងនៃរបាយការណ៍នេះ ។



នាយករដ្ឋមន្ត្រី ហ៊ុន សែន



ប៊ុន រ៉ានី ភរិយារបស់ ហ៊ុន សែន



ឌី ចូច ប្អូនជីដូនមួយរបស់ ហ៊ុន សែន
ក៏ត្រូវបានស្គាល់ផងដែរថាជា ហ៊ុន ចូច



សេង គាង ភរិយាមុនរបស់ ឌី ចូច



សេង កុកហ៊ាង ប្អូនប្រុសរបស់ សេង គាង
ក៏ត្រូវបានស្គាល់ផងដែរថាជា Mr. ៩៥



ចាន់ សារុន ប្អូនថ្លៃរបស់ ឃុន ចុង
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ទី សុគន្ធ កូនប្រសាររបស់ ឃុន ចុង
អគ្គនាយករដ្ឋបាលព្រៃឈើ



ឧត្តមសេនីយ៍ត្រី ហ៊ីង ប៊ុនហៀង
មេបញ្ជាការកងអង្គរក្ស ហ៊ុន សែន



ឧត្តមសេនីយ៍ សៅ សុខា
មេកងរាជអាវុធហត្ថរបស់ប្រទេសកម្ពុជា



## ៣. សកម្មភាពដែលសមាជិកក្រុមកាប់ឈើនេះ កំពុងជាប់ទាក់ទង រួមមានដូចខាងក្រោម ៈ

- ការចាប់ពង្រត់ និងឃុំឃាំង ដែលអាចមើលឃើញជាក់ស្តែងទៅលើ លី ជុនហួរ[១៤] នាយកគ្រប់គ្រងក្រុមហ៊ុនកាប់ឈើ Kingwood Industry ។
- ការកាប់ឈើខុសច្បាប់ទ្រង់ទ្រាយធំក្នុងព្រៃឡង់ ត្រូវបានអនុវត្តដោយស្ថិតក្រោមទម្រង់នៃការអភិវឌ្ឍន៍ចំការកៅស៊ូទីរីង ។
- ការកាប់រំលំឈើយកជ័ររាប់ពាន់ដើម ដោយប្រជាជនក្នុងមូលដ្ឋានដែលផ្អែកលើឈើទាំងនោះជាប្រភពចំណូល ។ ឈើយកជ័រត្រូវបានការពារដោយច្បាប់ប្រទេសកម្ពុជា ។
- ការប៉ុនប៉ងដែលបានរាយការណ៍ដោយ សេង កុកហ៊ាង ដើម្បីសម្លាប់សកម្មជនព្រៃឈើសហគមន៍ពីរនាក់ក្នុងទីរីង ដែលបានតវ៉ាប្រឆាំងការកាប់ឈើយកជ័ររបស់ក្រុមហ៊ុន Seng Keang Company ។
- ការប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនក្លែងបន្លំ ដែលរៀបរាប់ពីឈើថា ជាអុសដែលមានតម្លៃថោក ។ នេះអាចធ្វើឱ្យរតនាគាររបស់ប្រទេសកម្ពុជាច្រើនជាងលានដុល្លារបាត់បង់ចំណូលពន្ធ ។
- ការនាំចេញទៅកាន់ប្រទេសចិននូវក្តារបន្ទះមានតម្លៃរាប់លានដុល្លារ ដែលគ្មានការបង់ពន្ធទំនងជាត្រូវបានបង់ ។
- ការបង្កើតក្នុងទីរីងនូវរោងចក្រមួយសម្រាប់អារឈើ និងធ្វើបន្ទះឈើ ។ ច្បាប់ព្រៃឈើរបស់ប្រទេសកម្ពុជា ហាមប្រាមការសាងសង់រោងចក្រកែច្នៃឈើក្នុងតំបន់ព្រៃឈើ ។
- រោងចក្រនេះ កំពុងកែច្នៃឈើជាង ១០០,០០០ ម៉ែត្រគីប ($m^3$) ក្នុងមួយឆ្នាំ ទៅជាផលិតផលឈើដែលមានតម្លៃជាង US$១៣ លានប្រចាំឆ្នាំ ។ ឈើភាគច្រើនបំផុតដែលបានប្រើប្រាស់ត្រូវបានកាប់ខុសច្បាប់ក្នុងព្រៃឡង់ ។
- សកម្មភាពខាងលើ ត្រូវបានរ៉ាប់រងដោយច្បាប់ប្រទេសកម្ពុជាដែលមានស្រាប់ និងអាចដាក់ទោសដោយការកាត់ទោសជាប់ពន្ធនាគារ និងពិន័យ ។ ទោះយ៉ាងណាក៏ដោយ ឌី ចូច, សេង គាង, ឃុន ថុង និង សេង កុកហ៊ាង មិនត្រូវបានកាត់ទោសនោះទេ ។

## ៤. មន្ត្រីជាន់ខ្ពស់ចូលដៃគ្នាក្នុងសកម្មភាពទាំងនេះ

- នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបើកសម្ពោធចំការកៅស៊ូទីរីងដោយខ្លួនឯង ដែលបានផ្តល់ឱ្យនូវមូលដ្ឋានសម្រាប់ការកាប់ឈើខុសច្បាប់ដ៏ធំនៅព្រៃឡង់ ដោយក្រុមហ៊ុន Seng Keang Company ។
- ការបង្កើតចំការនេះ បានធ្វើក្រោយការអង្កេតស្រាវជ្រាវតំបន់ទីរីងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលរៀបចំឡើងដោយ ចាន់ សារុន ប្អូនថ្លៃរបស់ ឃុន ថុង ។ ការអង្កេតស្រាវជ្រាវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនេះ ចែកចំណាត់ថ្នាក់តំបន់នេះខុសថា ជាដីដែលមានព្រៃឈើមានតម្លៃតិចតួចប៉ុណ្ណោះ ។
- ទោះបីជាមានការអះអាងថា ខ្វះខាតឈើមានតម្លៃក្នុងតំបន់នេះក៏ដោយ ចាន់ សារុន នៅតែផ្តល់សិទ្ធិផ្តាច់មុខដល់ក្រុមហ៊ុន Seng Keang Company ដើម្បីប្រមូល និងកែច្នៃរាល់កំណាត់ឈើទាំងអស់ក្នុងចំការកៅស៊ូទីរីង ។
- ក្រោយមក ចាន់ សារុន បានផ្តល់ឱ្យក្រុមហ៊ុននូវលិខិតអនុញ្ញាតបង្កើតរោងចក្រកែច្នៃឈើរបស់ខ្លួនក្នុងទីរីង ទោះបីជាការពិតថានេះខុសច្បាប់ក៏ដោយ ។
- រដ្ឋបាលព្រៃឈើ ដែលគ្រប់គ្រងដោយលោក ទី សុគន្ធ កូនប្រសាររបស់ ឃុន ថុង បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការកាប់ឈើខុសច្បាប់ និងសកម្មភាពល្មើសផ្សេងទៀតរបស់ក្រុមហ៊ុន Seng Keang Company ។

## ៥. ភស្តុតាងបង្ហាញថាមន្ត្រីជាន់ខ្ពស់មួយចំនួនក្នុងចំណោមនេះ ទទួលខុសត្រូវដោយផ្ទាល់ចំពោះអំពើពុករលួយក្នុងស្ថាប័នដែលពួកគេដឹកនាំ

- មានភស្តុតាងត្រឹមត្រូវមួយថា ចាន់ សារុន និង ទី សុគន្ធ បានលក់ដោយខុសច្បាប់នូវការងារលើសពី ៥០០ ក្នុងរដ្ឋបាលព្រៃឈើ (FA) ។
- មន្ត្រីទាំងនេះបានគណនាថា ការលក់ការងារនេះបានផ្តល់ឱ្យសំណូកដល់ ចាន់ សារុន ជាង US$2.5 លាន ។
- តម្រូវការដើម្បីទទួលបានការចំណាយទិញតួនាទីទាំងនេះវិញ ទំនងជាទទួលខុសត្រូវចំពោះឥរិយាបថពុករលួយ ដែលមានការកើនឡើងក្នុងចំណោមមន្ត្រីរដ្ឋបាលព្រៃឈើជាច្រើន ។
- អំពើពុករលួយ និងការឃុបឃិតបទល្មើសព្រៃឈើទាំងពីរ ត្រូវបានរ៉ាប់រងដោយច្បាប់ប្រទេសកម្ពុជាដែលមានស្រាប់ និងអាចដាក់ទោសដោយកាត់ទោសជាប់ពន្ធនាគារ និងពិន័យ ។ ទោះយ៉ាងណាក៏ដោយ គ្មានមន្ត្រីជាន់ខ្ពស់ណាម្នាក់ ត្រូវបានចោទប្រកាន់ ឬដាក់វិន័យពាក់ព័ន្ធនឹងការលក់ការងារ ឬការកាប់ឈើខុសច្បាប់ក្នុងព្រៃឡង់នៅឡើយទេ ។

## ៦. ទ័ពផ្ទាល់ខ្លួនរបស់ ហ៊ុន សែន ត្រូវបានផ្តល់ប្រាក់តាមរយៈការកាប់ឈើខុសច្បាប់ និងការរត់ពន្ធ

- ក្នុងការដឹកជញ្ជូនឈើដែលបានកាប់ខុសច្បាប់ចេញពីព្រៃឡង់ ក្រុមហ៊ុន Seng Keang Company បានធ្វើការយ៉ាងជិតស្និទ្ធជាមួយកងពលតូចលេខ ៧០ របស់កងយោធពលខេមរភូមិន្ទ ។ កងពលតូចលេខ៧០ ដើរតួជាកងកម្លាំងបម្រុងសម្រាប់កងអង្គរក្សដ៏ខ្លាំងចំនួន ៤០០០ នាក់របស់ ហ៊ុន សែន ។ អង្គភាពទាំងពីរនេះមាននូវទ័ពផ្ទាល់ខ្លួនសំខាន់ ដែលត្រូវបានគ្រប់គ្រងដោយនាយករដ្ឋមន្ត្រី ។
- ផ្សេងពីសកម្មភាពរបស់ខ្លួនក្នុងព្រៃឡង់ កងពលតូចលេខ ៧០ ដើរតួជាផ្តល់សេវាកម្មដឹកជញ្ជូនឈើទូទាំងប្រទេស ។ កងពលនេះ

ជញ្ជូនឈើដែលបានកាប់ខុសច្បាប់ទូទាំងប្រទេសកម្ពុជា និងនាំចេញបរិមាណដ៏ច្រើនទៅកាន់ប្រទេសវៀតណាម ។

- មន្ត្រីដែលរៀបចំប្រតិបត្តិការទាំងនេះមាន ឧត្តមសេនីយ៍ត្រី ហាក់ ម៉ៅ ។ អ្នកការពារ និងម្ចាស់សំខាន់របស់គាត់ រួមមាន ឧត្តមសេនីយ៍ឯក ហ៊ីង ប៊ុនហៀង មេបញ្ជាការកងអង្គរក្ស ហ៊ុន សែន និងឧត្តមសេនីយ៍ សៅ សុខា មេបញ្ជាការកងរាជ-អាវុធហត្ថទូទាំងប្រទេស[១៥] ។
- អតិថិជនរបស់កងពលតូចលេខ ៧០ គឺ "នរណាក៏ដោយ" នៃសេដ្ឋីឈើធំៗក្នុងប្រទេសកម្ពុជា ដែលរួមមានក្រុមហ៊ុន Turys Pheapimex ដែលគ្រប់គ្រងដោយ យាយភូ ដែលជាមិត្តជិតស្និទ្ធរបស់ ហ៊ុន សែន ក៏ដូចជាមន្ត្រីរដ្ឋាភិបាល និងមជ្ឈដ្ឋានទូទៅផងដែរ ។
- ក្នុងឆមាសទីពីរ ឆ្នាំ ២០០៦ កងពលតូចលេខ ៧០ បានកំពុងជញ្ជូនឈើកាប់ខុសច្បាប់ចំនួន ១២៦០ម៣ ក្នុងមួយសប្តាហ៍ ។ តាមរយៈប្រតិបត្តិការដឹកឈើទាំងនេះ ហាក់ ម៉ៅ អាចរកបានប្រមាណ US$១.២ លានក្នុងមួយឆ្នាំ ។
- កងពលតូចលេខ ៧០ ប្រតិបត្តិការសេវាកម្មដឹកជញ្ជូនទំនិញខុសច្បាប់ដូចគ្នានេះ តាមរយៈកំពង់ផែសមុទ្រភាគខាងត្បូងរបស់ប្រទេសកម្ពុជាដែលគួរឱ្យកត់សំគាល់ គឺកំពង់ផែឧកញ៉ា ម៉ុង ដែលជារបស់លោក ម៉ុង ឫទ្ធី[១៦] ជាមហាសេដ្ឋីម្នាក់ដែលជាព្រឹទ្ធសមាជិកសម្រាប់គណបក្សប្រជាជន (CPP) របស់ ហ៊ុន សែន ផងដែរ ។
- ប្រតិបត្តិការដឹកឈើខុសច្បាប់ និងការរត់ពន្ធដែលមានការពាក់ព័ន្ធរបស់កងពលតូចលេខ ៧០ មានតម្លៃរវាង US$២ លាន និង US$២.៧៥ លាន ជារៀងរាល់ឆ្នាំ ។
- ប្រាក់ចំណេញ ត្រូវបានប្រើប្រាស់សម្រាប់ប្រតិបត្តិការកងពលតូចលេខ ៧០ ខ្លួនឯង ។ ជាងនេះទៅទៀត ការកាប់ទ្រង់ទ្រាយធំមួយត្រូវបានប្រគល់ឱ្យឧត្តមសេនីយ៍ឯក ហ៊ីង ប៊ុនហៀង មេបញ្ជាការកងអង្គរក្ស ហ៊ុន សែន ។
- សកម្មភាពទាំងនេះ ត្រូវបានរ៉ាប់រងដោយច្បាប់ប្រទេសកម្ពុជាដែលមានស្រាប់ និងអាចដាក់ទោសបាន ដោយការកាត់ទោសជាប់ពន្ធនាគារ និងពិន័យ ។ ទោះយ៉ាងណាក៏ដោយ មកទល់ថ្ងៃនេះ គ្មាននរណាម្នាក់ដែលទទួលខុសត្រូវ ត្រូវបានកាត់ទោសឡើយ ។
- ទោះបីជាមានភស្តុតាងពីបទល្មើសជុំវិញក្នុងកងយោធពលខេមរភូមិន្ទក៏ដោយ ក៏ម្ចាស់ជំនួយអន្តរជាតិ ដូចជា ចិន និង អាមេរិក ឥឡូវនេះកំពុងតែផ្តល់ជំនួយយោធាដោយផ្ទាល់មកឱ្យប្រទេសកម្ពុជា ។

## ៧. ម្ចាស់ជំនួយអន្តរជាតិរបស់ប្រទេសកម្ពុជា មិនកំពុងប្រើប្រាស់ឥទ្ធិពលរបស់ពួកគេមានប្រសិទ្ធិភាពនោះទេ

- ម្ចាស់ជំនួយអន្តរជាតិផ្តល់ជំនួយប្រចាំឆ្នាំប្រមាណ US$600 លានក្នុងមួយឆ្នាំ ឱ្យប្រទេសកម្ពុជា ។ នេះស្មើនឹងពាក់កណ្តាលថវិកាជាតិ ។
- ម្ចាស់ជំនួយមិនបានប្រើប្រាស់អានុភាព ដែលជំនួយនេះផ្តល់ឱ្យពួកគេយ៉ាងមានប្រសិទ្ធិភាពនោះទេ ។ ជាពិសេស ពួកគេបានបដិសេធទទួលស្គាល់ការពិតថា រដ្ឋាភិបាលមានការពុករលួយខ្លាំង ហើយមិនដើរតួជាផលប្រយោជន៍ប្រសើរបំផុតរបស់ប្រជាជន ។
- ហេតុនេះ ជំនួយរាប់ពាន់លានដុល្លារដែលផ្តល់ឱ្យដោយអ្នកជាប់ពន្ធនៅលោកខាងលិច បានធ្វើការកែលំអបន្តិចបន្តួចប៉ុណ្ណោះចំពោះការរស់នៅរបស់ប្រជាជនខ្មែរសាមញ្ញ ។
- ជាងនេះទៅទៀត ជំនួយរបស់ម្ចាស់ជំនួយ មិនបានបង្កើតឱ្យមានកំណែទម្រង់ ដែលនឹងធ្វើឱ្យរដ្ឋាភិបាលកាន់តែទទួលខុសត្រូវចំពោះប្រជាជនរបស់ខ្លួននោះទេ ។ ជំនួសមកវិញ រដ្ឋាភិបាលកំពុងកេងប្រវ័ញ្ចយ៉ាងជោគជ័យនូវជំនួយអន្តរជាតិ ដែលជាប្រភពមួយនៃធម្មានុរូបនយោបាយ ។



| តារាង ១ ៖ បញ្ហាដែលអាចផ្វាធរយុត្តិធម៌របស់ប្រទេសកម្ពុជា ត្រូវតែស៊ើបអង្កេតនាពេលនេះ [iii] | | |
|---|---|---|
| **បុគ្គល** | **សកម្មភាព** | **ច្បាប់ពាក់ព័ន្ធ និងការដាក់ទោសសម្រាប់ការរំលោភបំពាន** |
| ឌី ចូច<br>សេង គាង<br>ឃុន ថុង | ការឃុំឃាំងដែលអាចមើលឃើញយ៉ាងច្បាស់លើ លី ជុនហួរ និងកាន់កាប់ដោយបង្ខំលើក្រុមហ៊ុន Kingwood Industry ។ | **ច្បាប់ស្តីពីបទល្មើសរំលោភរូបកាយ**<br>មាត្រា ៧ ៖ ការឃុំខ្លួន និងការឃុំឃាំងខុសច្បាប់<br>ទោស ៖ ជាប់ពន្ធនាគារ ៥-១០ ឆ្នាំ<br>មាត្រា ៦ ៖ លួចប្លន់<br>ទោស ៖ ជាប់ពន្ធនាគារ ៥-១០ ឆ្នាំ |
| សេង កុកហ៊ាង | ការប៉ុនប៉ងសម្លាប់សកម្មជនព្រៃឈើសហគមន៍ពីរនាក់ ដែលបានរាយការណ៍ ។ | **ច្បាប់ស្តីពីបទល្មើសរំលោភរូបកាយ**<br>មាត្រា ៣ ៖ សម្លាប់<br>ទោស ៖ ជាប់ពន្ធនាគារ ១៥-២០ ឆ្នាំ |
| ឌី ចូច<br>សេង គាង<br>ឃុន ថុង<br>សេង កុកហ៊ាង | ការកាប់ឈើទ្រង់ទ្រាយឧស្សាហកម្មនៅខាងក្រៅព្រំដែនចំការកៅស៊ូទីរីង និងការកាប់ឈើយកជ័ររាប់ពាន់ដើម ដែលជារបស់ប្រជាជនក្នុងមូលដ្ឋាន ។ | **ច្បាប់ព្រៃឈើ** មាត្រា ៩៨ ៖ ការប្រើប្រាស់លិខិតអនុញ្ញាតមិនត្រឹមត្រូវ ដើម្បីប្រមូលផលព្រៃឈើ ការប្រមូលផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ការកាប់រំលំពូជឈើកម្រ និងដើមឈើ ដែលប្រជាជនក្នុងមូលដ្ឋានយកជ័រ<br>ទោស ៖ ជាប់ពន្ធនាគារ ១-៥ ឆ្នាំ និងពិន័យជាប្រាក់ ១០-១០០ លានរៀល (US$2,500-US$25,000) ។<br>**ច្បាប់ភូមិបាល** មាត្រា ២៥៩ ៖ ការរំលោភបំពានលើទ្រព្យសម្បត្តិសាធារណៈ<br>ទោស ៖ ជាប់ពន្ធនាគារ ១-៥ ឆ្នាំ និង/ឬពិន័យជាប្រាក់ ៥-៥០ លានរៀល (US$1,250-US$12,500) ។<br>**ច្បាប់ស្តីពីបទល្មើសរំលោភរូបកាយ**<br>មាត្រា ៦ ៖ លួចប្លន់<br>ទោស ៖ ជាប់ពន្ធនាគារ ៥-១០ ឆ្នាំ<br>**ក្រមព្រហ្មទណ្ឌអ៊ុនតាក់** មាត្រា ៥២ ៖ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិខុសច្បាប់<br>ទោស ៖ ជាប់ពន្ធនាគារ ១-៣ ឆ្នាំ |
| | ដឹកជញ្ជូនឈើដែលមានតម្លៃរាប់លានដុល្លារ ដែលបានកាប់ក្នុងអំឡុងពេលប្រតិបត្តិការទាំងនេះ | **ច្បាប់ព្រៃឈើ** មាត្រា ៩៦ ៖ ការដឹកជញ្ជូនផលិតផលព្រៃឈើដែលបានទទួលតាមរយៈការប្រមូលផលខុសច្បាប់<br>ទោស ៖ ពិន័យពី ២-៣ ដងនៃតម្លៃផលិតផលព្រៃឈើ |
| | ប្រើប្រាស់លិខិតអនុញ្ញាតប្រមូល "អុស" ដើម្បីសម្របសម្រួលការដឹកជញ្ជូនឈើ | **ច្បាប់ពន្ធដារ** មាត្រា ១២៧ និងមាត្រា ១៣៥ ៖ ការលួចពន្ធ<br>ទោស ៖ ជាប់ពន្ធនាគារ ១-៥ ឆ្នាំ និង/ឬពិន័យជាប្រាក់ ១០-២០ លានរៀល (US$2,500-US$5,000) ។<br>**ច្បាប់ព្រៃឈើ** មាត្រា ៩៦ ៖ ការដឹកជញ្ជូនផលិតផលព្រៃឈើ ផ្ទុយទៅនឹងអ្វីដែលមានក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន<br>ទោស ៖ ពិន័យពី ២-៣ ដងនៃតម្លៃផលិតផលព្រៃឈើ |
| | កែច្នៃឈើទាំងនេះ | **ច្បាប់ព្រៃឈើ** មាត្រា ៩៦ ៖ ការកែច្នៃផលិតផលព្រៃឈើដែលបានទទួលតាមរយៈការប្រមូលផលខុសច្បាប់<br>ទោស ៖ ពិន័យពី ២-៣ ដងនៃតម្លៃផលិតផលព្រៃឈើ |
| | ដឹកជញ្ជូនផលិតផលសម្រេច | **ច្បាប់ព្រៃឈើ** មាត្រា ៩៦ ៖ ការដឹកជញ្ជូនផលិតផលព្រៃឈើដែលបានទទួលតាមរយៈការប្រមូលផលខុសច្បាប់<br>ទោស ៖ ពិន័យពី ២-៣ ដងនៃតម្លៃផលិតផលព្រៃឈើ |

| | | |
|---|---|---|
| | លក់ទំនិញទាំងនេះ | **ច្បាប់ព្រៃឈើ** មាត្រា ៩៦ : ការធ្វើពាណិជ្ជកម្មផលិតផលព្រៃឈើ ដែលបានទទួលតាមរយៈការប្រមូលផលខុសច្បាប់<br>ទោស : ពិន័យពី ២-៣ ដងនៃតម្លៃផលិតផលព្រៃឈើ |
| | ការបង់ប្រាក់ឱ្យមន្ត្រី ដើម្បីការពារ ឬបិទភ្នែកចំពោះសកម្មភាពខាងលើ | **ក្រមព្រហ្មទណ្ឌអ៊ុនតាក់** មាត្រា ៥៤ : អំពើពុករលួយដោយមានចេតនា<br>ទោស : ជាប់ពន្ធនាគារ ១-៣ ឆ្នាំ |
| | បង្កើតសមាគមក្រៅផ្លូវការ ដែលជួយដល់ការអនុវត្តសកម្មភាពខាងលើនេះ | **ក្រមព្រហ្មទណ្ឌអ៊ុនតាក់** មាត្រា ៣៦ : បទល្មើសដោយមានការរៀបចំទុក<br>ទោស : ជាប់ពន្ធនាគារ ៣-១៥ ឆ្នាំ |
| ចាន់ សារុន | ចេញលិខិតអនុញ្ញាត ដែលផ្តល់ការរ៉ាប់រងចំពោះការកាប់ឈើទ្រង់ទ្រាយឧស្សាហកម្ម នៅខាងក្រៅព្រំដែនចំការកៅស៊ូទីរឹង និងកាប់ឈើយកជ័ររបស់អ្នកភូមិ | **ច្បាប់ព្រៃឈើ** មាត្រា ១០០ : មន្ត្រីដែលអនុញ្ញាតដោយផ្ទាល់ ឬដោយប្រយោលឱ្យមានសកម្មភាពផ្ទុយនឹងច្បាប់ព្រៃឈើ<br>ទោស : ជាប់ពន្ធនាគារ ១-៥ ឆ្នាំ និងពិន័យជាប្រាក់ ១០-១០០ លានរៀល (US$2,500-US$25,000) ។<br>**ក្រមព្រហ្មទណ្ឌអ៊ុនតាក់** មាត្រា ៦៩ : ការរួមគំនិត<br>ទោស : ការដាក់ទោសអនុវត្តដូចគ្នានឹងអ្នកប្រព្រឹត្តល្មើស |
| | អនុញ្ញាតឱ្យសាងសង់រោងចក្របន្ទះឈើ និងរោងចក្រអារឈើដោយក្រុមហ៊ុន Seng Keang Company ក្នុងព្រៃឡង់ | **ច្បាប់ព្រៃឈើ** មាត្រា ៣០ : បម្រាមពីការសាងសង់រោងចក្រអារឈើក្នុងរង្វង់ ៥ គីឡូម៉ែត្រ (km) ពីតំបន់បម្រុងព្រៃឈើអចិន្ត្រៃយ៍ ។<br>មាត្រា ១០០ : មន្ត្រីដែលអនុញ្ញាតដោយផ្ទាល់ ឬដោយប្រយោលឱ្យមានសកម្មភាពផ្ទុយនឹងច្បាប់ព្រៃឈើ<br>ទោស : ជាប់ពន្ធនាគារ ១-៥ ឆ្នាំ និងពិន័យជាប្រាក់ ១០-១០០ លានរៀល (US$2,500-US$25,000) ។ |
| ចាន់ សារុន<br>ទី សុគន្ធ | លក់ការងាររាប់រយក្នុងរដ្ឋបាលព្រៃឈើ | **ក្រមព្រហ្មទណ្ឌអ៊ុនតាក់** មាត្រា ៣៨ : ការគម្រាមកំហែងយកប្រាក់<br>ទោស : ជាប់ពន្ធនាគារ ៣-៧ ឆ្នាំ ហើយពិន័យពីរដងលើប្រាក់សរុបដែលបានគម្រាមកំហែង ។ ហាមប្រាមឈរឈ្មោះបោះឆ្នោត ឬកាន់តំណែងរដ្ឋរយៈពេល ២ ឆ្នាំ បន្ទាប់ពីការកាត់ទោសបានកំណត់ឱ្យ ។ |
| ហ៊ីង ប៊ុនហៀង<br>ឌី ផេន | ត្រូវការ និងទទួលបានការបង់ប្រាក់ពីបរិវារ | **ក្រមព្រហ្មទណ្ឌអ៊ុនតាក់** មាត្រា ៣៨ : ការគម្រាមកំហែងយកប្រាក់<br>ទោស : ជាប់ពន្ធនាគារ ៣-៧ ឆ្នាំ ហើយពិន័យពីរដងលើប្រាក់សរុបដែលបានគម្រាមកំហែង ។ ហាមប្រាមឈរឈ្មោះបោះឆ្នោត ឬកាន់តំណែងរដ្ឋរយៈពេល ២ ឆ្នាំ បន្ទាប់ពីការកាត់ទោសបានកំណត់ឱ្យ ។ |
| ហាក់ ម៉ៅ | ដឹកជញ្ជូនឈើ និងផលិតផលពីឈើ ដែលមានតម្លៃរាប់លានដុល្លារ ដែលមានប្រភពមកពីតំបន់ដែលគ្មានប្រតិបត្តិការប្រមូលផលឈើស្របច្បាប់ | **ច្បាប់ព្រៃឈើ** មាត្រា ៩៦ : ការដឹកជញ្ជូនផលិតផលព្រៃឈើដែលបានទទួលតាមរយៈការប្រមូលផលខុសច្បាប់<br>ទោស : ពិន័យពី ២-៣ ដងនៃតម្លៃផលិតផលព្រៃឈើ |
| | ចាត់ចែង និងការពារការដឹកជញ្ជូនទំនិញដែលពន្ធនាំចូលតម្រូវឱ្យមានជាចាំបាច់ មិនត្រូវបានបង់ឱ្យ | **ច្បាប់ពន្ធដារ** មាត្រា ១២៧ និងមាត្រា ១៣៥ : ការលួចពន្ធ<br>ទោស : ជាប់ពន្ធនាគារ ១-៥ឆ្នាំ និង/ឬពិន័យជាប្រាក់ ១០-២០លានរៀល (US$2,500-US$5,000) ។<br>មាត្រា ១២៨ និងមាត្រា ១៣៦ : ការរារាំងដល់ការអនុវត្តពន្ធដារ<br>ទោស : ជាប់ពន្ធនាគារ ១ ខែ ទៅ ១ ឆ្នាំ និង/ឬពិន័យជាប្រាក់ ៥-១០ លានរៀល (US$1,250-US$2,500) ។ |
| | ប្រមូល ស្តុក និងបែងចែកទំនិញទាំងនេះ | **ក្រមព្រហ្មទណ្ឌអ៊ុនតាក់** មាត្រា ៥១ : ការទទួល និងលាក់ទំនិញដែលបានលួច<br>ទោស : ជាប់ពន្ធនាគារ ១-៥ ឆ្នាំ |

[iii] ចំណុចយោងសម្រាប់ចំណុចជាច្រើនដែលមានក្នុងផ្នែកនេះ អាចរកបានក្នុងផ្នែកខាងក្នុងនៃរបាយការណ៍នេះ ។

# ជំពូក I : ព្រៃឈើ និងស្ថានភាពមានតែឈ្មោះរបស់ប្រទេសកម្ពុជា

តាមសេចក្តីថ្លែងការណ៍ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៦ លោក Yash Ghai តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាបាននិយាយថា *"មនុស្សម្នាក់មិនត្រូវការជំនាញសិទ្ធិមនុស្ស ដើម្បីទទួលស្គាល់ថា គោលនយោបាយរដ្ឋាភិបាលជាច្រើន បានធ្វើឱ្យទន់ខ្សោយគោលការណ៍ប្រជាធិបតេយ្យចាំបាច់ និងដំណើរការសមរម្យ ដែលកាត់ផ្តាច់ប្រជាជនពីធនធានសេដ្ឋកិច្ចរបស់ពួកគេ និងមធ្យោបាយចិញ្ចឹមជីវិត ហើយមិនផ្តល់ឱ្យពួកគេនូវកិត្តិយសរបស់ពួកគេ ។ ខ្ញុំបានជឿថា គោលនយោបាយទាំងនេះមានសារៈសំខាន់ចំពោះប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងរបស់រដ្ឋាភិបាល ដែលសម្របសម្រួលដំណើរការប្រជាធិបតេយ្យ ធ្វើឱ្យអន្តរាយដល់គូប្រឆាំងនយោបាយតាមផ្លូវច្បាប់ និងបានប្រើប្រាស់រដ្ឋសម្រាប់បង្កើនទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។និយាយឱ្យខ្លី ខ្ញុំជឿជាក់ថា ការបដិសេធដែលបានគិតទុកជាមុនលើទស្សនាទានរដ្ឋគ្រប់គ្រងដោយនីតិរដ្ឋបានប្រមូលផ្តុំនៅលើអំណាចគ្រប់គ្រងរបស់គណៈបក្សកាន់អំណាច"* ។

ក្នុងឆ្នាំ ១៩៩១ សហគមន៍អន្តរជាតិ បានរ៉ាប់រងនាំយកប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍មកកាន់ប្រទេសកម្ពុជាមុនជម្លោះ ។ ជាងដប់ប្រាំឆ្នាំក្រោយមក អ្វីដែលតំណាងពិសេសអង្គការសហប្រជាជាតិបានលើកឡើងថា "លក្ខណៈខាងក្រៅនៃប្រជាធិបតេយ្យដែលមានភាពញ៉ែរញ៉ៃយ" របស់ប្រទេសកម្ពុជា គ្របពីលើរដ្ឋដែលមានតែឈ្មោះ[iv] ដែលត្រូវបានបង្កើតឡើងលើការឧបត្ថម្ភអំពើពុករលួយ និងការបង្ខិតបង្ខំ[១៧] ។រដ្ឋដែលមានតែឈ្មោះរបស់ប្រទេសកម្ពុជាប្រើប្រាស់ខុសច្បាប់នូវទ្រព្យសម្បត្តិសាធារណៈ គម្រាមកំហែងយកប្រាក់ពីអាជីវកម្ម និងចាត់ចែងសេដ្ឋកិច្ចខុសច្បាប់យ៉ាងច្រើន ។ រដ្ឋត្រូវបានគ្រប់គ្រងដោយទេសរដ្ឋមន្ត្រី ដែលមានជំនាញក្នុងការនិយាយភាសាមិនត្រឹមត្រូវពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

នាយករដ្ឋមន្ត្រី ហ៊ុន សែន និងមជ្ឈដ្ឋានខាងក្នុងរបស់គាត់បានប្រើប្រាស់វិធីសាស្ត្រមុខពីរនេះក្នុងរដ្ឋាភិបាល តាំងពីចុងទសវត្សរ៍ឆ្នាំ ១៩៨០ មកម្ល៉េះ ។ បន្ទាប់ពីរក្សាការលាក់កំបាំងសង្គមនិយមដើម្បីឱ្យអ្នកណែនាំវៀតណាមស្ងប់ចិត្ត ឥឡូវនេះពួកគេមានគម្រោងប្រហាក់ប្រហែលប្រជាធិបតេយ្យសេរី ដែលតម្រង់ទៅកាន់ម្ចាស់ជំនួយលោកខាងលិច ។ នៅតាមផ្លូវនេះ ពួកគេបានពង្រឹងជាលំដាប់នូវការច្បាមយកអំណាច ដោយមធ្យោបាយនយោបាយ និងសេដ្ឋកិច្ច ។

## ១. ការច្រៀកទ្រព្យសម្បត្តិរបស់ប្រទេសកម្ពុជា

រដ្ឋដែលមានតែឈ្មោះរបស់ប្រទេសកម្ពុជា បង្កើតទ្រព្យសម្បត្តិខុសច្បាប់ជាច្រើនរបស់ខ្លួន តាមរយៈការដកហូតតាមផ្លូវច្បាប់នូវទ្រព្យសម្បត្តិសាធារណៈ ជាពិសេសធនធានធម្មជាតិ ក៏ដូចជាតាមរយៈអំពើពុករលួយក្នុងស្ថាប័ន[១៨] ។ដោយយោងជាពិសេសទៅកាន់វិស័យព្រៃឈើ របាយការណ៍នេះពិនិត្យមើលលើវិធីសាស្ត្រធំៗបី ដែលនេះនឹងធ្វើការ :

***បែងចែកទ្រព្យសម្បត្តិសាធារណៈឱ្យមិត្តជិតស្និទ្ធ និងសាច់ញាតិរបស់អ្នកដឹកនាំកម្ពុជា***



ឡៅ ម៉េងឃិន និង ជឹង សុភាព (ក៏ត្រូវបានស្គាល់ផងដែរថាជា យាយភូ) ទាំងអស់គ្នាគ្រប់គ្រងក្រុមហ៊ុន Pheapimex ដែលប្រហែលជាក្រុមហ៊ុនមានអំណាចបំផុតរបស់ប្រទេសកម្ពុជា ។ តាមរយៈសម្បទានឈើ និងសម្បទានដីសេដ្ឋកិច្ច ក្រុមហ៊ុន Pheapimex គ្រប់គ្រងផ្ទៃដី ៧.៤% នៃផ្ទៃដីសរុប[១៩]

នេះពាក់ព័ន្ធការបែងចែកសម្បទានព្រៃឈើ ដីធ្លី ស្រទាប់រ៉ែ មច្ឆា និងតំបន់កើ្តដំណែលស្របកិច្ចព្រមព្រៀង "ផ្លាស់ប្តូរដី" លើអាគារកាន់កាប់ដោយរដ្ឋ ។ ប្រតិបត្តិការជាច្រើនក្នុងចំណោមនេះគឺខុសច្បាប់ ។ អ្នកទទួលប្រយោជន៍គឺជាមហាសេដ្ឋីមួយក្រុមតូច ដែលមានចំណងនយោបាយអាជីវកម្ម ឬគ្រួសារជាមួយមន្ត្រីជាន់ខ្ពស់ ។ ផលប៉ះពាល់ គឺនឹងដាក់ឱ្យទ្រព្យសម្បត្តិសាធារណៈស្ថិតក្រោមការគ្រប់គ្រងរបស់បុគ្គលឯកជន ដែលពួកគេជាផ្នែកមួយនៃរចនាសម្ព័ន្ធរដ្ឋមានតែឈ្មោះ។

ក្នុងការបកស្រាយបង្ហាញពីការត្រួតស៊ីគ្នារវាងនយោបាយ និងអាជីវកម្មនេះ មហាសេដ្ឋីចំនួនប្រាំមួយ ក្នុងចំណោមមហាសេដ្ឋីខ្លាំងបំផុត

[iv] "រដ្ឋដែលមានតែឈ្មោះ" គឺជាពាក្យមួយដែលបង្កើតដោយបណ្ឌិតសភា William Reno ដើម្បីរៀបរាប់ពីវិធីដែលរដ្ឋាភិបាលត្រូវអនុម័តដោយប្រមុខរដ្ឋអាហ្វ្រិក ។ លក្ខណៈបង្ហាញពី "រដ្ឋដែលមានតែឈ្មោះ" ទាំងនេះ រួមមាន ការប្រើប្រាស់បណ្តាញក្រៅផ្លូវការ ដើម្បីបង្កើនទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងអនុវត្តអំណាច ធ្វើឱ្យអន្តរាយដោយគិតទុកជាមុនដល់ស្ថាប័នផ្លូវការរបស់រដ្ឋាភិបាល និងបែបបទគ្រប់គ្រងបដិរូបខ្ពស់ដែលមិនអនុវត្តយោងតាមច្បាប់ ។(William Reno "សេដ្ឋកិច្ចផ្ទុយច្បាប់អំពើហិង្សា និងរដ្ឋក្នុងអាហ្វ្រិក" សារព័ត៌មានកិច្ចការអន្តរជាតិលេខ ៥៣ ឆ្នាំ ២០០០) ។

សម្បទានលើទ្រព្យសម្បត្តិសាធារណៈ

កិច្ចសន្យា និងលិខិតអនុញ្ញាតរបស់រដ្ឋាភិបាល ការចូលទៅកាន់គ្រួសាររបស់ ហ៊ុន សែន

## រូបភាពទី ១ : សេដ្ឋី - ព្រឹទ្ធសមាជិករបស់ប្រទេសកម្ពុជា




ឯកសារយោងនៃទិន្នន័យនេះ មានការបកស្រាយនៅក្នុងឧបសម្ព័ន្ធ ១



ហ៊ុន សែន ត្រូវបានអរគុណដោយមេបញ្ជាការ ឧត្តមសេនីយ៍ កែ គឹមយ៉ាន នៃកងយោធពលខេមរភូមិន្ទ និងឧត្តមសេនីយ៍ ទៀ បាញ់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

បច្ចុប្បន្ននេះ ត្រូវបានតែងតាំងជាព្រឹទ្ធសមាជិកសម្រាប់គណបក្សប្រជាជនកម្ពុជារបស់ ហ៊ុន សែន ។ អ្នកទាំងប្រាំមួយនោះ គឺ កុក អាន, គង់ ទ្រីវ, លី យ៉ុងផាត់, ឡៅ ម៉េងឃិន (ដែលស្របជាមួយភរិយារបស់គាត់ យាយភូ គ្រប់គ្រងក្រុមហ៊ុន Pheapimex) ម៉ែន សារុន[១៩] និង ម៉ុង ឫទ្ធី ។ រូបភាព ១ រៀបរាប់សង្ខេបពីផលប្រយោជន៍ចម្បងៗរបស់ពួកគេ ។

ព័ត៌មានពីកិច្ចព្រមព្រៀងពាក់ព័ន្ធទ្រព្យសម្បត្តិសាធារណៈ មិនត្រូវបានធ្វើឱ្យអាចទទួលបានដល់ប្រជាជនកម្ពុជា ដែលពួកគេទាំងអស់គ្នាជាម្ចាស់នោះទេ ។ សម្រាប់ពលរដ្ឋធម្មតា ដែលការចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកលើធនធាន ដែលកំពុងត្រូវបានចុះហត្ថលេខាលក់ចេញដំបូង ដែលពួកគេឮពីសម្បទានថ្មី ជាញឹកញាប់ គឺជាសម្លេងនៃរណារយន្តកាត់ព្រៃឈើរបស់ពួកគេ ឬម៉ាស៊ីនឈូសពង្រាបដំណាំរបស់ពួកគេ ។

ផលប៉ះពាល់លើមនុស្សភ្លាមៗនៃការច្រៀកយកទ្រព្យសម្បត្តិនេះ គឺបដិសេធសិទ្ធិចេញចូលរបស់ប្រជាជនខ្មែរទៅកាន់ធនធានធម្មជាតិ និងក្នុងករណីខ្លះ បណ្ដេញពួកគេចេញពីផ្ទះរបស់ពួកគេ ។ កាន់តែទូលំ-ទូលាយថែមទៀតនោះ ការពុះច្រៀកនេះ កាត់ផ្ដាច់ចំណូលពីប្រជាជនទាំងអស់ ដែលអាចទាញយកមកពីការគ្រប់គ្រងប្រកបដោយចីរភាពនូវទំនិញសាធារណៈទាំងនេះ ។ អំពើពុករលួយដែលសម្របសម្រួលសម្បទានច្រៀកទ្រព្យសម្បត្តិនេះ ធ្វើឱ្យអន្តរាយដល់នីតិរដ្ឋ ស្របពេលការបង្កើនទ្រព្យសម្បត្តិរបស់គ្រួសារអ្នកដឹកនាំ ផ្ដល់ឱ្យពួកគេនូវអំណាច និងភាពគ្មានទោសដែលកាន់តែកើនឡើង ។ លទ្ធផលចុងក្រោយ គឺថាប្រជាជនខ្មែរដែលក្រីក្ររួចហើយនោះ កាន់តែក្រទៅៗ ហើយឃើញថាកាន់តែពិបាកក្នុងការទាញយកអ្នកគ្រប់គ្រងប្រទេសឱ្យទទួលខុសត្រូវ ។




បណ្ណចេញដោយខ្មែរក្រហមឱ្យអ្នកកាប់ឈើប្រតិបត្តិការក្នុងតំបន់ដែលពួកគេបានគ្រប់គ្រង

### *អំពើពុករលួយក្នុងស្ថាប័នរដ្ឋាភិបាលដែលបង្កើនទ្រព្យធនមន្ត្រីជាន់ខ្ពស់*

ចួនកាលអំពើពុករលួយក្នុងប្រទេសកម្ពុជា ត្រូវបានពណ៌នាតែថាជាយន្តការរស់រាន ដោយមន្ត្រីរាជការដែលមានបៀវត្សមិនសមរម្យ ។ ទោះយ៉ាងណាក៏ដោយ ក្នុងស្ថាប័នទាំងនេះ ជាមួយទំហំធំបំផុតសម្រាប់ស្វែងរកថ្លៃឈ្នួល ជាទូទៅ បុគ្គលិកចំណាយសម្រាប់ការងាររបស់ពួកគេ ធ្វើការបង់ប្រាក់ជាប្រចាំដើម្បីរក្សាពួកគេ និងរំពឹងថាបានមកវិញនូវចំណាយទាំងនេះ តាមរយៈអំពើពុករលួយ[២០] ។ ប្រាក់ដែលបានមកតាមរយៈការអនុវត្តអំពើពុករលួយហូរទៅខាងលើតាមរយៈរចនាសម្ព័ន្ធពីរ៉ាមីត ដែលមានការបែងចែកច្រើនបំផុតបង្កើនក្នុងហោប៉ៅរបស់អ្នកទាំងឡាយដែលស្ថិតនៅកម្រិតកំពូលនៃឋានានុក្រម[២១] ។ បន្ទុកនៃអំពើពុករលួយជារៀងរាល់ថ្ងៃក្នុងប្រទេសកម្ពុជា ធ្លាក់ធ្ងន់បំផុតទៅលើអ្នកទាំងឡាយដែលគ្មានអំណាច និងទំនាក់ទំនង ដើម្បីប្រឆាំងតបត ។

### *ការគ្រប់គ្រងសេដ្ឋកិច្ចខុសច្បាប់របស់ទ័ព*

កងយោធពលខេមរភូមិន្ទ (RCAF) មានគោលបំណងយុទ្ធសាស្ត្របន្តិចបន្តួច និងសមត្ថភាពប្រតិបត្តិការគួរឱ្យសង្ស័យ ។ ពួកគេចូលរួមយ៉ាងពេញទំហឹងក្នុងកិច្ចព្រមព្រៀងពាក់ព័ន្ធទ្រព្យសម្បត្តិសាធារណៈ គួរឱ្យកត់ចំណាំតាមរយៈករណី ដែលមិនបានលាតត្រដាងពី "តំបន់អភិវឌ្ឍន៍យោធា" ដែលគ្របដណ្ដប់លើផ្ទៃដី ៧00,000 ហិកតា (ha) ឬស្មើរតែបួន ភាគរយនៃផ្ទៃដីរបស់ប្រទេសកម្ពុជា[២២] ។ មន្ត្រីជាន់ខ្ពស់របស់កងយោធពលខេមរភូមិន្ទ គឺជាអ្នកសំដែងដ៏សំខាន់ក្នុងសកម្មភាពអាជីវកម្មខុសច្បាប់ ដូចជាការកាប់ឈើ និងការជួញដូរថ្នាំញៀន[២៣] ។ ពួកគេក៏បង្កើតប្រាក់ដ៏ច្រើនពីការគម្រាមកំហែងយកប្រាក់ផងដែរ[២៤] ។

## ២. វិស័យព្រៃឈើរបស់ប្រទេសកម្ពុជា

វិស័យព្រៃឈើរបស់ប្រទេសកម្ពុជា ផ្តល់នូវការពន្យល់បង្ហាញដ៏រស់រវើកជាពិសេសពីរបៀប ដែលអ្នកដឹកនាំរបស់ប្រទេសបានលួចយកទ្រព្យសម្បត្តិសាធារណៈ ។

ក្នុងសង្គ្រាមស៊ីវិលរបស់ប្រទេសកម្ពុជាជាច្រើនឆ្នាំមុន ដែលបានបញ្ចប់ក្នុងឆ្នាំ ១៩៩៨ ទាំងរដ្ឋាភិបាលខ្មែរក្រហម និងភ្នំពេញ បានប្រើ-ប្រាស់ការកាប់ឈើដើម្បីផ្តល់ប្រាក់ដល់យុទ្ធនាការយោធានិងក្រោយមកបានប្រើប្រាស់យុទ្ធនាការយោធាជាលេស សម្រាប់ការកាប់ឈើបន្ថែមទៀត ។ តាំងតែពីពេលនោះមក អ្នកដឹកនាំរបស់ប្រទេសកម្ពុជាបានរកឃើញថា មានការពិបាកក្នុងការទាត់ចោលទម្លាប់ប្រព្រឹត្តចំពោះព្រៃឈើរបស់ប្រទេស ដែលជាប្រាក់ស្មោកគ្រោកសម្រាប់យុទ្ធនាការនយោបាយការបង្កើនធនធានផ្ទាល់ខ្លួន និងលើកទឹកចិត្តអតិថិជនសំខាន់ៗ ។

ក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ រដ្ឋមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់បានផ្តល់ឱ្យជាសម្ងាត់សម្បទានព្រៃឈើរវាងពី ៣០ និង ៤០ ទៅឱ្យក្រុមហ៊ុនដែលគ្រប់គ្រងដោយជនជាតិខ្មែរ និងបរទេស ។ កិច្ចសន្យាត្រូវបានចុះហត្ថលេខាផ្តល់ឱ្យព្រៃឈើជាងប្រាំពីរលានហិកតា ៣៩% នៃផ្ទៃដីរបស់ប្រទេសកម្ពុជាក្នុងអំឡុងពេលដែលបំពេញផលប្រយោជន៍យ៉ាងខ្លាំងដល់សម្បទានិកទៅលើសម្បទានរបស់ប្រទេសកម្ពុជា[២៥] ។ សម្បទានិកទាំងអស់បានដំណើរការបំពានច្បាប់ ឬលក្ខខណ្ឌនៃកិច្ចសន្យារបស់ពួកគេ ឬទាំងពីរ ។ នៅចុងទសវត្សរ៍នោះ ពួកគេបានទទួលខុសត្រូវចំពោះការកាប់ឈើខុសច្បាប់ជាច្រើនបំផុតក្នុងប្រទេសកម្ពុជា ។

### *កំណែទម្រង់*

ជាដំបូង Global Witness បានចាប់ផ្តើមថ្លែងពីការកាប់ឈើខុសច្បាប់ក្នុងប្រទេសកម្ពុជា ហើយនិងទំនាក់ទំនងរបស់ខ្លួនជាមួយជម្លោះអំពើពុករលួយនិងការរំលោភបំពានសិទ្ធិមនុស្សក្នុងឆ្នាំ១៩៩៥ ។ សម្ពាធអន្តរជាតិលើរដ្ឋាភិបាល ដើម្បីទប់ទល់ការបំផ្លិចបំផ្លាញព្រៃឈើបានរៀបចំឡើង ហើយនៅចុងឆ្នាំ ១៩៩៨ ហ៊ុន សែន បានប្រកាសថាគាត់នឹងដោះស្រាយបទល្មើសព្រៃឈើនិងកំណែទម្រង់ស្ថាប័ន ។ បាតុភូតជាក់ច្បាស់របស់នាយករដ្ឋមន្ត្រី កើតឡើងស្របតាមការធ្លាក់ចុះសមត្ថភាពគូបដិបក្ខរបស់គាត់ ដើម្បីប្រកួតប្រជែងចំពោះប្រាក់ចំណូលពីការកាប់ឈើ ។ នេះពាក់ព័ន្ធជាមួយនឹងរដ្ឋប្រហាររបស់គណបក្សប្រជាជនប្រឆាំងនឹងដៃគូចម្រុះហ្វ៊ុនស៊ិនប៉ិចរបស់ខ្លួន ក្នុងខែកក្កដា ឆ្នាំ ១៩៩៧ ជ័យជំនះរបស់ខ្លួនក្នុងការបោះឆ្នោតជាតិនៅឆ្នាំបន្ទាប់ និងការបំបែកបំបាក់ពួកខ្មែរក្រហមចុងក្រោយ ។

រដ្ឋាភិបាលបង្ក្រាបសកម្មភាពរបស់អ្នកកាប់ឈើខុសច្បាប់ដែលមានទំនាក់ទំនងល្អបានយ៉ាងត្រឹមត្រូវ អនុម័តច្បាប់ថ្មីនិងក្នុងឆ្នាំ១៩៩៩ យល់ព្រមតែងតាំង Global Witness ជាអ្នកត្រួតពិនិត្យឯករាជ្យទៅលើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងបទល្មើសព្រៃឈើ ។ ក្នុងខែ កញ្ញា ឆ្នាំ ២០០១ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើគំនិតផ្តួចផ្តើមអនុវត្ត និងអភិបាលកិច្ចច្បាប់ព្រៃឈើ (FLEG) តំបន់អាស៊ីបូព៌ា ដោយរដ្ឋាភិបាលប្តេជ្ញាចិត្ត "ចាត់វិធានការណ៍បន្ទាន់ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងពង្រឹងសហប្រតិបត្តិការទ្វេភាគីថ្នាក់តំបន់ និងពហុភាគី ដើម្បីដោះស្រាយចំពោះការរំលោភបំពានច្បាប់ព្រៃឈើ និងបទល្មើសព្រៃឈើ ជាពិសេសការកាប់ឈើខុសច្បាប់ ការធ្វើពាណិជ្ជកម្មខុសច្បាប់ និងអំពើពុករលួយពាក់ព័ន្ធ និងផលប៉ះពាល់អវិជ្ជមានរបស់ពួកគេទៅលើនីតិរដ្ឋ"[២៦] ។

សម្រាប់ផ្នែកមួយរបស់ពួកគេ សម្បទានិកឈើមិនបានអនុវត្តតាមលក្ខខណ្ឌដំណើរការស្តារឡើងវិញ ដែលតម្រូវឱ្យពួកគេបង្កើតផែនការគ្រប់គ្រងព្រៃឈើប្រកបដោយចេរភាព (SFMPs) និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម (ESIAs) ។ មួយចំនួនអនុវត្តការកាប់ឈើខុសច្បាប់ ។ ដោយស្ថិតក្រោមសម្ពាធឱ្យអនុវត្តចុងក្រោយ រដ្ឋាភិបាលបានបញ្ឈប់មួយរយៈនូវប្រតិបត្តិការសម្បទានិកចាប់ពី ខែ មករា ឆ្នាំ ២០០២ ។

ក្នុងឆ្នាំ ២០០៣ ម្ចាស់ជំនួយអន្តរជាតិ និងរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមការងារអ្នកពិគ្រោះយោបល់អន្តរជាតិមួយ ដើម្បីអនុវត្តការវាយតម្លៃវិស័យព្រៃឈើដោយឯករាជ្យ (IFSR) និងរៀបចំ "ផែនទីផ្លូវ" សម្រាប់កំណែទម្រង់វិស័យព្រៃឈើ ។ ក្នុងឆ្នាំ ២០០៤ អ្នកពិគ្រោះយោបល់ទាំងនេះ បានផ្តល់អនុសាសន៍ឱ្យរដ្ឋាភិបាលបញ្ឈប់ប្រព័ន្ធសម្បទានកាប់ឈើ និងប្រគល់ទំនួលខុសត្រូវគ្រប់គ្រងព្រៃឈើឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានទទួលការបោះឆ្នោតឱ្យជាមួយនឹងរដ្ឋបាលព្រៃឈើ (FA) ដែលដើរតួនាទីចេញច្បាប់ ។ មូលដ្ឋានសម្រាប់គំរូ "ព្រៃភាពជាដៃគូ" គឺជាការផ្តល់អំណាចដល់ប្រជាជនដែលរស់នៅក្នុង និងជុំវិញព្រៃឈើ ហើយការត្រួតពិនិត្យ និងតុល្យភាពស្ថាប័នកាន់តែទូលំទូលាយ មានបំណងកាត់បន្ថយអំពើពុករលួយ ។ ទោះយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានបង្ហាញនូវភាពសប្បាយរីករាយមានកំណត់ចំពោះសំណើរបស់ IFSR ហើយសហគមន៍ម្ចាស់ជំនួយអន្តរជាតិមិនបានគាំទ្រពួកគេខ្លាំងគ្រប់គ្រាន់ល្មមនោះទេ ។

### *រដ្ឋដែលមានតែឈ្មោះវាយប្រហារត្រឡប់វិញ*

ទោះបីជាស្របពេលដែលរដ្ឋមន្ត្រីថ្នាក់ខ្ពស់បានប្តេជ្ញាចិត្តចំពោះដំណើរការកំណែទម្រង់ក៏ដោយ រដ្ឋដែលមានតែឈ្មោះរបស់ប្រទេសកម្ពុជា បានបន្តរកប្រាក់ពីវិស័យព្រៃឈើដដែល ។ មន្ត្រីដដែលនេះដែលទទួលខុសត្រូវអនុវត្តកំណែទម្រង់យ៉ាងសកម្ម បានធ្វើឱ្យពួកគេអន់ខ្សោយ ដោយហេតុនេះ ការកាប់ឈើខុសច្បាប់បានបន្តក្នុងទម្រង់ផ្សេងៗជាច្រើន :

### *លិខិតអនុញ្ញាត*

នៅក្នុងលទ្ធផលពីការចាត់វិធានការណ៍បំបាត់ និងការបង្អាក់ប្រតិបត្តិការសម្បទានកាប់ឈើ ការចេញនូវលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណ ដែលលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណទាំងនេះ មានលក្ខណៈខុសច្បាប់ ឬត្រូវបានរៀបចំឡើង ដើម្បីផ្តល់ការបិទបាំងដល់សកម្មភាពខុសច្បាប់ មានការកើនឡើង និងប្លែកៗពីគ្នា ។ ទាំងនេះ រួមមានលិខិតអនុញ្ញាតឱ្យប្រមូល "ឈើចាស់ៗ" - ដែលជាការអនុវត្តត្រូវបានហាមប្រាមដោយ ហ៊ុន សែន ក្នុងឆ្នាំ ១៩៩៩ ដោយសារតែការ

ប្រើប្រាស់យ៉ាងទូលំទូលាយរបស់ខ្លួនជាការបិទបាំងប្រតិបត្តិការកាប់ឈើខុសច្បាប់ ។ ការផ្លាស់ប្តូរដោយការច្នៃប្រឌិតទៅលើទិដ្ឋភាពប្រមូល "ឈើចាស់ៗ" ក៏បានកើតឡើងផងដែរដែលគួរឱ្យកត់សំគាល់ គឺអាជ្ញាប័ណ្ណប្រមូលសំគាល់ឈើ មែកឈើ និងឈើវែង ការអនុញ្ញាតឱ្យកាប់ឈើសម្រាប់ទូកប្រណាំង និងលិខិតអនុញ្ញាតសាងសង់បន្ទាយឈើសម្រាប់កងវរះសេនាធំឆ័ត្រយោង ដើម្បីលោត[២៧] ។



លិខិតអនុញ្ញាតដែលអនុញ្ញាតឱ្យកងវរសេនាធំឆ័ត្រយោងកាប់ឈើ

## *ការដាំដើមឈើ*

ការចេញលិខិតអនុញ្ញាតឆ្លៀតឱកាស បានរួមជាមួយផែនការសម្របសម្រួលការកាប់ឈើដែលមានមហិច្ឆតាកាន់តែខ្លាំងឡើង ។ ច្រើនបំផុតក្នុងចំណោមនេះ គឺការកាប់ឈើក្នុងឈ្មោះនៃការអភិវឌ្ឍន៍ដាំដើមឈើ ភាពឱនលំទោននៃគម្រោងអភិវឌ្ឍន៍ដឹកនាំដោយរដ្ឋាភិបាល ឬសម្បទានដីសេដ្ឋកិច្ច (ELCs) ។ តាមរយៈគ្រោងការណ៍ទាំងនេះ មន្ត្រីបានផ្តល់ដីឱ្យមហាសេដ្ឋី ដែលគាំទ្រគណបក្សប្រជាជនកម្ពុជា ដែលមានព្រៃឈើមានតម្លៃ ។ បន្ទាប់មកព្រៃឈើត្រូវបានកាប់រំលំដោយយកឈ្មោះថាធ្វើផ្លូវដាំដើមឈើ ហើយឈើត្រូវបានចម្រាញ់និងលក់ ។ ស្ថានភាពនៃសម្បទានដីសេដ្ឋកិច្ចទៅលើព្រៃឈើល្មើសទៅនឹងច្បាប់ភូមិបាលឆ្នាំ ២០០១ របស់ប្រទេសកម្ពុជា ដែលចាត់ព្រៃឈើជា *ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ* ហើយអនុញ្ញាតឱ្យមានសម្បទានដីសេដ្ឋកិច្ចតែចំពោះ *ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ*ប៉ុណ្ណោះ ។សម្បទានដីសេដ្ឋកិច្ចជាច្រើនលើសពីកម្រិតកំណត់ ១០,០០០ហា របស់ច្បាប់ ។ ប្រសិនបើមិនមែនទាំងអស់ទេ ភាគច្រើនបំផុត អ្នកកាន់កាប់សម្បទានដីសេដ្ឋកិច្ច មិនបានបំពេញតាមតម្រូវការច្បាប់ ដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានឡើយ ។

ប្រតិបត្តិការកាប់សំអាត ដែលចង្អុលបង្ហាញពី "ការអភិវឌ្ឍន៍ដាំដើមឈើ" ធ្វើឱ្យមានការបំផ្លាញចោលទាំងស្រុងនូវព្រៃឈើ ។ ការបំផ្លាញនេះ គឺហៀបបាត់បង់អស់ទៅហើយ ។ជំពូក II រៀបរាប់បង្ហាញពីករណីអភិវឌ្ឍន៍ដាំដើមឈើ ដែលកំពុងត្រូវបានប្រើប្រាស់ជាលេសសម្រាប់ការកាប់ឈើទ្រង់ទ្រាយខុសច្បាប់កម្មថ្មីក្នុងព្រៃឡង់ ដែលជាព្រៃបៃតងទំនាបធំបំផុតក្នុងអាស៊ីអាគ្នេយ៍ដីគោក ។

## *ការកាប់ឈើរបស់យោធា*

ពេលដែលលិខិតអនុញ្ញាត និងផែនការដាំដើមឈើ ផ្តល់ឱ្យការកាប់ឈើនូវភាពរលូននៃការិយាល័យធិបតេយ្យ កងយោធពលខេមរភូមិន្ទ បានរក្សាការបំផ្លិចបំផ្លាញព្រៃឈើរបស់ប្រទេស ដែលមិនធ្វើ សូម្បីតែធ្វើឱ្យមានលក្ខណៈស្របច្បាប់ ។ អង្គភាពកងយោធពលខេមរភូមិន្ទជាច្រើនមានទីតាំងនៅក្នុង ឬជុំវិញព្រៃឈើ ហើយធ្វើប្រតិបត្តិការកាប់ឈើខុសច្បាប់ ដែលរៀបចំឆ្ពោះទៅកាន់ការបង្កើនទ្រព្យសម្បត្តិរបស់មេបញ្ជាការពួកគេ ។



ឡានដឹកឈើធំៗ របស់ក្រុមហ៊ុនកាប់ឈើ ខែ មីនា ឆ្នាំ ២០០៦

ក្នុងខែវិច្ឆិកា ឆ្នាំ ២០០៤ ក្នុងពាក់កណ្ដាលនៃ "សង្គ្រាមប្រឆាំងអំពើពុករលួយ" ដែលប្រកាសដោយ ហ៊ុន សែន Global Witness បានចេញផ្សាយនូវទទួលយកការកាប់ ដែលជាសេចក្ដីរាយការណ៍ពីការកាប់ឈើរបស់យោធា និងការគម្រាមកំហែងយកប្រាក់នៅតំបន់ជម្រកសត្វព្រៃឱរ៉ាល់ ដែលមានឈ្មោះមន្ត្រីកងយោធពលខេមរភូមិន្ទជាន់ខ្ពស់មួយចំនួន ដែលបានទទួលយកផលប្រយោជន៍ ។ អ្នកនាំពាក្យរដ្ឋាភិបាលម្នាក់បានរិះគន់ Global Witness ចំពោះការធ្វើឱ្យព័ត៌មានដឹងជាសាធារណៈ ដោយមិនបានផ្ដល់ព័ត៌មាននេះឱ្យរដ្ឋាភិបាលជាមុន តែមិនបានជំទាស់ចំពោះការចោទប្រកាន់ជាក់លាក់ ដែលបានធ្វើឡើងនោះទេ[២៨] ។ អាជ្ញាធរមិនបានចាត់វិធានការណ៍ខ្លាំង ដើម្បីបញ្ឈប់បទល្មើសព្រៃឈើក្នុងភ្នំឱរ៉ាល់ និងតាមជំពូក IV បង្ហាញថា យោធានៅតែចូលរួមយ៉ាងខ្លាំងក្នុងការកាប់ឈើខុសច្បាប់នៃតំបន់ការពារ និងព្រៃផលិតកម្មទូទាំងប្រទេស ។

### *ការរៀបចំការដេញថ្លៃប្រចាំឆ្នាំ*

បន្ទាប់ពីការបញ្ឈប់មួយរយៈនូវសម្បទានកាប់ឈើ រដ្ឋបាលព្រៃឈើបានចាប់ផ្ដើមបង្កើតការរៀបចំដេញថ្លៃប្រចាំឆ្នាំ ដែលជាជម្រើសមួយ ។ ប្រព័ន្ធសម្បទានផ្ដល់ឱ្យក្រុមហ៊ុនកាន់កាប់លើព្រៃឈើធំៗ ប៉ុន្តែជាធម្មតា បែងចែកជាតូចៗចំនួនម្ភៃប្រាំផ្នែក ដែលក្នុងនោះ សម្បទានិកអាចប្រមូលផលម្ដងក្នុងមួយឆ្នាំ ។ ផ្ទុយមកវិញ ការរៀបចំដេញថ្លៃប្រចាំឆ្នាំ គឺជាកញ្ចប់ព្រៃឈើកាន់តែតូច ដែលក្រុមហ៊ុនកាប់សម្រាប់ត្រឹមតែ ១២ ខែប៉ុណ្ណោះ ។ តាមទ្រឹស្ដីរដ្ឋបាលព្រៃឈើឥឡូវនេះអាចបំបែកព្រៃដែលមានទំហំសម្បទាន ទៅជាកញ្ចប់ដេញថ្លៃប្រចាំឆ្នាំចំនួន ២៥ ហើយផ្ដល់កញ្ចប់ទាំងអស់សម្រាប់ការកាប់ឈើជាបន្តបន្ទាប់ ហេតុនេះ បង្កើនអត្រាកាប់បំផ្លិចបំផ្លាញព្រៃឈើកាន់តែខ្លាំងឡើង ។

មានតម្លាភាពតិចតួចប៉ុណ្ណោះ ក្នុងការធ្វើសេចក្ដីសម្រេចចិត្តរបស់រដ្ឋបាលព្រៃឈើ ហើយការពិតដែលថា ព្រំដែនរៀបចំដេញថ្លៃប្រចាំឆ្នាំនឹងត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ អាចធ្វើឱ្យស្ថានភាពកាន់តែអាក្រក់ទៅៗ ។ សមាជិក សាធារណជន នឹងស្វែងរកកាន់តែពិបាកនូវដាន ដែលក្រុមហ៊ុនមានលិខិតអនុញ្ញាតប្រមូលផលនៅពេលណាមួយ ហើយហេតុនេះ កាន់តែពិបាកក្នុងការនាំពួកគេមកឱ្យទទួលខុសត្រូវ ។ បទដ្ឋាននៃការធ្វើផែនការគ្រប់គ្រង ការវាយតម្លៃផល-ប៉ះពាល់បរិស្ថាន និងសង្គម ការពិគ្រោះយោបល់សាធារណៈ និងការអនុវត្តច្បាប់ ដែលបានកប់ជ្រៅទៅហើយក្រោមរបបសម្បទាន ហាក់បីដូចជាកាន់តែធ្វើឱ្យយ៉ាប់ឡើងៗ ។

ប្រព័ន្ធថ្មីក៏នឹងចូលរួមក្នុងការសាងសង់បណ្ដាញផ្លូវតាមព្រៃ តាមតំបន់ព្រៃ ដើម្បីឱ្យក្រុមហ៊ុនកាប់ឈើទទួលបានការរៀបចំដេញថ្លៃប្រចាំរបស់ពួកគេ ។ ការសាងសង់ផ្លូវនៅប្រទេសកម្ពុជា ក៏ដូចជាកន្លែងផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ បានផ្ដល់ឱ្យនូវការបិទបាំងការកាប់ឈើដែលគ្មានការត្រួតពិនិត្យ និងបើកចំហផ្លូវព្រៃដែលមិនអាចចូលដល់ពីមុន ដល់ការធ្វើខុសច្បាប់ រុករានដី និងប្រតិបត្តិការកាប់ឈើខុសច្បាប់បន្ទាប់បន្សំ ។ ដោយការទទួលស្គាល់នូវការគម្រាមកំហែងទាំងនេះ ការវាយតម្លៃវិស័យព្រៃឈើដោយឯករាជ្យ ឆ្នាំ ២០០៤ បានផ្ដល់អនុសាសន៍ឱ្យបញ្ឈប់ការសាងសង់ផ្លូវនៅតំបន់ព្រៃ ។

តាមប្រអប់ ១ បង្ហាញលិខិតអនុញ្ញាតរៀបចំដេញថ្លៃប្រចាំឆ្នាំលើកដំបូង ដែលនឹងត្រូវផ្ដល់ឱ្យចាប់តាំងពីការព្យួរសម្បទានកាប់ព្រៃ បានផ្ដល់ឱ្យនូវមូលដ្ឋានសម្រាប់ប្រតិបត្តិការកាប់ឈើខុសច្បាប់ ។



សម្បទានដីសេដ្ឋកិច្ចដែលកំពុងប្រើប្រាស់ជាលេស ដើម្បីឈូសសំអាតព្រៃឈើព្រៃឡង់ xxx?xxx ហិកតា ដោយក្រុមហ៊ុន HMH ខែ កញ្ញា ឆ្នាំ ២០០៦
(រូបតូច) កំពុងកែច្នៃឈើ

## ប្រអប់ទី ១ : ការផ្តល់ឱ្យសភាជាតិ

ការផ្តល់ឱ្យលើកដំបូងឱ្យមានលក្ខណៈប្រតិបត្តិការ គឺត្រូវបានរៀបរាប់ជាផ្លូវការថាជា "ការផ្តល់ឱ្យពិសេស ដើម្បីផ្គត់ផ្គង់ឈើឱ្យគណៈកម្មការសាងសង់សភាជាតិថ្មី"[២៩] ។ ប្រធានគណៈកម្មការនេះជាសមាជិកសភាមកពីគណបក្សប្រជាជន ជៀម យាប[៣០] បានសរសេរទៅកាន់ ចាន់ សារុន ក្នុងខែ ឧសភា ឆ្នាំ ២០០៤ ដើម្បីប្រាប់គាត់ថា អាគារសភាជាតិថ្មី នឹងត្រូវការឈើប្រណិតសម្រាប់គ្រឿងសង្ហារឹម និងឈើលេខមួយ និងលេខពីរសម្រាប់គោលបំណងដែលមិនបានបង្ហាញ[៣១] ។ឈើប្រណិតបានមកពីពូជឈើកម្រដែលត្រូវបានការពារដោយច្បាប់[២៩] ។ ក្នុងខែ មិនា ឆ្នាំ ២០០៥ ចាន់ សារុន បានណែនាំឱ្យរដ្ឋបាលព្រៃឈើ បង្កើតការផ្តល់ឱ្យសម្បទានឈើរបស់ក្រុមហ៊ុន Hero Taiwan ដែលបានលុបចោលក្នុងខេត្តរតនៈគីរី[២៩] ។ សេចក្តីសម្រេចនេះ ផ្ទុយនឹងអនុក្រឹត្យស្តីពីការគ្រប់គ្រងសម្បទានព្រៃឈើ ដែលចែងថាព្រៃឈើក្នុងសម្បទានឈើ ដែលបានលុបចោលមិនអាចត្រូវបានផ្តល់ឱ្យជាថ្មីដល់ក្រុមហ៊ុនមួយផ្សេងទៀតបានឡើយ ។

ការណែនាំរបស់ ចាន់ សារុន ដល់រដ្ឋបាលព្រៃឈើធ្វើឱ្យមានការប្រមូលផលឈើចំនួន ១០,៥៧៧ម$^{៣}$ ដើម្បីបង្កើតឈើអារចំនួន ៦៥០៩ម$^{៣}$ ។ ទោះយ៉ាងណាក៏ដោយ បន្ទាប់មកសន្និធិដែលរដ្ឋបាលព្រៃឈើបានធ្វើច្រើនជាងនេះ ហើយត្រូវបានស្នើសុំឱ្យកាប់រំលំឈើចំនួន ១៦,៧៤៧ម$^{៣}$ [៣២] ។ ផែនការទាំងនេះបានឱ្យដឹងថា ការសាងសង់សភាជាតិថ្មីរបស់ប្រទេសកម្ពុជា អាចនៅក្នុងចំណោមដែលត្រូវបានផ្តល់ឱ្យច្រើនជាងគេបំផុតក្នុងពិភពលោក ។ Global Witness មិនមានន្ទូវយថាប្រភេទសម្រាប់ប្រភេទសង្ហារឹម ដែលបានស្នើឡើងនោះទេ ។ ទោះយ៉ាងណាក៏ដោយ មានតម្លៃពិចារណាថាការកែច្នៃឈើ ១៦,៧៤៧ម$^{៣}$ ទៅជាបន្ទះឈើកម្រាស់ ២៥មម នៅអត្រាកែច្នៃដែលបានកំណត់ដោយ ចាន់ សារុន នឹងបង្កើតកន្លែងមួយដែលមានទំហំ ៤១ហា ឬគ្រប់គ្រាន់គ្របដណ្តប់លើទីលានវាយតេនីសចំនួន ១៥៨០ ។



ជៀម យាប ប្រធានគណៈកម្មការសាងសង់សភាជាតិថ្មី

ក្នុងឆ្នាំ២០០៥រដ្ឋាភិបាលបានផ្តល់លិខិតអនុញ្ញាតឱ្យកាប់ឈើ ក្នុងការផ្តល់ឱ្យក្រុមហ៊ុនដែលមានឈ្មោះថា Heng Brothers[៣៣] ។ យោងតាមចំណេះដឹងប្រសើរបំផុតរបស់ Global Witness ការផ្តល់ឱ្យលិខិតអនុញ្ញាតនេះ មិនបានធ្វើតាមដំណើរដេញថ្លៃជាចំហប្រភេទណាមួយនោះទេ[៣៤] ។ ក្រុមហ៊ុន Heng Brothers ពីមុនមានការពាក់ព័ន្ធការកាប់ឈើខុសច្បាប់នៅឧទ្យានជាតិបុទុមសាគរ ក្នុងខេត្តកោះកុង ក្នុងឆ្នាំ ២០០៤ ដោយមានដៃគូសម្ងាត់ជាមួយសាខាក្រុមហ៊ុន Asia Pulp and Paper របស់ឥណ្ឌូនេស៊ីដែលមានវិវាទ[៣៥] ។ សម្រាប់ការផ្តល់ពិសេសនេះ ក្រុមហ៊ុន Heng Brothers បានបង្កើតក្រុមការងារជាមួយក្រុមហ៊ុន Ly Chhuong Construction Company[៣៦] ដែលកំពុងសាងសង់សភាជាតិថ្មី និងត្រូវបានរាយការណ៍ថាកាន់កាប់ដោយកូនប្រសាររបស់លោក ជៀម យាប ។

ក្រុមហ៊ុន Heng Brothers បានចាប់ផ្តើមប្រតិបត្តិការក្នុងខែមេសា ឆ្នាំ ២០០៥ ហើយកំពុងតែកាប់ឈើនៅកណ្តាលផ្លូវផ្តល់ឱ្យរហូតដល់ឆ្នាំបន្ទាប់ទៀត[៣៨] ។ ក្នុងខែ កញ្ញា ឆ្នាំ ២០០៦, Global Witness បានទទួលសេចក្តីរាយការណ៍ពីប្រភពមួយ ដែលជិតស្និទ្ធក្រុមហ៊ុនថា ការកាប់ឈើនៅក្នុងការផ្តល់ឱ្យពិសេស មិនមែនឱ្យសភាជាតិតាមតម្រូវការនោះទេ តែជំនួសឱ្យដោយការកំពុងដឹកជញ្ជូនឆ្លងព្រំដែនសម្រាប់លក់ក្នុងប្រទេសវៀតណាម[៣៩] ។ ការទទួលខុសត្រូវនេះ ត្រូវបានបន្ថែមដោយការស៊ើបអង្កេតដាច់ដោយឡែកទៀតក្នុងខេត្តរតនៈគីរី ដោយបុគ្គលិករបស់អង្គការក្រៅរដ្ឋាភិបាល[៣២] ។

ក្នុងខែ សីហា ឆ្នាំ ២០០៦ លោក ជៀម យាប បានប្រកាសថា ការផ្តល់ឱ្យមកទល់ពេលនេះ ផលិតបានឈើត្រឹមតែ ២៥៧ម$^{៣}$ ប៉ុណ្ណោះ សម្រាប់ការសាងសង់សភាជាតិ[៤០] ។ Global-Witness បានសរសេរទៅកាន់គាត់ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ ដើម្បីស្នើសុំកំណែប្រែតួលេខនេះ តែមិនទាន់បានទទួលការឆ្លើយតបនៅឡើយទេ ។



សភាជាតិថ្មីរបស់ប្រទេសកម្ពុជា កំពុងសាងសង់ ខែ ធ្នូ ឆ្នាំ ២០០៦

*ការបង្ក្រាបសម្លេងរិះគន់*

ចាប់តាំងពីការបង្កើតរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនថ្មីមួយក្នុងខែ មិថុនា ឆ្នាំ ២០០៤ មានចំនួនវាយប្រហារហិង្សាជាច្រើនទៅលើអ្នកភូមិ មន្ត្រីថ្នាក់ទាប និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ដែលចូលរួមក្នុងការប្រយុទ្ធប្រឆាំងបទល្មើសព្រៃឈើ ។ ទាំងនេះរួមមានយ៉ាងហោចណាស់ ការសម្លាប់ចំនួនបី និងការសម្លាប់ដោយប៉ុនប៉ងជាមុនចំនួនពីរ ។




ស្របពេលជាមួយគ្នានេះដែរ អាជ្ញាធរក៏បានព្យាយាមបង្ក្រាបសេចក្តីរាយការណ៍ពីការកាប់ឈើខុសច្បាប់ និងអំពើពុករលួយដែលពាក់ព័ន្ធ ។យុទ្ធសាស្ត្រអភិវឌ្ឍន៍មួយដែលបានរៀបចំឡើងដោយមន្ត្រីសម្រាប់កិច្ចប្រជុំក្រុមពិគ្រោះយោបល់ (CG) ម្ចាស់ជំនួយរដ្ឋាភិបាលខែ ធ្នូ ឆ្នាំ ២០០៤ បានប្រកាសថា "រាជរដ្ឋាភិបាលស្វាគមន៍ការធ្វើការក្នុងប្រទេសកម្ពុជារបស់ Global Witness អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ និងអង្គការសង្គមស៊ីវិល ដែលពាក់ព័ន្ធជាមួយនឹងការអនុវត្តច្បាប់ព្រៃឈើ" [៤១] ។ ទោះយ៉ាងណាក៏ដោយ ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៥ មន្ត្រីគយបានរឹបអូសរបាយការណ៍ *ទទួលយកការកាត់* របស់ Global Witness ចំនួន ២,០០០ច្បាប់ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងនៅខែបន្ទាប់មក ទីស្តីការគណៈរដ្ឋមន្ត្រីបានប្រកាសថា ខ្លួនកំពុងស៊ើបអង្កេតសកម្មភាពរបស់ Global Witness ក្នុងប្រទេសកម្ពុជា ។ ក្នុងខែ កក្កដា ទាហាន និងប៉ូលីស បានផ្តល់ការគម្រាមកំហែងដល់បុគ្គលិកជនជាតិខ្មែររបស់អង្គការមួយចំនួន ហើយរដ្ឋាភិបាលបានហាមប្រាមបុគ្គលិកអន្តរជាតិប្រាំនាក់មិនឱ្យចូលប្រទេស ។ ការបង្កើតទាំងនេះ ស្របជាមួយនឹង Global Witness កំពុងស៊ើបអង្កេតការកាប់ឈើខុសច្បាប់ដោយសាច់ញាតិរបស់ ហ៊ុន សែន និងកងឯកភាពយោធាកងពលតូចលេខ ៧០ ដ៏មានឥទ្ធិពល ។

ក្នុងទិដ្ឋភាពនៃការបង្កឱ្យមានស្ថានភាពសន្តិសុខ Global Witness បានបិទការិយាល័យក្នុងក្រុងភ្នំពេញរបស់ខ្លួនក្នុងខែ កញ្ញា ឆ្នាំ ២០០៥ ។ នាខែដដែលនោះដែរ ហ៊ុន សែន បានប្រកាសថា អង្គការនេះត្រូវបាន "បញ្ចប់" ហើយ ។[៤២] ក្នុងឆ្នាំ ២០០៦ បុគ្គលិកមានមូលដ្ឋាននៅទីក្រុងឡុងដ៍របស់ Global Witness បានបញ្ចប់ការស៊ើបអង្កេត ដែលបានចាប់ផ្តើមដោយការិយាល័យនៅទីក្រុងភ្នំពេញកាលពីឆ្នាំមុន ។ លទ្ធផលបង្កើតឱ្យមានមូលដ្ឋាននៃរបាយការណ៍នេះ ។




ប៉ូលីសកុបកម្មរឹបអូសខ្លែងនៅក្នុងបាតុកម្មអហិង្សា អំពាវនាវឱ្យមានសេរីភាពបញ្ចេញមតិកាន់តែទូលំទូលាយ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ។
ខ្លែងត្រូវបានយកទៅ ដើម្បីចៀសវាងការរំខានដល់ការធ្វើដំណើរតាមអាកាស

## ប្រអប់ទី ២ : ការវាស់វែងគម្របព្រៃឈើ និងការបំផ្លិចបំផ្លាញព្រៃឈើក្នុងប្រទេសកម្ពុជា

ការប៉ាន់ស្មានពីគម្របព្រៃឈើនិងអត្រាបំផ្លិចបំផ្លាញព្រៃឈើរបស់ប្រទេសកម្ពុជា គឺជាបញ្ហាវិវាទមួយ ។ ការអង្កេតស្រាវជ្រាវដោយជោគជ័យពីគម្របព្រៃឈើរបស់ប្រទេសកម្ពុជា ទោះជាធ្លាប់មានក៏ដោយ កម្របានប្រើប្រាស់វិធីសាស្ត្រដូចគ្នាពីរដងណាស់ ដោយហេតុនេះ រឹតបន្តឹងព្រំដែនសម្រាប់ការប្រៀបធៀបឆ្លង និងការវាស់វែងបានត្រឹមត្រូវនូវការបាត់បង់ព្រៃឈើ ។ ជាងនេះទៅទៀត ការអង្កេតស្រាវជ្រាវគម្របព្រៃឈើនាពេលថ្មីៗនេះ បានពឹងផ្អែកលើការបញ្ជូនរូបភាពពីផ្កាយរណប ដែលមានការពិនិត្យបញ្ជាក់តិចតួច ឬគ្មានកម្រិតមូលដ្ឋាន ។ ការអង្កេតស្រាវជ្រាវនាពេលថ្មីៗទាំងនេះ ផ្តល់ត្រឹមតែការយល់ដឹងមានកំណត់ទៅក្នុងគុណភាពព្រៃឈើក្នុងផ្នែកជីវចម្រុះ ឬចំនួនឈើដែលមានប៉ុណ្ណោះ[៤៣] ។

ការអង្កេតស្រាវជ្រាវគម្របព្រៃឈើថ្នាក់ជាតិលើកចុងក្រោយបំផុតរបស់ប្រទេសកម្ពុជា ត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០០៣ ដោយរដ្ឋបាលព្រៃឈើ និងត្រូវបានផ្តល់មូលនិធិដោយកម្ចីពីធនាគារពិភពលោក ។ លទ្ធផលចម្បងរបស់ការអង្កេតស្រាវជ្រាវ - ថាគម្របព្រៃឈើបានកើនឡើង - បានរៀបចំប្រឆាំងភស្តុតាងដែលប្រមូលដោយអង្គការក្រៅរដ្ឋាភិបាល ហើយជាច្រើនឆ្នាំកន្លងមកទៀត ការកាប់ឈើខុសច្បាប់ បានបណ្តាលឱ្យមានការធ្លាក់ចុះគម្របព្រៃឈើ និងគុណភាពព្រៃឈើក្នុងប្រទេសកម្ពុជា ។

Global Witness បានសម្ភាសន៍ទីប្រឹក្សាម្នាក់ ដែលធ្វើការនៅក្នុងការសិក្សាឆ្នាំ ២០០៣ និងបានស្នើឱ្យគាត់ពន្យល់ពីរបៀបដែលការអង្កេតស្រាវជ្រាវគូសចំណាំថា ជាតំបន់គ្របដណ្តប់ដោយព្រៃឈើពេញ ដែលការអង្កេតពីមុន (១៩៩៧) បានគូសចំណាំថាមិនមានព្រៃឈើ ។ ជាការឆ្លើយតប ទីប្រឹក្សានេះបាននិយាយថានេះបានបង្ហាញពីអសមត្ថភាពរបស់ការអង្កេតស្រាវជ្រាវគម្របព្រៃឈើឆ្នាំ ២០០៣ ក្នុងការចែកឱ្យដាច់ពីគ្នាឱ្យបានគ្រប់គ្រាន់រវាងព្រៃឈើ និងឫស្សី ។[៤៤]

ទោះបីជាការសង្ស័យកាន់តែខ្លាំងពីភាពគួរឱ្យជឿជាក់លើការអង្កេតស្រាវជ្រាវគម្របព្រៃឈើឆ្នាំ ២០០៣ មន្ត្រីបានចាប់យកលទ្ធផលរបស់ការអង្កេតស្រាវជ្រាវ ជាភស្តុតាងនៃការកាន់កាប់អចលនទ្រព្យព្រៃឈើដ៏វៃឆ្លាតរបស់ពួកគេ ។ ដោយនិយាយមុនការបោះឆ្នោតថ្នាក់ជាតិមួយថ្ងៃ នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថា :

"ជាសមិទ្ធិផលដ៏ចម្បងមួយ ដែលគម្របព្រៃឈើរបស់ប្រទេសកម្ពុជា បានកើនឡើងពី ៥៨.៦% (១០,៦៣៨,២០៩ ហិកតា) ក្នុងឆ្នាំ ១៩៩៧ ទៅ ៦១.១៤% (១១,១០៤,២៨៥ ហិកតា) ក្នុងឆ្នាំ ២០០២ ។ នេះ គឺជាសមិទ្ធិផលដ៏សំខាន់មួយនៃរាជរដ្ឋាភិបាលអណត្តិទីពីរ" ។[៤៥]

ទោះយ៉ាងណាក៏ដោយ ការវាយតម្លៃពីគម្របព្រៃឈើសកលរបស់អង្គការស្បៀងអាហារ និងកសិកម្មនាពេលថ្មីៗបំផុតនេះ ផ្តល់ឱ្យនូវរូបភាពខុសគ្នាយ៉ាងខ្លាំង ។ លទ្ធផលរបស់ការវាយតម្លៃបង្ហាញថា ប្រទេសកម្ពុជាបាត់បង់ព្រៃត្រូពិចធំជាងគេរបសខ្លួនចំនួន ២៩% ក្នុងរវាងឆ្នាំ ២០០០ និង ២០០៥ ។[៤៦] ស្របពេលដែលការប៉ាន់ស្មាននេះ ប្រហែលជាអាចខ្ពស់ពេក ក៏អាចមានការសង្ស័យបន្តិចបន្តួចថាការបំផ្លិចបំផ្លាញព្រៃឈើក្នុងប្រទេសកម្ពុជា កំពុងបន្តនៅក្នុងអត្រាប្រកាសអាសន្នមួយ ។



គ្មានចំនងជើងជាខ្មែរទេ

## ៣. ម្ចាស់ជំនួយអន្តរជាតិរបស់កម្ពុជា - ផ្តល់ជំនួយដល់ប្រជាជនកម្ពុជា ឬសមគំនិតជាមួយរដ្ឋាភិបាល

Milan Kothari អ្នកទំនាក់ទំនងពិសេសសិទ្ធិផ្ទះសម្បែងរបស់អង្គការសហប្រជាជាតិ បាននិយាយក្នុងឆ្នាំ ២០០៥ ថា *"ឥឡូវនេះមាននូវភាពរំជើបរំជួលខ្លាំងមួយនៅទូទាំងប្រទេសដោយអ្នកមាន និងអ្នកមានអំណាចក្នុងប្រទេសកម្ពុជាទិញដី ។ ខ្ញុំគិតថា សហគមន៍ម្ចាស់ជំនួយ និងភ្នាក់ងារអង្គការសហប្រជាជាតិ ត្រូវតែនិយាយកុំលាក់លៀមឱ្យបានកាន់តែខ្លាំងឡើង ។ អ្វីដែលខ្ញុំស្វែងរកមិនឃើញមាននៅទីនេះ គឺអារម្មណ៍នៃការបំពានដែលគួរតែមាននៅទីនោះ"* ។[៤៧]

អស់រយៈពេលជាមួយទសវត្សរ៍មកហើយ ជារៀងរាល់ឆ្នាំ ម្ចាស់ជំនួយអន្តរជាតិបានផ្តល់ឱ្យប្រទេសកម្ពុជានូវជំនួយ ដែលស្មើនឹងពាក់កណ្តាលនៃថវិកាជាតិរបស់ខ្លួន ។ នាពេលបច្ចុប្បន្ន ចំនួនជំនួយអន្តរជាតិសរុបមានប្រមាណ $៦០០ លានក្នុងមួយឆ្នាំ ។ ទោះបីជាអានុភាពដែលចំនួននេះ ផ្តល់ឱ្យពួកគេក៏ដោយ កំណត់ត្រាតាមដានរបស់ម្ចាស់ជំនួយក្នុងការធានាថា ជំនួយរបស់ពួកគេបង្កើតឱ្យបានផលសម្រាប់ប្រជាជនកម្ពុជា មិនត្រូវបានចាប់អារម្មណ៍ឡើយ ។

ក្នុងចុងទសវត្សរ៍ឆ្នាំ ១៩៩០ ភ្ជាប់ជាមួយឥណទានរបស់ពួកគេ ម្ចាស់ជំនួយបានដាក់ការកាប់ឈើខុសច្បាប់និងកំណែទម្រង់ការគ្រប់គ្រងព្រៃឈើនៅចំណុចកំពូលនៃរបៀបវារៈក្នុងកិច្ចពិភាក្សារបស់ពួកគេជាមួយរដ្ឋាភិបាលកម្ពុជា ។ ក្នុងឆ្នាំ ១៩៩៦ មូលនិធិរូបិយវត្ថុអន្តរជាតិបានបង្អាកការផ្តល់មូលនិធិដល់ប្រទេសកម្ពុជា ដោយសារតែភាពមិនធម្មតាខ្លាំងក្នុងការគ្រប់គ្រងប្រាក់ចំណូលកាប់ឈើរបស់រដ្ឋាភិបាល ។ នេះជំរុញឱ្យវិធានការណ៍ម្ចាស់ជំនួយត្រូវបានរួមផ្គុំគ្នា ដែលបានមើលឃើញថា ធនាគារពិភពលោកធ្វើការចំណាយឥណទានកែតម្រូវរចនាសម្ព័ន្ធចំនួនUS$១៥លាន ទៅលើការអនុវត្តកំណែទម្រង់ការគ្រប់គ្រងព្រៃឈើ ។

ទោះយ៉ាងណាក៏ដោយ កម្លាំងដែលបង្កើតឡើងដោយសម្ពាធម្ចាស់ជំនួយ និងការចាត់វិធានការណ៍បំបាត់របស់រដ្ឋាភិបាលជាដំបូងប្រឆាំងនឹងអ្នកកាប់ឈើខុសច្បាប់ ដែលមិនផ្តល់ប្រយោជន៍ដល់នយោបាយ បានបាត់បង់បន្តិចម្តងៗ ។ ជាមួយនឹងការបដិសេធរបស់ខ្លួនក្នុងខែ មករា ឆ្នាំ ២០០៣ មិនឱ្យ Global Witness បន្តធ្វើការជាអ្នកត្រួតពិនិត្យឯករាជ្យ និងគម្រាមកំហែងកាត់ទោសអ្នកតំណាងក្នុងប្រទេសរបស់ខ្លួន រដ្ឋាភិបាលបានបង្ហាញសញ្ញាថា ខ្លួនបានរំកិលទៅឆ្ងាយតាមដែលមានបំណងចង់ទៅ ។ ម្ចាស់ជំនួយជាច្រើនបានដកថយពីវិស័យមួយ ដែលត្រូវបានដឹងជាបន្តបន្ទាប់ថាមានការពិបាកណាស់ ។

ភាពទន់ខ្សោយរបស់ម្ចាស់ជំនួយ មិនបានកំណត់ព្រំដែនវិស័យព្រៃឈើនោះទេហើយទោះយ៉ាងណាក៏ដោយ កំណត់ត្រាតាមដានរបស់ម្ចាស់ជំនួយពាក់ព័ន្ធនឹងភាពក្រីក្រនៅជនបទ មរណភាព និងអក្ខរភាពកុមារ គឺនៅតែជាចំណុចពីរប្រសើរបំផុតដដែល ។ ក្នុងការបង្កើតប្រជាធិបតេយ្យនីតិរដ្ឋ ការគោរពសិទ្ធិមនុស្ស និងអភិបាលកិច្ចល្អពិតប្រាកដ ដូចជាមានការជឿទុកចិត្តតិចទៅៗ ។ ជាលក្ខណៈឯកជនរដ្ឋមន្ត្រីនិយាយពីម្ចាស់ជំនួយថាជា "មនុស្សភ្លើ" ដែលនឹងបន្តចំណាយប្រាក់ឱ្យរដ្ឋាភិបាល ទោះបីជាប្រាក់ពីអ្នកជាប់ពន្ធរបស់ពួកគេ មិនមានភាពត្រឹមត្រូវប៉ុណ្ណាក៏ដោយ[៤៨] ។ ជាលក្ខណៈសាធារណៈ ពួកគេបង្ហាញជំនួយដែលរដ្ឋាភិបាលទទួលបានថា ជាសញ្ញានៃការទទួលយករបស់សហគមន៍អន្តរជាតិនូវសកម្មភាពរបស់ពួកគេ[៤៩] ។

ជាញឹកញាប់ ម្ចាស់ជំនួយកែតម្រូវការបរាជ័យរបស់ពួកគេឱ្យធ្វើការខ្លាំងឡើងសម្រាប់ផលប្រយោជន៍ប្រជាជនធម្មតា ដោយការចោទសួរថា ជំហររឹងប៉ឹងកាន់តែច្រើន នឹងរុញឱ្យ ហ៊ុន សែន ចូលទៅកណ្តាប់ដៃ ឬហោប៉ៅរបស់ប្រទេសចិន ។ ឥទ្ធិពលដែលមានការកើនឡើងរបស់ប្រទេសចិនក្នុងប្រទេសកម្ពុជា គឺមិនអាចបដិសេធបានឡើយ ។ ទោះយ៉ាងណាក៏ដោយ ការជជែកវែកញែកនេះ មើលរំលងពីការពិតដែលថាទោះបីជាដោយសារតែការអនុគ្រោះរបស់ខ្លួនក៏ដោយ ប្រទេស



កន្លែងអារឈើរបស់យោធានៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

ចិនមិនអាចផ្តល់ឱ្យរដ្ឋាភិបាលកម្ពុជា នូវលទ្ធភាពនៃការគោរពជាអន្តរជាតិដែលវាស្វែងរកនោះឡើយ ។ ការបន្តយកការទទួលស្គាល់ជាអន្តរជាតិជាបន្តបន្ទាប់របស់រដ្ឋាភិបាល អាចត្រូវបានមើលឃើញក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធានាអសនៈមួយនៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ទទួលបានការចូលទៅកាន់អង្គការពាណិជ្ជកម្មពិភពលោកចូលរួមជាមួយកងកម្លាំងរក្សាសន្តិភាពអង្គការសហប្រជា-ជាតិ និងចូលរួមក្នុង "សង្គ្រាមប្រឆាំងភេរវកម្ម" ដែលដឹកនាំដោយសហរដ្ឋអាមេរិក ។ ស្រដៀងគ្នាទៅនឹងការចង់ចុះហត្ថលេខាលើរាល់លក្ខណៈនៃអនុសញ្ញាអន្តរជាតិ ដែលជាទូទៅ ក្រោយមកចិនបរាជ័យក្នុងការអនុវត្ត ។ សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីស្តីពីការអនុវត្ត និងអភិបាលកិច្ចច្បាប់ព្រៃឈើអាស៊ីបូព៌ា ឆ្នាំ ២០០១ គឺគ្រាន់តែជាឧទាហរណ៍មួយប៉ុណ្ណោះ ។

ការពន្យល់កាន់តែគ្មានខ្លឹមសារ តែកាន់តែគួរឱ្យជឿខ្លាំងឡើងសម្រាប់ឥរិយាបថដេកផ្ងាររបស់ម្ចាស់ជំនួយ គឺជាការព្រងើយកន្តើយសាមញ្ញមួយ ។ ក្នុងព្រឹត្តិការណ៍អន្តរជាតិ ប្រទេសកម្ពុជាបានបាត់បង់តម្លៃភាពប្លែកថ្មីរបស់ខ្លួន ហើយអាទិភាពរបស់អ្នកបង្កើតគោល-នយោបាយមានយូរមកហើយ តាំងតែពីបានចេញដំណើរមកម្លេះ ។ អ្នកតំណាង ម្ចាស់ជំនួយ និងអ្នកការទូតយល់យ៉ាងសាមញ្ញថា ពួកគេនឹងមិនត្រូវបានផ្តល់ដោយទីស្នាក់ការធំរបស់ពួកគេចំពោះការបង្កើតឱ្យមានបញ្ហា និងដាក់ឱ្យប្រទេសកម្ពុជាត្រឡប់ទៅកាន់របៀបវារៈពោរពេញដោយគោលនយោបាយបរទេសបានវិញឡើយ ។ កាន់តែងាយស្រួលឱនក្បាលចុះ និងធ្វើឱ្យលុយហូរចុះឡើង ។

មិនត្រឹមតែអង្គការក្រៅរដ្ឋាភិបាលប៉ុណ្ណោះទេ ដែលត្រូវបានរំខានដោយការស្ទាក់ស្ទើររបស់ម្ចាស់ជំនួយ ក្នុងការខិតខំប្រឹងប្រែងដោយខ្លួនឯង ។ ក្នុងឆ្នាំ ២០០៦ តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា លោក Yash Ghai បាននិយាយថា :

"ប្រសិនបើជាការពិតដែលថា ភ្នាក់ងារម្ចាស់ជំនួយមិនបានយកចិត្តទុកដាក់ពីសិទ្ធិមនុស្ស ឬប្រជាធិបតេយ្យ តែគ្រាន់តែចង់បង្កើតទំនាក់ទំនងកក់ក្តៅជាមួយរដ្ឋាភិបាលនោះ ចំពោះខ្ញុំ ហាក់បីដូចជាថាពួកគេមិនត្រឹមតែបរាជ័យចំពោះប្រជាជនកម្ពុជាប៉ុណ្ណោះទេ តែថែមទាំងអ្នកជាប់ពន្ធក្នុងស្រុកផ្ទាល់របស់ពួកគេថែមទៀតផង ដែលអនុម័តជំនួយទាំងនេះ ក្នុងការរំពឹងទុកថា ប្រទេសទាំងនេះនឹងគឺជាអ្នកទទួលប្រយោជន៍" [៥០] ។



ហ៊ុន សែន ជួបគណៈប្រតិភូចិន ។
ម្ចាស់ជំនួយជាច្រើនលើកឡើងថា ប្រទេសចិនកំពុងបង្កើនដោយការបិទភ្នែកចំពោះការិយាល័យបែបលួចប្លន់ដោយរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា

# ជំពូក II : ការរក្សាក្នុងគ្រួសារ

## ១. ការណែនាំទៅកាន់ក្រុមកាប់ឈើលេខមួយរបស់ប្រទេសកម្ពុជា

ជំពូកនេះ ពិនិត្យមើលពីអាជីពរបស់ក្រុមអភិជនឈើ ដែលទាំងអស់គ្នានេះ បង្កើតជាក្រុមកាប់ឈើដ៏មានអំណាចបំផុតរបស់ប្រទេសកម្ពុជា ។ ដោយអួតក្អេងក្អាងពីទំនាក់ទំនងគ្រួសារជាមួយនាយករដ្ឋមន្ត្រី ហ៊ុន សែន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក ចាន់ សារុន និងប្រធានរដ្ឋបាលព្រៃឈើ លោក ទី សុគន្ធ អាជីពរបស់ពួកគេ បង្ហាញពីរបៀបដែលអ្នកដឹកនាំយោបាយរបស់ប្រទេស បានធ្វើការគម្រាមកំហែងដោយជោគជ័យលើកំណែទម្រង់ការគ្រប់គ្រងព្រៃឈើ និងបន្តលួចប្លន់ទ្រព្យសម្បត្តិសាធារណៈដ៏មានតម្លៃ ។ មានភស្តុតាងជាច្រើនដែលថា សកម្មភាពរបស់ក្រុមនេះ មានវិសាលភាពក្រៅពីការកាប់ឈើខុសច្បាប់ទៅទៀត រហូតដល់ឡោមព័ទ្ធចាប់ជំរិត និងសម្លាប់ដោយគ្រោងទុក ។ ជាងនេះទៅទៀត មានការបញ្ជាក់ដ៏ច្បាស់លាស់ថា អំពើពុករលួយ និងញាតិនិយមនៅកម្រិតខ្ពស់បំផុត ពន្យល់បង្ហាញពីភាពគ្មានទោសពៃរ៍ ដែលសមាជិករបស់ខ្លួនបានអនុវត្តរយៈពេលស្ទើរតែមួយទសវត្សរ៍មកហើយនោះ ។

ស្របពេលដែលក្រុមនេះ បានអនុវត្តដោយស្ថិតក្រោមផ្លាកយីហោផ្សេងៗនាពេលថ្មីៗបំផុតនេះ "ក្រុមហ៊ុន Seng Keang Import Export Company Ltd." ទ្រង់ទ្រាយសាធារណៈរបស់ខ្លួនកំពុងពិចារណាទាបទៅលើផលប៉ះពាល់ បំផ្លិចបំផ្លាញដ៏ធំមហិមា ដែលខ្លួនបានធ្វើទៅលើព្រៃឈើរបស់ប្រទេស ។

### ១.១ ឌី ចូច ក៏ត្រូវបានស្គាល់ថាជា ហ៊ុន ចូច ផងដែរ

ឌី ចូច ត្រូវបានស្គាល់ជាងថាជា ហ៊ុន ចូច គឺជាបងជីដូនមួយបង្អស់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ ឌី ចូច បានធ្វើអាជីវកម្មជាច្រើនជាមួយ ហ៊ុន តូ[៥១] ជាក្មួយប្រុសរបស់នាយករដ្ឋមន្ត្រី ដែលប្រភពដ៏ល្អមួយបានឱ្យឈ្មោះថា ជាអ្នកជួញដូរថ្នាំញៀនដ៏ធំមួយ[៥២] ។ដៃគូអាជីវកម្មដំបូងរបស់ឌីចូចមួយផ្សេងទៀត



ឌី ចូច សមាជិកក្រុមកាប់ឈើនៅឯជំរុំកាប់ឈើ ពាក់ស្នា របស់ក្រុមហ៊ុន Mieng Ly Heng ឆ្នាំ ២០០១



រថយន្ត Hummers របស់ ហ៊ុន តូ ដៃគូ ឌី ចូច

គឺមេបញ្ជាការកងយោធពលខេមរភូមិន្ទដ៏ទុរយស សាត សឿន[៥៣] ។ អស់រយៈពេលមួយទសវត្សរ៍កន្លងមក សាត សឿន បានប្រឈមនឹងការចោទប្រកាន់ពាក់ព័ន្ធការសម្លាប់ផ្សេងៗគ្នាចំនួនបី ពីរជាការសម្លាប់ដោយបានគ្រោងទុក និងមួយជាការរំលោភបំពានរូបរាងកាយ[៥៤] ។ ដោយយោងតាមអ្នករស់នៅខេត្តកំពង់ចាមបានឱ្យដឹងថា ការបណ្តាក់ទុនពីមុនរបស់ ឌី ចូច, ហ៊ុន តូ និង សាត សឿន ផ្តោតទៅលើការរត់ពន្ធគ្រឿងញៀន និងដើមឈើកៅស៊ូឆ្លងកាត់ព្រំដែនទៅប្រទេសវៀតណាម[៥៥] ។



សាត សឿន ដៃគូ ឌី ចូច

ឌី ចូច និងភរិយាមុនរបស់គាត់ សេងគាង បានបន្តគ្រប់គ្រងប្រតិបត្តិការកាប់ឈើសម្រាប់សម្បទានិកព្រៃឈើជាច្រើនទៀត រួមមាន ក្រុមហ៊ុន Kingwood Industry ដែលសកម្មភាពរបស់ក្រុមហ៊ុនត្រូវបានរៀបរាប់លំអិតពេលក្រោយក្នុងជំពូកនេះ ក្រុមហ៊ុន Cambodia Cherndar Plywood និងក្រុមហ៊ុន Mieng Ly Heng ។ Global Witness បានកត់ត្រាសកម្មភាពខុសច្បាប់ដោយសម្បទានិកទាំងបីនេះអស់រយៈពេលជាច្រើនឆ្នាំ[៥៦] ។ ទោះបីជាមានកម្មសិទ្ធិជាជនជាតិតៃវ៉ាន់ដែលបានតែងតាំងរបស់ខ្លួនក៏ដោយ ក្រុមហ៊ុន Cambodia Cherndar Plywood គឺសំដៅទៅលើអាជីវកម្មឈើក្នុងឋានៈជា "ក្រុមហ៊ុនរបស់ហ៊ុនចូច" ឬ "ក្រុមហ៊ុនរបស់សេងគាង"[៥៧] ។ ទោះយ៉ាងណាក៏ដោយ សញ្ញាណពិតប្រាកដនៃទំនាក់ទំនងរបស់អ្នកទាំងពីរជាមួយក្រុមហ៊ុន Cambodia Cherndar Plywood បានបង្ហាញនូវការពិបាកក្នុងការបង្កើតឡើង ។

ទំនាក់ទំនងរបស់ ឌី ចូច និង សេង គាង ជាមួយក្រុមហ៊ុន Mieng Ly Heng គឺច្បាស់ណាស់ស្ទើគ្នា ហើយ ឌី ចូច ហាក់បីដូចជាស្ទាក់ស្ទើរបង្ហាញពីទំនាក់ទំនងរបស់គាត់ជាមួយក្រុមហ៊ុននេះ[៥៨] ។ក្នុងអំឡុងពេលទៅកាន់ជំរុំកាប់ឈើរបស់ក្រុមហ៊ុន Mieng Ly Heng នៅពាក់ស្នា ក្នុងខេត្តកំពង់ធំ ឆ្នាំ ២០០១ បុគ្គលិករបស់ Global Witness បានជួបជាមួយមនុស្សប្រុសម្នាក់ ដែលបានណែនាំខ្លួនគាត់ថាជា "លី សេង"

ប្រធានសន្តិសុខរបស់ក្រុមហ៊ុន ។ ក្នុងឋានៈជាអ្នកគ្រប់គ្រងសន្តិសុខ នៅពេលដែលត្រូវបានសួរថា តើគាត់អាចលៃលកទិញនាឡិកាដាំគុជ ម៉ាក់រ៉ូឡិច បំពាក់ដោយពេជ្រ មាសសុទ្ធ ដែលគាត់កំពុងពាក់បាន ដោយរបៀបណា "លី សេង" បានពន្យល់ថា គាត់ត្រូវបានផ្តល់ឱ្យដោយថៅកែរបស់គាត់ ក្នុងការទទួលស្គាល់នូវការបម្រើការងាររបស់គាត់ចំពោះក្រុមហ៊ុន ។ Global Witness បានថតរូប "លី សេង" ដែលនាពេលក្រោយមកត្រូវបានស្គាល់ថាជា ឌី ចូច ដោយមនុស្សពីរនាក់ដែលស្គាល់គាត់ [៥៩] ។

ទោះយ៉ាងណាក៏ដោយ ក្នុងមជ្ឈដ្ឋានសង្គម ឌី ចូច គ្មានភាពលាក់លៀម ហើយណែនាំខ្លួនគាត់ថាជាឧកញ៉ា ។ ឧកញ៉ា ដែលមានន័យស្រដៀងគ្នាទៅនឹង "លោក" គឺជាឋានៈគួរឱ្យគោរពមួយដែលប្រគល់ឱ្យអាជីវករដែលបានបរិច្ចាគយ៉ាងហោចណាស់ US$១00,000 ដល់រដ្ឋ[៦០] ។ ឌី ចូច ត្រូវបានដឹងថា គម្រាមកំហែងដោយកាំភ្លើងទៅលើនរណា ដែលបដិសេធហៅគាត់ដោយប្រើឋានៈនេះ[៦១] ។

## ១.២ សេង គាង

ស្របពេលដែល "ហ៊ុន ចូច" បញ្ហាឱ្យមានការទទួលស្គាល់ឈ្មោះកាន់តែខ្លាំង ឥទ្ធិពលរបស់ សេង គាង ក្នុងអាជីវកម្មឈើ ហាក់បីដូចជាស្មើ ឬលើសរបស់អតីតស្វាមីរបស់នាងទៀត ។ ដូច ឌី ចូច ដែរ សេង គាង បានធ្វើជាអ្នកម៉ៅការបន្តផ្គត់ផ្គង់ឈើដល់ក្រុមហ៊ុន Cambodian Cherndar Plywood ក្រុមហ៊ុន Mieng Ly Heng និងក្រុមហ៊ុន Kingwood Industry[៦២] ។ គាត់ក៏ដើរតួនាទីស្រដៀងគ្នាសម្រាប់សម្បទានិកឈើក្រុមហ៊ុន Everbright CIG Wood ដែលគ្រប់គ្រងដោយរដ្ឋរបស់ប្រទេសចិនផងដែរ[៦៣] ។ ជាងនេះទៅទៀត មន្ត្រីរដ្ឋបាលព្រៃឈើបានដាក់ឈ្មោះ សេង គាង ថាជាម្ចាស់ហ៊ុនធំក្នុងក្រុមហ៊ុន Mieng Ly Heng ទៀតផង[៦៤] ។



**លាង វួចឆេង ភរិយារបស់បងប្រុសនាយករដ្ឋមន្ត្រី, ម្នាក់ក្នុងចំណោមដៃគូអាជីវកម្ម ដែលមានទំនាក់ទំនងអាជីវកម្មយ៉ាងល្អរបស់ សេង គាង**

សេង គាង មានមិត្តភក្តិជាច្រើនដែលមានតំណែងខ្ពស់ ។ គាត់ជាមិត្តភក្តិរបស់ ប៊ុន រ៉ានី ភរិយា ហ៊ុន សែន[៦៥] និងបង្ហាញខ្លួនម្តងម្កាលជាមួយគាត់នៅតាមការផ្សព្វផ្សាយព្រឹត្តិការណ៍សាធារណៈលើទូរទស្សន៍ជាតិ ។ គាត់ក៏ជិតស្និទ្ធជាមួយ លាង វួចឆេង[៦៦] ភរិយាបងរបស់នាយករដ្ឋមន្ត្រីនិងអភិបាលខេត្តកំពង់ចាម ហ៊ុន ណេង ផងដែរ[៦១] ។ Global Witness បានទទួលរបាយការណ៍ពីប្រភពដ៏ល្អមួយថា សេង គាង និង លាង វួចឆេង គ្រប់គ្រងការបណ្តាក់ទុនរកស៊ីទុច្ចរិតរកបានកម្រៃយ៉ាងច្រើនមួយក្នុងខេត្តកំពង់ចាម ដោយធ្វើជាដៃគូជាមួយភរិយារបស់មន្ត្រីខេត្តផ្សេងទៀតពីរនាក់ ។ សកម្មភាពទាំងនេះត្រូវបាននិយាយសំដៅបញ្ចូលការហូតពន្ធប្រាក់ការពារពីអ្នកប្រកបរត់ឡានឈ្នួលក្នុងក្រុងកំពង់ចាម ផងដែរ [៦១] ។

ឌី ចូច និង សេង គាង បានលែងលះគ្នាក្នុងឆ្នាំ ២00៥[៦៧] ។ ទោះយ៉ាងណាក៏ដោយ ដោយយោងតាមអ្នកនៅខាងក្នុងអាជីវកម្មឈើ បានឱ្យដឹងថា ពួកគេបន្តធ្វើអាជីវកម្មជាមួយគ្នាដដែល[៦៨] ។



សេង គាង (ឆ្វេង) សមាជិកក្រុមកាប់ឈើ និង ប៊ុន រ៉ានី ភរិយារបស់នាយករដ្ឋមន្ត្រី

**សម្ព័ន្ធភាព និងចំណងទាក់ទងរបស់ក្រុមហ៊ុនកាប់ព្រៃឈើកម្ពុជា**




## ១.៣ យុន ថុង

យុន ថុង មានការរាប់អានទ្វេដងជាបងថ្លៃរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក ចាន់ សារុន និងឪពុកក្មេករបស់ប្រធានរដ្ឋបាលព្រៃឈើ លោក ទី សុគន្ធ[៦៩] ។ សៀវភៅបញ្ជីឈ្មោះលេខទូរស័ព្ទក្រុងភ្នំពេញពីមុន បានរាយរោងចក្រអារឈើមួយក្នុងចំណោមរោងចក្រអារឈើជាច្រើនរបស់ យុន ថុង ជាអាសយដ្ឋានស្នាក់នៅរបស់ទី សុគន្ធ[៧០] ។

ដូច សេង គាង និង ឌី ចូច ដែរ យុន ថុង គឺជាអ្នកម៉ៅការបន្តកាប់ឈើ និងបានធ្វើការជាមួយក្រុមហ៊ុន Kingwood Industry និង Everbright CIG Wood[៧១] ។ ក្នុងឆ្នាំ ២០០១ ក្នុងសមត្ថភាពរបស់ខ្លួនជាអ្នកត្រួតពិនិត្យព្រៃឈើដោយឯករាជ្យផ្លូវការ Global-Witness បានបង្ហាញប្រតិបត្តិការកាប់ឈើខុសច្បាប់ទ្រង់ទ្រាយធំមួយដោយក្រុមហ៊ុន Everbright នៅខាងក្រៅសម្បទានរបស់ខ្លួន ។ សមាជិកក្រុមរដ្ឋាភិបាល ដែលក្រោយមកបានស៊ើបអង្កេតករណីនោះបានបន្ទោសទំនាក់ទំនងរបស់ យុន ថុង ជាមួយ ទី សុគន្ធ ចំពោះអសមត្ថភាពរបស់ពួកគេក្នុងការរៀបចំការកាត់ទោសឱ្យបានជោគជ័យចំពោះក្រុមហ៊ុននេះ[៧២] ។

បន្ថែមពីលើការងាររបស់គាត់ជាមួយក្រុមហ៊ុន Kingwood និង Everbright យុន ថុង ត្រូវបានដឹងថា បានបង្កើតចំណូលបន្ថែមទៀតដោយការគម្រាមកំហែងយកប្រាក់ និងឈើពីពាណិជ្ជករឈើ ដែលជាគូប្រជែងតាមដងទន្លេមេគង្គ ។ ដោយយោងតាមចំណុចទាំងឡាយដែលគាត់បានកំណត់ទិសដៅយុនថុងនឹងអមតម្រូវការរបស់គាត់ជាមួយការគម្រាមកំហែងសំអាងលើ"វិធានការណ៍លុបបំបាត់"ដោយមន្ត្រីរុក្ខាប្រមាញ់ដែលអាចឆ្លើយបានចំពោះកូនប្រសាររបស់គាត់លោក ទីសុគន្ធ[៧៣] ។

ទោះយ៉ាងណាក៏ដោយ យុន ថុង ដែលជាឥស្សរជនទ្រង់ទ្រាយតូច ត្រូវបានរៀបរាប់ដោយ ឌី ចូច ថាជា "ឆ្អឹងខ្នង" ចំពោះអាជីវកម្មឈើរបស់គាត់ ហើយឈ្មោះរបស់គាត់មានឃើញនៅលើឯកសារជាច្រើនពាក់ព័ន្ធសកម្មភាពរបស់ក្រុមនេះ[៧៤] ។



យុន ថុង
ចូលចិត្តមានរូបភាពមិនច្បាស់លាស់



ចាន់ សារុន ប្អូនថ្លៃរបស់ យុន ថុង
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



ទី សុគន្ធ កូនប្រសាររបស់ យុន ថុង
អគ្គនាយករដ្ឋបាលព្រៃឈើ

## ២. Kingwood - ការបង្កើត និងការលុបចោលសម្បទានិកឈើ

ការផ្តល់ឱ្យរវាងពី ៣០ និង ៤០ សម្បទានឈើរបស់រដ្ឋាភិបាលកម្ពុជាក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ បង្កើតនូវដំណាក់កាលចំពោះអ្វីមួយ ដែលការត្រួតពិនិត្យរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានរៀបរាប់ថាជា "ការបរាជ័យប្រព័ន្ធទាំងមូល"[៧៥] ។ដោយឡែកបានដាក់ភ្ជាប់ដោយចម្លល់នូវធនធានធម្មជាតិដ៏មានសារៈសំខាន់បំផុតរបស់ប្រទេសទៅក្នុងដៃរបស់ប្រភេទអ្នកធ្វើអាជីវកម្មមិនត្រឹមត្រូវបំផុត ដែលជាច្រើនក្នុងចំណោមនោះបានអនុវត្តដោយស្ថិតក្រោមការឧបត្ថម្ភរបស់គ្រួសារអ្នកកាន់អំណាចរបស់ប្រទេស ។ ជាការកត់សំគាល់អ្នកត្រួតត្រាព្រៃឈើរបស់ប្រទេសកម្ពុជាថ្មីទាំងនេះ គឺក្រុមហ៊ុន Kingwood Industry ដែលជាក្រុមហ៊ុនមួយបង្កើតឡើងក្នុងប្រទេសកម្ពុជា ដោយពាណិជ្ជករជនជាតិ តៃវ៉ាន់ សិង្ហបុរី និងឥណ្ឌូនេស៊ី ដែលបានទទួលសម្បទានចំនួន ៣០១,២០០ហិកតា ក្នុងឆ្នាំ ១៩៩៥ ដែលគ្របដណ្តប់លើផ្នែកជាច្រើននៃខេត្តក្រចេះ ស្ទឹងត្រែង និងមណ្ឌលគិរី[៧៦] ។ជារួមជាមួយនឹងទាំងអស់នេះ តែពីរក្នុងចំណោមសម្បទានិក ក្រុមហ៊ុន Kingwood មិនមានបទពិសោធន៍គ្រប់គ្រងព្រៃឈើនោះទេ ។ ដូចអ្នកផ្សេងទៀតជាច្រើនផងដែរ ក្រុមហ៊ុនបានបង្ហាញយ៉ាងឆាប់រហ័សនូវបំណងបំពានច្បាប់ ដើម្បីយកប្រាក់ចំណេញឱ្យបានឆាប់រហ័ស ។

ទិដ្ឋភាពជាឧទាហរណ៍មួយផ្សេងទៀត ពីប្រតិបត្តិការរបស់ក្រុមហ៊ុន Kingwood គឺការទំនាក់ទំនងរបស់ក្រុមហ៊ុន ជាមួយគ្រួសារដែលមានឥទ្ធិពលនយោបាយមួយ ។មុនពេលទទួលបានសម្បទានរបស់ខ្លួនក្រុមហ៊ុន Kingwood បានបង្កើតដៃគូជាស្រេចជាមួយ សុខ កែវ[៧៧] ជាប្អូនស្រីរបស់ ឃុន ថុង និងភរិយារបស់ ចាន់ សារុន បន្ទាប់មកប្រធាននាយកដ្ឋានរុក្ខាប្រមាញ់និងនេសាទ(MAFF) ។ក្នុងខែកញ្ញា ឆ្នាំ១៩៩៤ សុខ កែវ បានជួយក្រុមហ៊ុន Kingwood ឱ្យទទួលបានដីដែលមានទំហំ ២៥ហិកតា នៅតាមដងទន្លេមេគង្គ ក្នុងស្រុកមុខកំពូលរបស់ខេត្តកណ្តាល ចម្ងាយ ២១ គីឡូម៉ែត្រពីក្រុងភ្នំពេញ ។ ក្នុងអំឡុងពេលបួនថ្ងៃពីការទទួលបានប័ណ្ណកម្មសិទ្ធិសម្រាប់ដីដែលមានឈ្មោះរបស់គាត់ សុខ កែវ បានចុះហត្ថលេខាព្រមព្រៀងជាមួយនាយកគ្រប់គ្រងជនជាតិតៃវ៉ាន់របស់ក្រុមហ៊ុនKingwood ឈ្មោះ Lia Chun Hua ដើម្បីផ្តល់ការគ្រប់គ្រងតំបន់នេះដល់ក្រុមហ៊ុន ។ ឯកសារបញ្ជាក់ថា គាត់នឹងជួលដីឱ្យ Kingwood ដោយមិនគិតថ្លៃចំនួន ៧០ឆ្នាំ ស្របជាមួយនឹងក្រុមហ៊ុន Kingwood នឹងផ្តល់ឱ្យគាត់នូវកម្ចីដោយមិនមានការប្រាក់ចំនួន US$៤៣០,៥៨៤ ។ លក្ខខណ្ឌតែមួយគត់ ដែលបានភ្ជាប់ក្នុងការឱ្យខ្ចីនេះ គឺថាក្រុមហ៊ុន Kingwood ត្រូវបានអនុញ្ញាតឱ្យសាងសង់រោងចក្រមួយនៅលើតំបន់នោះ[៧៨] :




ហត្ថលេខាស្នាមមេដៃរបស់ សុខ កែវ ទៅលើការជួលដោយមិនបង់ថ្លៃឈ្នួលទៅឱ្យក្រុមហ៊ុន Kingwood

"ក្នុងករណីរដ្ឋាភិបាលកម្ពុជាមិនអនុញ្ញាតឱ្យ (ក្រុមហ៊ុន Kingwood) សាងសង់រោងចក្រកែច្នៃឈើនៅលើដីដែលបាននិយាយនេះ (សុខ កែវ) ត្រូវលក់ ផ្ទេរ ឬរៀបចំដីដែលបាននិយាយនេះក្នុងអំឡុងពេលមួយឆ្នាំ ។ កម្ចីដោយមានការបញ្ចាំចំនួន US$៤៣០,៥៨៤ នេះ នឹងត្រូវបង្វិលសងជូនដល់ (ក្រុមហ៊ុន Kingwood) ដោយគ្មានលក្ខខណ្ឌ[៧៨] ។"

កិច្ចសន្យានេះ មិននិយាយថា តើ សុខ កែវ មានបំណងទទួលយកតួនាទីសកម្មក្នុងការធានាថាក្រុមហ៊ុន Kingwood បានទទួលការអនុញ្ញាតសាងសង់រោងចក្រដែរ ឬអត់នោះទេ ទោះយ៉ាងណាក៏ដោយ បានផ្តល់ឱ្យគាត់នូវការលើកទឹកចិត្តយ៉ាងខ្លាំងសម្រាប់ការធ្វើដូច្នេះ ។ កិច្ចព្រមព្រៀងនេះ ក៏បានបង្កើតនូវជម្លោះ ដែលអាចមានរវាងទំនួលខុសត្រូវរបស់ លោក ចាន់ សារុន ក្នុងឋានៈជាអ្នកចេញច្បាប់ដោយមិនលំអៀងម្នាក់នៃវិស័យព្រៃឈើ និងផលប្រយោជន៍អាជីវកម្មរបស់ភរិយាគាត់ផងដែរ ។



សុខ កែវ (ឆ្វេង) និង ចាន់ សារុន ស្វាមីរបស់គាត់ ជួបព្រះមហាក្សត្រ នរោត្តម សីហមុនី (ស្តាំ) នៅទិវាកាកបាទក្រហមកម្ពុជា ខែ ឧសភា ឆ្នាំ ២០០៥

ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ Global Witness បានសរសេរជូនលោក ចាន់ សារុន ដើម្បីសួរគាត់ថា តើគាត់បានដឹងពីកិច្ចព្រមព្រៀងរបស់ភរិយាគាត់ជាមួយក្រុមហ៊ុន Kingwood ដែរ ឬអត់ និងថា តើគាត់បានជួយក្រុមហ៊ុនឱ្យទទួលបានលិខិតអនុញ្ញាតសាងសង់រោងចក្ររបស់ខ្លួនដែរ ឬអត់ ។ មកទល់នឹងរបាយការណ៍នេះយកទៅបោះពុម្ពផ្សាយ ចាន់ សារុន មិនបានឆ្លើយតបចំពោះលិខិតនេះទេ ។

បន្ទាប់ពីទទួលបានការអនុញ្ញាតឱ្យសាងសង់លើដីដែលបានជួលពី សុខ កែវ នាយករបស់ក្រុមហ៊ុន Kingwood បានយកប្រាក់កម្ចីដំបូងយ៉ាងហោចណាស់ US$១០ លាន ដើម្បីធ្វើហិរញ្ញប្បទានសាងសង់រោងចក្រក្តារបន្ទះ ។ កិច្ចព្រមព្រៀងកម្ចីឆ្នាំ ២០០១ រវាងក្រុមហ៊ុន និងធនាគារសាធារណៈកម្ពុជា បាននិយាយថា សុខ កែវ ជាម្ចាស់ទាំងលើបរិវេណរោងចក្រ និងគ្រឿងម៉ាស៊ីនដែលមានក្នុងបរិវេណនោះ[៧៩] ។ ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ Global Witness បានសរសេរទៅកាន់ សុខ-កែវ ដើម្បីស្នើគាត់ឱ្យពន្យល់ពីទំនាក់ទំនងរបស់គាត់ជាមួយក្រុមហ៊ុន Kingwood ហើយនិងនៅតែកំពុងរង់ចាំការឆ្លើយតបនៅឡើយ ។

## ២.១ ការកាប់ឈើខុសច្បាប់

ដោយយោងតាមអ្នកវិភាគអាជីវកម្ម រោងចក្រដែលក្រុមហ៊ុន Kingwood បានសាងសង់ឡើង អាចផលិតផលិតផលឈើសម្រេចចំនួន ៩៦,០០០ម៣ ក្នុងមួយឆ្នាំ ដោយមានសមត្ថភាពអនុវត្តចំនួន ៨៤,០០០ម៣ ក្នុងមួយឆ្នាំ[៨០] ។ ដើម្បីអនុវត្តតាមសមត្ថភាពអនុវត្តពេញលេញ និងមានប្រសិទ្ធិភាពពេញលេញ ហេតុនេះត្រូវបានតម្រូវឱ្យមានការផ្គត់ផ្គង់ឈើមូលប្រមាណ ១៦៨,០០០ម៣ ជារៀងរាល់ឆ្នាំ - ប្រហែលជាប្រាំដងឈើ ៣៥,០០០ម៣ ក្នុងមួយឆ្នាំ ដែលក្រុមហ៊ុន Kingwood ត្រូវបានអនុញ្ញាតឱ្យដោយស្របច្បាប់ឱ្យកាប់ក្នុងសម្បទានព្រៃឈើក្នុងទ្រង់ទ្រាយធំតែដោយស្តើងៗ[៨០] ។ ការដំណើរការលើសសមត្ថភាពគឺជាលក្ខណៈមួយនៃប្រព័ន្ធសម្បទានរបស់ប្រទេសកម្ពុជាទាំងមូល ។ សម្រាប់សម្បទានិក បានបង្កើតការលើកទឹកចិត្តយ៉ាងខ្លាំង ទាំងការកាប់ឈើខុសច្បាប់ ឬព្យាយាមទទួលបានឈើពីសម្បទានផ្សេងទៀត ។ ក្រុមហ៊ុន Kingwood បានជ្រើសរើសយកធ្វើទាំងពីរ ។



លិខិតអនុញ្ញាតប្រមូលឈើចាស់ៗដែលប្រើប្រាស់ និងចំពានដោយក្រុមហ៊ុន Kingwood

ក្នុងឆ្នាំ១៩៩៧ ក្រុមហ៊ុនបានកាប់ដើមឈើខុសច្បាប់ក្នុងសម្បទានក្រុមហ៊ុន Macro-Panin ក្បែរតំបន់របស់ខ្លួន ដោយយកលេសថា ក្រុមហ៊ុនកំពុងប្រមូល "ឈើចាស់ៗ" ចំនួន ៥០,០០០ម៣ [៨១] ។ មួយរយៈពេលដូចគ្នានេះ ក្រុមហ៊ុនបានជួលមេបញ្ជាការយោធាឱ្យកាប់ដើមឈើក្នុងតំបន់១០០គម២ ខាងក្រៅសម្បទានរបស់ខ្លួនហើយដឹកពួកត្រឡប់មកក្នុងព្រំដែនក្រុមហ៊ុន Kingwood ដើម្បីឆ្លងជាផលិតផលប្រតិបត្តិការប្រមូលផលផ្ទាល់របស់ក្រុមហ៊ុន[៨២] ។ ក្នុងអំឡុងរដូវក្តៅឆ្នាំ ១៩៩៧-១៩៩៨ ក្រុមហ៊ុន Kingwood ក៏បានធ្វើប្រតិបត្តិការប្រមូលផលដ៏ធំមួយក្នុងសម្បទានផ្ទាល់របស់ខ្លួន ទោះបីជាការពិតថាខ្លួនគ្មានលិខិតអនុញ្ញាតឱ្យកាប់ក៏ដោយ[៨២] ។ ជាងនេះទៅទៀត ការត្រួតពិនិត្យការអនុវត្តប្រតិបត្តិការរបស់សម្បទានិកឈើរបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ ២០០០ បានបង្ហាញថា ក្រុមហ៊ុនមិនបានអនុវត្តតាមការប្តេជ្ញាចិត្ត ដែលមានក្នុងកិច្ចសន្យារបស់ខ្លួនក្នុងការវិនិយោគចំនួន US$៧៦.៥លាន ក្នុងប្រទេសកម្ពុជា និងបង់សួយសារ និងប្រាក់កក់ចំនួន US$៣០០,០០០ ដល់រដ្ឋាភិបាល[៨៣] ។

ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីផ្គត់ផ្គង់រោងចក្ររបស់ខ្លួន ក្រុមហ៊ុន Kingwood បានចុះកិច្ចសន្យាជាមួយបងប្រុសរបស់ សុខ កែវ ឈ្មោះ ឃុន ថុង ជាមួយ សេង គាង ដើម្បីផ្គត់ផ្គង់ឈើ [៨៤] ។ ផលប្រយោជន៍ចំពោះក្រុមហ៊ុន Kingwood រួមមាន សមត្ថភាពរបស់ សេង គាង និង ឃុន ថុង ក្នុងការទទួលបានឈើពីសម្បទានផ្សេងទៀត ដែលពួកគេបានធ្វើជាអ្នកម៉ៅការបន្តដែលគួរកត់សំគាល់ គឺក្រុមហ៊ុន Cambodia Cherndar Plywood ។

## ២.២ បំណុលដែលមានបញ្ហា

ទោះបីជាមានសកម្មភាពផលិតកម្មច្រើនរបស់រោងចក្រខ្លួនក៏ដោយ ប្រតិបត្តិការរបស់ក្រុមហ៊ុនKingwood ត្រូវបានសរសេរគាំទ្រដោយការពង្រីកក្រុមកម្ចី ។ ប្រភពមួយស្និទ្ធិនឹងក្រុមហ៊ុនបានបញ្ជាក់ថាក្រុមហ៊ុនត្រូវការខ្ចី ដោយសារតែនាយកក្រុមហ៊ុនកំពុងតែបង្កើនចំណូលលក់តាមរយៈក្រុមហ៊ុនដៃគូនៅក្នុងប្រទេស ឥណ្ឌូនេស៊ី សិង្ហបុរី និងតៃវ៉ាន់ ។ Global Witness បានសរសេរទៅកាន់នាយករបស់ក្រុមហ៊ុនKingwood ក្នុងខែ កុម្ភៈ ឆ្នាំ២០០៧ ដើម្បីស្នើឱ្យពួកគេផ្តល់យោបល់លើការអះអាងនេះ ប៉ុន្តែមិនទាន់បានទទួលការឆ្លើយតបនៅឡើយ ។ ទោះបីជាការចោទប្រកាន់នេះ ពិត ឬមិនពិតក៏ដោយគ្មានការសង្ស័យឡើយថាស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនទៀងទាត់ខ្លាំងឡើងៗ ។

ក្នុងអំឡុងដំណាក់កាលចាប់ផ្តើមរបស់ខ្លួនក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ ក្រុមហ៊ុន Kingwood បានទទួលកម្ចីបី ដែលមានទឹកប្រាក់សរុប US$៩.៤លាន ពីធនាគារ Maybank[៨៦] របស់ប្រទេសម៉ាឡេស៊ី[៨០] ។ កម្ចីទាំងនេះយកតាមទម្រង់ប័ណ្ណបំណុល ដោយសារក្រុមហ៊ុន Kingwood បានអះអាងថា ខ្លួនមិនមានកាន់កាប់ដីណាមួយ ហើយខ្លួនមិនអាចបញ្ចាំជាការធានាភ័យឡើយ ។ លក្ខខណ្ឌចងភ្ជាប់នៃកិច្ចព្រមព្រៀងប័ណ្ណបំណុល បានហាមប្រាមក្រុមហ៊ុន Kingwood ពីការផ្ទេរការត្រួតពិនិត្យ

ឬការខ្ចីពីភាគីណាមួយផ្សេងទៀត[៨៧] ។ ទោះបីជាបែបនេះក៏ដោយ ក្រុមហ៊ុនបានបន្តខ្ចីពីធនាគារផ្សេងទៀតបីនៅក្នុងប្រទេសកម្ពុជា[៨៥] ។ ឧទាហរណ៍ក្នុងខែ មិថុនា ឆ្នាំ ២០០១ សុខ កែវ ភរិយារបស់ ចាន់ សារុន បានខ្ចីពីធនាគារកម្ពុជាសាធារណៈជំនួសឱ្យក្រុមហ៊ុន Kingwood ដោយបញ្ចាំទីតាំងរោងចក្រ និងគ្រឿងម៉ាស៊ីន[៧៩] ។ កិច្ចព្រមព្រៀងបញ្ចាំ ត្រូវបានចុះហត្ថលេខា មិនត្រឹមតែដោយ សុខ កែវ និងអ្នកតំណាងរបស់ធនាគារកម្ពុជាសាធារណៈប៉ុណ្ណោះទេថែមទាំងដោយប្រធានសមាគមមេធាវីកម្ពុជា លោក គី តិច ទៀតផង[៧៩] ។ ប្រភពមួយជិតស្និទ្ធនឹងក្រុមហ៊ុន Kingwood បញ្ជាក់ថា ធនាគារកម្ពុជាសាធារណៈ បានផ្តល់កម្ចីដល់ក្រុមហ៊ុនសរុបប្រមាណ US$៣លាន[៨៥] ។



រោងចក្រក្តារបន្ទះរបស់ក្រុមហ៊ុន Kingwood ចម្ងាយ ២១ គីឡូម៉ែត្រ ភាគខាងជើងក្រុងភ្នំពេញ

## ប្រអប់ ៣ : គី តិច

ប្រធានសមាគមមេធាវីកម្ពុជា គី តិច ត្រូវបានរៀបរាប់ដោយប្រភពដ៏ល្អជាច្រើនថា ជាទីប្រឹក្សារបស់ ប៊ុន រ៉ានី ភរិយារបស់ ហ៊ុន សែន ហើយគាត់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអ្នកធ្វើអាជីវកម្មឈើរបស់ប្រទេសកម្ពុជាដ៏មានអំណាចជាច្រើន[៨៨] ។ ក្នុងដើមឆ្នាំ ២០០១ គាត់បានតំណាងឱ្យសម្បទានិកឈើក្រុមហ៊ុន Everbright ក្នុងការចាត់វិធានការណ៍ច្បាប់មិនបានជោគជ័យប្រឆាំងបុគ្គលិកមកពី Global Witness ចំពោះការចូលតំបន់ហាមឃាត់ដែលបានចោទប្រកាន់ ។ នៅពេលនោះ Global Witness គឺជាអ្នកត្រួតពិនិត្យឯករាជ្យផ្លូវការរបស់រដ្ឋាភិបាលប្រឹងប្រែងដោះស្រាយបទល្មើសព្រៃឈើ ហើយការចូលតំបន់ហាមឃាត់ដែលបានចោទប្រកាន់ គឺជាការធ្វើអធិការកិច្ចផ្លូវការ ដែលរៀបចំឡើងដោយ



អាគារប្រើប្រាស់ដោយតុលាការចម្រុះអង្គការសហប្រជាជាតិ - រដ្ឋាភិបាលបង្កើតឡើងដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ដែលទទួលខុសត្រូវចំពោះការស្លាប់ប្រជាជនខ្មែរ ប្រមាណពីរលាននាក់ក្នុងរវាង ឆ្នាំ ១៩៧៥ និង ១៩៧៩ ។ ប្រជាជនខ្មែរជាច្រើនកំពុងសង្ឃឹមថា តុលាការនេះ នឹងជួយបង្កើនបទដ្ឋានក្នុងវិស័យយុត្តិធម៌របស់ប្រទេស ។

ទីស្តីការគណៈរដ្ឋមន្ត្រីទៅលើរោងចក្រក្តារបន្ទះរបស់ក្រុមហ៊ុន Everbright ។ ក្នុងអំឡុងពេលអធិការកិច្ចនេះ Global Witness បានលាតត្រដាងភស្តុតាងពីការលួចស្ទួយសារទ្រង់ទ្រាយធំដោយក្រុមហ៊ុន ។

ដូចក្រុមហ៊ុន Kingwood ដែរ អ្នកម៉ៅការធំរបស់ក្រុមហ៊ុន Everbright រួមមាន សេង គាង និង ឃុន ថុង ។ ដូចបានរៀបរាប់នៅកន្លែងផ្សេងទៀតក្នុងជំពូកនេះ គី តិច បានតំណាងឱ្យ សេង គាង ក្នុងការដោះស្រាយជាមួយនាយករបស់ក្រុមហ៊ុន Kingwood និងតុលាការកម្ពុជា ។

គីតិចបានទាក់ទាញចំណាប់អារម្មណ៍ប្រព័ន្ធផ្សព្វផ្សាយនាពេលថ្មីៗនេះ ចំពោះការរិះគន់ជាសម្លេងរបស់គាត់លើសំណើអនុញ្ញាតឱ្យមេធាវីបរទេសធ្វើការនៅការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម[៨៩] ។ គាត់ក៏ត្រូវបានរាយការណ៍ថា បាននិយាយថា មេធាវីកម្ពុជា ដែលចូលរួមក្នុងការបណ្តុះបណ្តាលដែលរៀបចំឡើងដោយសមាគមមេធាវីអន្តរជាតិក្នុងការគាំទ្រដល់តុលាការកាត់ទោសខ្មែរក្រហម គឺជាការបំពានច្បាប់ប្រទេសកម្ពុជា[៩០] ។ Global Witness បានសរសេរលិខិតមួយទៅកាន់ គី តិច ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ ដើម្បីសួរគាត់ថា តើសេចក្តីអធិប្បាយដែលបានរាយការណ៍ទាំងនេះ ជាការបង្ហាញត្រឹមត្រូវនូវអ្វី ដែលគាត់បាននិយាយមែនដែរ ឬទេ ហើយប្រសិនបើដូច្នេះ សូមឱ្យពន្យល់ពីអត្ថន័យរបស់ពួកគេ ។ គី តិច មិនបានឆ្លើយតបលិខិតនេះនៅឡើយទេ ។ បុគ្គលិកសិទ្ធិមនុស្សបានបង្ហាញពីការព្រួយបារម្ភថា គី តិច នឹងធ្វើការតាមសេចក្តីណែនាំពីមន្ត្រីជាន់ខ្ពស់ប្រទេសកម្ពុជា ដែលចង់ឃើញដំណើរការកាត់ទោសជាប់គាំង ឬរំសាយទាំងអស់គ្នាវិញ[៩១] ។

នៅចុងឆ្នាំ ២០០១ បញ្ជីឈ្មោះអ្នកផ្តល់ឥណទានមិនទាន់បានសងរបស់ក្រុមហ៊ុន Kingwood រួមមានមិនត្រឹមតែធនាគារប៉ុណ្ណោះទេ តែថែមទាំងអ្នកម៉ៅការរបស់ខ្លួនទៀតផង ។ នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០១ នាយកគ្រប់គ្រងក្រុមហ៊ុន Kingwood លោក Lia Chun Hua និង សេង គាង បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដែលគ្រប់គ្រងលើការទិញឈើមូលកាលពីមុន និងនាពេលអនាគត ។ ឃុន ថុង បានចុះហត្ថលេខាអមលើឯកសារក្នុងឋានៈជាសាក្សី[៨៤] ។ កិច្ចព្រមព្រៀងនេះបង្ហាញថា ក្រុមហ៊ុន Kingwood បានខ្ចី សេង គាង ជាង US$១.៩ លាន ដែល Lia Chun Hua បានសន្យាសងបណ្តាក់ US$១00,000 ក្នុងរយៈពេលជាង ២០ ខែ ។ Lia Chun Hua ក៏បានសន្យាបន្តទិញឈើមូលពី សេង គាង ផងដែរ ហើយបានប្រគល់សិទ្ធិឱ្យគាត់គ្រប់គ្រងជាបណ្តោះអាសន្នលើគ្រឿងម៉ាស៊ីនអាជីវកម្មចំនួន ៩៤មុខ ក្នុងរោងចក្រក្រុមហ៊ុន Kingwood ជាការធានា ។ ការគ្រប់គ្រងរបស់គាត់លើគ្រឿងម៉ាស៊ីនទាំងនេះ នឹងក្លាយជាអចិន្ត្រៃយ៍ក្នុងករណីដែលមានការបំពានលើកិច្ចសន្យាសងប្រាក់នេះ[៨៤] ។គ្រឿងម៉ាស៊ីនដែលបានផ្ទេរឱ្យ សេង-គាង គឺដូចគ្នានឹងបរិក្ខារដែលបានបញ្ចាំឱ្យធនាគារកម្ពុជាសាធារណៈ ដោយ សុខ កែវ ។ មិនច្បាស់ថា តើធនាគារ ឬ សុខ កែវ បានដឹងពីកិច្ចព្រម-ព្រៀងរបស់ Lia Chun Hua ជាមួយ សេង គាង ដែរ ឬអត់នោះទេ ។


កិច្ចសន្យារវាង សេង គាង និង Lia Chun Hua ពាក់ព័ន្ធការផ្គត់ផ្គង់ឈើ និងបំណុលរបស់ Kingwood ខែ តុលា ឆ្នាំ ២០០១

ដោយស្ថិតក្រោមសម្ពាធពីអង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយអន្តរជាតិ ការរំពឹងទុករបស់ក្រុមហ៊ុន Kingwood ក្នុងការបន្តសងបំណុលរបស់ខ្លួន មិនត្រូវបានពង្រឹងឡើយនៅពេលដែលរដ្ឋាភិបាលកម្ពុជាបានកំណត់ការបញ្ឈប់មួយរយៈ ចំពោះការប្រមូលផលសម្បទានឈើដែលមានសុពលភាពចាប់ពីខែ មករា ឆ្នាំ ២០០២ ។ ការបញ្ឈប់មួយរយៈកើតឡើង បន្ទាប់ពីការខកខានរបស់សម្បទានិកក្នុងការបំពេញតាមកាលផុតកំណត់ដាក់ជូននូវផែនការគ្រប់គ្រងព្រៃឈើប្រកបដោយចេរភាព (SFMPs) និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម (ESIAs) ដែលបានកំណត់ឱ្យនៅចុងខែ វិច្ឆិកា ឆ្នាំ ២០០១ ។

ការបញ្ឈប់មួយរយៈចំពោះការកាប់ឈើ ត្រូវបានធ្វើឡើងបន្ទាប់ដោយការបញ្ឈប់មួយរយៈនូវការដឹកជញ្ជូនឈើមូល ដែលចូលជាធរមានក្នុងខែឧសភាឆ្នាំ២០០២ ។សម្បទានិកមួយចំនួនដែលគួរឱ្យកត់សំគាល់ គឺក្រុមហ៊ុន GAT International និងក្រុមហ៊ុន Pheapimex ជាដំបូងបន្តកាប់ឈើ និងដឹកជញ្ជូនឈើបំពានលើការបញ្ឈប់មួយរយៈនេះ ។ ទោះយ៉ាងណាក៏ដោយ បន្ទាប់ពីការបង្ហាញរបស់ Global Witness ពីសកម្មភាពរបស់ក្រុមហ៊ុន GAT ហ៊ុន សែន បានលុបចោលសម្បទានចំនួនពីររបស់ក្រុមហ៊ុនក្នុង ខែ មិថុនា ឆ្នាំ ២០០២[៩២] ។ ពីនេះតទៅ ប្រព័ន្ធសម្បទានឈើបានចូលទៅកាន់អសកម្មភាពស្ទើរតែទាំងស្រុង ។

## ២.៣ ការគ្រប់គ្រងដែលមានអរិភាពខ្លាំង

សម្រាប់ ឌី ចូច, សេង គាង និង ឃុន ថុង ក្រុមហ៊ុនសម្បទានដូចជាក្រុមហ៊ុន Kingwood បានផ្តល់ឱ្យនូវលក្ខណៈមានប្រយោជន៍ស្ថិតនៅពីក្រោយអ្វីដែលពួកគេអាចធ្វើការគ្រប់គ្រងលើការធ្វើអាជីវកម្មកាប់ឈើមួយផ្នែកធំនៅក្នុងប្រទេសកម្ពុជា ។ ទោះយ៉ាងណាក៏ដោយ ការបញ្ឈប់មួយរយៈនៅឆ្នាំ ២០០២ ទៅលើការប្រមូលផល និងការដឹកជញ្ជូន បានផ្លាស់ប្តូរចំណុចនេះទាំងស្រុង ។

ប្រភពមួយជិតស្និទ្ធនឹងប្រតិបត្តិការក្រុមហ៊ុន Kingwood បានជូនដំណឹងដល់ Global Witness ថា ក្នុងខែ សីហា ឆ្នាំ ២០០២ នាយកគ្រប់គ្រងរបស់ក្រុមហ៊ុន Kingwood លោក Lia Chun Hua បានព្យាយាមកាត់បន្ថយការខាតបង់ ដែលមានការកើនឡើងរបស់គាត់ និងចាកចេញពីកម្ពុជាជាធម្មតា ។ ដោយយោងតាមប្រភពនេះបានឱ្យដឹងថា គាត់ត្រូវបានទប់ស្កាត់ពីការធ្វើដូចនេះ ដោយ សេង គាង ដែលកូនចៅរបស់គាត់បានចាប់ជំរត់ Lia រឹបអូសលិខិតឆ្លងដែនរបស់គាត់ និងដាក់គាត់ជាចំណាប់ខ្មាំងក្នុងបរិវេណរោងចក្រ ។ Global Witness បានស៊ើបអង្កេតការបញ្ជាក់អះអាងទាំងនេះ ហើយបានប្រមូលព័ត៌មានពីប្រភពជាច្រើន ដែលចង្អុលបង្ហាញទៅលើតម្រូវការឱ្យមានការស៊ើបអង្កេតយុត្តិធម៌ ដែលអាចទុកចិត្តបានទៅលើជោគវាសនារបស់ Lia និងការកាន់កាប់នាពេលបច្ចុប្បន្នលើក្រុមហ៊ុន Kingwood ។ ព័ត៌មាននេះ ត្រូវបានសង្ខេបដូចខាងក្រោមនេះ :

i) ***ឯកសារពាក់ព័ន្ធការប្រគល់ឱ្យរបស់ Lia Chun Hua ចំពោះការគ្រប់គ្រងក្រុមហ៊ុន Kingwood***


កិច្ចសន្យាដែល Lia Chun Hua ទទួលស្គាល់បំណុលជិត US$ ៣.៥ លាន ចំពោះ សេង គាង និង ឃុន ថុង ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២

Lia Chun Hua បានលះបង់ការគ្រប់គ្រងក្រុមហ៊ុន Kingwood ដោយមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយ សេង គាង និង ឃុន ថុង ក្នុងអំឡុងពាក់កណ្តាលទីពីរនៃ ខែ សីហា ឆ្នាំ ២០០២ ។ នៅថ្ងៃទី ១២ ខែ សីហា គាត់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងតំណាងឱ្យក្រុមហ៊ុនដោយទទួលស្គាល់បំណុលចំនួន US$១,៨៧១,៨៧១.៥៦ ចំពោះ សេង គាង និង US$១,៦០៥,000 ចំពោះ ឃុន ថុង ។ ឯកសារនេះ ជំនួសឱ្យដោយមានប្រសិទ្ធិភាពលើកិច្ចព្រមព្រៀងស្តីពីការទិញឈើ ក្នុងខែ តុលា ឆ្នាំ ២០០១ ។ កិច្ចព្រមព្រៀងបានបញ្ជាក់ម្តងទៀតថា សេង គាង ហើយឥឡូវនេះ ឃុន ថុង ផងដែរ នឹងគ្រប់គ្រងគ្រឿងម៉ាស៊ីនរបស់រោងចក្រទាំង ៩៤មុខដូចគ្នា ជាការធានារហូតដល់ Lia Chun Hua បានជម្រះបំណុលរបស់គាត់រួច ។ Lia ក៏បានព្រមព្រៀងបង់ការប្រាក់ ១.៨% ក្នុងមួយខែផងដែរ ។ ឯកសារនេះត្រូវបានចុះហត្ថលេខាអមដោយអភិបាលរងស្រុក និងមេឃុំ[៩៣] ។

មួយសប្តាហ៍ក្រោយមក នៅថ្ងៃទី ១៩ ខែ សីហា Lia Chun Hua បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីពីរ ដែលក្នុងនោះ គាត់បានប្រគល់ឱ្យការគ្រប់គ្រងទាំងអស់លើក្រុមហ៊ុន Kingwood ។ កិច្ចសន្យាទីពីរនេះបង្ហាញថា Lia បានផ្ទេរប្រតិបត្តិការ និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន Kingwood ទាំងអស់ឱ្យទៅ សេង គាង និង ឃុន ថុង រហូតដល់បំណុល និងការប្រាក់ត្រូវបានបង់សងវិញ ។ កិច្ចព្រមព្រៀងបន្ថែមទៀតថា នៅពេលដែលការសងប្រាក់លើកចុងក្រោយ ត្រូវបានធ្វើឡើង សេង គាង និង ឃុន ថុង នឹងរក្សាមានភាគហ៊ុន ៣0% ក្នុងក្រុមហ៊ុន ។ ឯកសារក៏បានប្រគល់ឱ្យ Lia ជួយរៀបចំរោងចក្រផងដែរ ។ ជាថ្មីម្តងទៀត កិច្ចព្រមព្រៀងត្រូវបានធ្វើជាសាក្សីដោយអភិបាលរងស្រុក និងមេឃុំ[៩៤] ។

នៅថ្ងៃបន្ទាប់មក សេង គាង, ឃុន ថុង និង Lia Chun Hua បានចុះហត្ថលេខាលើអនុស្សារណៈរាយគ្រឿងម៉ាស៊ីនទាំង ៩៤ មុខ ដែលមានយោងក្នុងកិច្ចព្រមព្រៀងមុន ។ ឯកសារសរសេរដោយដៃនេះមានហត្ថលេខាមនុស្ស ១៣ នាក់ផ្សេងគ្នា ដែលរួមមានទាំងមន្ត្រីមូលដ្ឋាន និងនាយប៉ូលីសផងដែរ ។ កិច្ចព្រមព្រៀងត្រូវបានភ្ជាប់ដោយកិច្ចសន្យាទីបួន ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២០ ខែសីហា ផងដែរ ដែលបញ្ជាក់ថា ការគ្រប់គ្រងគ្រឿងម៉ាស៊ីនរោងចក្រ Kingwood ទាំងអស់បានប្រគល់ឱ្យ សេង គាង, ឃុន ថុង និងបុគ្គលឈ្មោះ យៀម សេង[៩៥] ។ ហត្ថលេខីចំពោះកិច្ចព្រមព្រៀងចុងក្រោយនេះ គឺ Lia Chun Hua និងពាណិជ្ជករជនជាតិម៉ាឡេស៊ី និង Lim Yok Fong ដែលជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន Kingwood[៩៦] ។



**កិច្ចសន្យាចុះហត្ថលេខាដោយ សេង គាង, ឃុន ថុង និង** Lia Chun Hua
**ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០២**



**កិច្ចសន្យាដែល** Lia Chun Hua **ប្រគល់ការគ្រប់គ្រងក្រុមហ៊ុន** Kingwood
**ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២**



**កិច្ចព្រមព្រៀងទីពីរពាក់ព័ន្ធការប្រគល់ទ្រព្យសម្បត្តិរបស់** Kingwood
**ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០២**

លទ្ធផល គឺជាការផ្ទេរពិសេសនូវកម្មសិទ្ធិទ្រព្យសម្បត្តិ និងប្រតិបត្តិការរបស់ក្រុមហ៊ុន Kingwood ឱ្យទៅ សេង គាង និង ឃុន ថុង ។ ស្របពេលដែលលក្ខខណ្ឌនៃកិច្ចសន្យាផ្សេងៗបញ្ជាក់ថា Lia Chun Hua អាចបានមកវិញមួយផ្នែក ប្រសិនបើមិនបានទាំងស្រុងនូវការគ្រប់គ្រងក្រុមហ៊ុននាពេលអនាគត ។ កម្រិតបំណុលដែលគាត់សន្យាសង ដោយមិនមានបង្ហាញពីការបង់ការប្រាក់មានខ្ពស់ណាស់ ។

ច្បាប់វិនិយោគរបស់ប្រទេសកម្ពុជាចែងថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) របស់រដ្ឋាភិបាល ត្រូវផ្តល់ការយល់ព្រមរបស់ខ្លួនចំពោះការផ្ទេរកម្មសិទ្ធិក្រុមហ៊ុនណាមួយក្នុងរយៈពេល ៣០ថ្ងៃពេញ មុនពេលហេតុការណ៍នេះកើតឡើង[៥៦] ។ ទោះយ៉ាងណាក៏ដោយ តាមចំណេះដឹងដ៏ប្រសើរបំផុតរបស់ Global Witness គ្មានក្រុមប្រឹក្សារបស់ក្រុមហ៊ុន Kingwood ឬ សេង គាង និង ឃុន ថុង បានបញ្ជូនឱ្យ CDC សម្រាប់សុំការអនុញ្ញាតរបស់ខ្លួននោះទេ ។ មន្ត្រី CDC ក្រោយមកបានដឹងពីការគ្រប់គ្រង និងការចុះកិច្ចសន្យាជាមួយ សេង គាង ។ គាត់បានជូនដំណឹងទៅពួកគេថា គាត់បានគ្រប់គ្រងក្រុមហ៊ុន Kingwood ដែលមធ្យោបាយដែលគាត់បានធ្វើ គឺដើម្បីចៀសវាងទំនួលខុសត្រូវដែលមានចំពោះបំណុលដែលមានស្រាប់របស់ក្រុមហ៊ុន[៨៥] ។

ការផ្ទេរការគ្រប់គ្រង ធ្វើឱ្យមានចម្ងល់ជាច្រើនដែលមិនបានឆ្លើយ ។ ឯកសារដែល Lia Chun Hua បានចុះហត្ថលេខានៅថ្ងៃទី ១២ ខែសីហា បានផ្តល់ឱ្យ សេង គាង និង ឃុន ថុង គ្រប់គ្រងគ្រឿងម៉ាស៊ីនរោងចក្រ រហូតដល់គាត់បានជម្រះបំណុលរបស់គាត់រួច ។ នេះយ៉ាងហោចណាស់ រក្សានូវកម្រិតជាប់លាប់ផ្នែកខាងក្នុងជាមួយកិច្ចព្រមព្រៀងទៅលើការសងបំណុល និងការផ្គត់ផ្គង់ឈើនៅ ខែតុលា ឆ្នាំ ២០០១ ។ បន្ទាប់មក តើហេតុអ្វីមួយសប្តាហ៍ក្រោយមក Lia Chun Hua ព្រមព្រៀងផ្ទេរការគ្រប់គ្រងប្រតិបត្តិការក្រុមហ៊ុន Kingwood ទាំងមូល? គ្មានអ្វីមួយនៅក្នុងឯកសារទទួលខុសត្រូវចំពោះការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវហេតុការណ៍នេះទេ ។ ជាងនេះទៅទៀត តើអ្វីដែលទទួលខុសត្រូវចំពោះពង្រាងដែលត្រួតស៊ីគ្នាទាំងបួន និងក្នុងករណីខ្លះឯកសារព្រាងជាលាយលក្ខណ៍អក្សរ ? ពេលដែលដានលើក្រដាស មិនមែនជាភស្តុតាងពីការបង្ខិតបង្ខំផ្ទាល់ កិច្ចព្រមព្រៀងនេះផ្តល់ឱ្យនូវការលេចឡើងពីការផ្ទេរការគ្រប់គ្រង ដែលមានលក្ខណៈប្រញាប់ប្រញាល់ និងមិនត្រឹមត្រូវតាមច្បាប់ ។

ii) ***ការពន្យល់ពីមនុស្សដែលបានប្រើប្រាស់ ឬពាក់ព័ន្ធជាមួយក្រុមកាប់ឈើ***

នៅចុងឆ្នាំ ២០០២ និងដើមឆ្នាំ ២០០៣ Global Witness បានធ្វើការសម្ភាសន៍ជាបន្តបន្ទាប់នៅតំបន់រោងចក្រ ក្រុមហ៊ុន Kingwood ជាមួយបុគ្គលិកដែលបានប្រើប្រាស់ដោយក្រុមកាប់ឈើ ។ ម្នាក់ក្នុងចំណោមអ្នកយាមជាច្រើន បាននិយាយថា កាតព្វកិច្ចរបស់គាត់រួមមានការដើរតាមការពារ "បុរសជនជាតិចិន" នៅពេលធ្វើដំណើរម្តងៗទៅកាន់ភ្នំពេញ ។ អ្នកយាមនោះ មិនបានផ្តល់លំអិតបន្ថែមពីអត្តសញ្ញាណរបស់បុរសនោះ ឬហេតុអ្វីបានជាគាត់ ត្រូវការការដើរតាមការពារនោះទេ[៥៧] ។

ក្នុងឆ្នាំ ២០០៤ Global Witness បានធ្វើសម្ភាសន៍ជាមួយសហការីជិតស្និទ្ធិរបស់ សេង គាង ដែលបានបញ្ជាក់ថា ក្រុមកាប់ឈើកំពុងឃុំ Lia ជាអ្នកទោសនៅក្នុងរោងចក្រ ។ មនុស្សម្នាក់នេះបានបន្ថែមទៀតថា ទោះបីជាអភិជនឈើនេះជឿជាក់ថា Lia មិនអាចគេច



**ការិយាល័យរបស់ក្រុមហ៊ុន** Kingwood **: ប្រភពជាច្រើនបានប្រាប់** Global Witness **ថា** Lia Chun Hua **កំពុងត្រូវបានចាប់ជាចំណាប់ខ្មាំងក្នុងអគារខាងក្នុងបរិវេណរោងចក្រ** Kingwood

ខ្លួនក៏ដោយ ក៏ពួកគេបារម្ភថា គាត់ប្រហែលជាព្យាយាមសម្លាប់ខ្លួន ។ អ្នកទទួលការសម្ភាសន៍ ក៏បានរាយការណ៍ពីវត្តមាននៅរោងចក្រនូវជនជាតិតៃវ៉ាន់ ១០ នាក់ផ្សេងទៀត ដែល ឌី ចូច និង ឃុន ថុង ប្រើប្រាស់ជាអ្នកបច្ចេកទេស ។ អ្នកបច្ចេកទេសទាំងនេះ ត្រូវបាននិយាយថា ត្រូវបានហាមមិនឱ្យចេញពីរោងចក្រ ដោយសារការភ័យខ្លាចថា ពួកគេអាចលាតត្រដាងព័ត៌មានពីសកម្មភាពរបស់ក្រុមនេះ[៩៨] ។

នាឆ្នាំដដែលនោះ Global Witness បានធ្វើកិច្ចសម្ភាសន៍ជាមួយបុគ្គលទីបី ដែលពាក់ព័ន្ធជិតស្និទ្ធនឹងប្រតិបត្តិការក្រុមហ៊ុន Kingwood ដែលនៅតែរក្សាបានការចេញចូលជាប្រចាំទៅកាន់រោងចក្រ ។ មនុស្សម្នាក់នេះ មិនបានជួប Lia Chun Hua ចាប់តាំងពីការចាប់ជំរិតគាត់ តែបានបញ្ជាក់ថាបានឮពីកម្មករថា គាត់ត្រូវបានរក្សាទុកក្នុងលក្ខខណ្ឌឃោរឃៅ ដែលប៉ះពាល់ដល់សុខភាពរបស់គាត់ថា ទូរស័ព្ទរបស់គាត់មិនត្រូវបានភ្ជាប់ទៀតទេ ហើយថាគាត់គ្មានទំនាក់ទំនងទៀតជាមួយពិភពខាងក្រៅឡើយ ។ អ្នកទទួលការសម្ភាសន៍នេះ បានរាយការណ៍ថា អ្នកយាមធ្វើដំណើរតាម Lia Chun Hua គ្រប់ពេលទាំងអស់ក្នុងបរិវេណរោងចក្រ[៩៩] ។

ក្នុងកិច្ចសម្ភាសន៍ដាច់ដោយឡែកមួយទៀតក្នុងឆ្នាំ ២០០៤ ដៃគូអាជីវកម្មរបស់ សេង គាង បានជូនដំណឹងដល់ Global Witness ថា LiaChunHua កំពុងរស់នៅក្នុងបរិវេណក្រុមហ៊ុនKingwood ។មនុស្សម្នាក់នេះមិនបាននិយាយពីលក្ខខណ្ឌនៃការចាប់ជំរិត ឬការឃុំឃាំង និងបានបញ្ជាក់ថា Lia កំពុងស្ថិតក្នុង "ការតាមថែរក្សាបានយ៉ាងល្អ" ។ ទោះយ៉ាងណា ពួកគេមិនបានផ្តល់ការពន្យល់ពីហេតុអ្វីបានជា Lia បានចាកចេញពីផ្ទះរបស់គាត់ ដើម្បីរស់នៅក្នុងរោងចក្រដំណើរការអាជីវកម្មឬហេតុអ្វីបានជាគាត់ត្រូវការការតាមថែរក្សានោះឡើយ[១០០] ។

ក្នុងឆ្នាំ ២០០៥ បុគ្គលិករបស់ក្រុមកាប់ឈើបានជូនដំណឹងដល់ Global Witness ថា Lia Chun Hua បានបន្តរស់នៅក្នុងបរិវេណរោងចក្រ និងកំពុងត្រូវបានយាមមើលដោយកងរាជអាវុធហត្ថដែលបានជួលដោយ ឌី ចូច[១០១] ។

### iii) ការពន្យល់ពីមន្ត្រីដែលបានស៊ើបអង្កេតករណីនេះ

មន្ត្រីរដ្ឋាភិបាលដ៏ល្បីឈ្មោះម្នាក់ ដែលបានធ្វើការស៊ើបអង្កេតផ្ទាល់ខ្លួនគាត់លើក្រុមហ៊ុន Kingwood បាននិយាយប្រាប់ Global Witness ក្នុងឆ្នាំ ២០០៤ ថា សេង គាង និង ឃុន ថុង កំពុងទុក Lia Chun Hua និងបុគ្គលិកជនជាតិបរទេសផ្សេងទៀតជាចំណាប់ខ្មាំងក្នុងបរិវេណរោងចក្រ និងបានរឹបអូសលិខិតឆ្លងដែនរបស់ពួកគេ ។ មន្ត្រីនេះបានបន្ថែមទៀតថា អាជ្ញាធរមិនអាចដោះលែងបុរសទាំងនោះដោយសារតែក្រុមកាប់ឈើតំណាងផលប្រយោជន៍អាជីវកម្មរបស់ ប៊ុន រ៉ានី ដែលជាភរិយារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន[១០២] ។



**ក្រុមកាប់ឈើ ត្រូវបានរាយការណ៍ថាតំណាងផលប្រយោជន៍អាជីវកម្មរបស់ ប៊ុន រ៉ានី ភរិយារបស់នាយករដ្ឋមន្ត្រី**



Lia Chun Hua **ត្រូវបាននិយាយថា ត្រូវបានយាមកាមដោយសមាជិកកងរាជអាវុធហត្ថរបស់ប្រទេសកម្ពុជា**

### iv) ភស្តុតាងពីក្រុមកាប់ឈើដាក់វិធានការណ៍សន្តិសុខតឹងរ៉ឹងនៅរោងចក្រក្រុមហ៊ុន Kingwood

ដោយយោងតាមអ្នកយាមសន្តិសុខនៅរោងចក្រក្រុមហ៊ុន Kingwood ជាអ្នកដែលទទួលខុសត្រូវចំពោះសន្តិសុខចាប់ពីឆ្នាំ ២០០២ គឺជាមន្ត្រីកងរាជអាវុធហត្ថឈ្មោះ កែវ សារីម[១០៣] ។ នៅឆមាសទីមួយនៃឆ្នាំ ២០០៥ ក្រុមរបស់ កែវ សារីម ដែលមានមន្ត្រីកងរាជអាវុធហត្ថចំនួនបីនាក់ ម្នាក់ៗប្រដាប់ដោយអាវុធ AK-៤៧ និងកាំភ្លើងខ្លី រួមជាមួយអ្នកយាមបន្ថែមចំនួនប្រាំមួយនាក់ទៀត ដែលម្នាក់ៗបំពាក់ត្រឹមតែអាវុធ AK-៤៧ ប៉ុណ្ណោះ[១០៤] ។ អ្នកទាំងអស់គ្នាត្រូវបានបង់ចំណាយឱ្យដោយ ឌី ចូច ។ ពីរនាក់ក្នុងចំណោមអ្នកយាមទាំងនេះ ត្រូវបានរៀបរាប់លំអិតថាធ្វើដំណើរតាម Lia Chun Hua គ្រប់ពេលនៅក្នុងបរិវេណរោងចក្រ ។ កាតព្វកិច្ចផ្សេងទៀតរបស់អ្នកយាម រួមមាន ការពិនិត្យ និងឆែកឆេរបុគ្គលិករោងចក្រ ពេលដែលពួកគេមកធ្វើការរៀងរាល់ថ្ងៃ និងហាមភ្ញៀវដែលមិនត្រូវការ មិនឱ្យចូល[១០៥] ។ អ្នកខាងក្រោយនេះ រួមមានសមាជិកអាជ្ញាធរមូលដ្ឋានដែលត្រូវបានទប់ស្កាត់ពីការធ្វើការត្រួតពិនិត្យ ដែលបានរៀបចំឡើងទៅលើប្រតិបត្តិការរបស់រោងចក្រ និងការអនុវត្តតាមទិដ្ឋាការរបស់បុគ្គលិកបរទេសរបស់ខ្លួន[៨៥] ។

v) **ការមើលឃើញពីបុរសដែលស្រដៀង** Lia Chun Hua

ក្នុងអំឡុងពេលទៅកាន់រោងចក្រក្រុមហ៊ុន Kingwood ក្នុងខែ ធ្នូ ឆ្នាំ ២០០២ អ្នកស៊ើបអង្កេតរបស់ Global Witness បានឃើញបុរសជនជាតិចិនចំណាស់ម្នាក់ជាមួយស្ត្រីជនជាតិចិនបួននាក់ ដែលកំពុងត្រូវបានតាមការពារទៅកាន់យានយន្ត ដែលកំពុងរង់ចាំដោយបុរសពីរនាក់ពាក់ឯកសណ្ឋានយោធា និងកាន់កាំភ្លើង ។ ពេលដែលមិនអាចបញ្ជាក់បានពីអត្តសញ្ញាណរបស់បុរសនោះ លក្ខណៈរូបរាងរបស់គាត់ និងអ្នកតាមការពារប្រដាប់អាវុធ ប្រៀបផ្ទឹមលក្ខណៈរបស់ Lia Chun Hua និងលក្ខខណ្ឌនៃការឃុំឃាំងដែលបានចោទប្រកាន់របស់គាត់[១០៦] ។

ក្នុងខែ មេសា ឆ្នាំ ២០០៥ បុគ្គលិករបស់ Global Witness បានរកឃើញថាមានអ្នកយាមបួននាក់បំពាក់អាវុធ AK-៤៧s ដើរតាមការពារបុរសម្នាក់ក្នុងបរិវេណក្រុមហ៊ុន Kingwood ។ បុគ្គលិករបស់ក្រុមកាប់ឈើដែលបានដើរតាម Global Witness បានស្គាល់បុរសនោះជា Lia Chun Hua ។ បុគ្គលិកនេះបានបន្ថែមទៀតថា Lia មិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីប្រទេសកម្ពុជា ហើយត្រូវតែដើរតាមការពារនៅគ្រប់ពេលវេលាទាំងអស់ដោយអ្នកយាមប្រដាប់អាវុធ[១០៧] ។

vi) **របាយការណ៍ដែល** Lia Chun Hua **មិនបានឆ្លើយតបចំពោះការកោះហៅពីតុលាការក្នុងក្រុងភ្នំពេញ**

ចាប់តាំងពីពេលផ្ទេរក្រុមហ៊ុន Kingwood ធនាគារ Maybank នៃប្រទេសម៉ាឡេស៊ីបានរកវិធានការណ៍ផ្លូវច្បាប់ ដើម្បីទារយកបំណុលដែលមិនបានបង់ពីក្រុមហ៊ុន ។ Lia Chun Hua មិនបានឆ្លើយតបចំពោះការកោះហៅឱ្យបង្ហាញខ្លួនចំពោះមុខតុលាការក្នុងក្រុងភ្នំពេញយ៉ាងហោចណាស់ចំនួនបីដង ។ កន្លែងរបស់គាត់ត្រូវបានដាក់ដោយមេធាវី ដែលបានជួលដោយ សេង គាង ដែលមិនបានពន្យល់ពីការមិនបានបង្ហាញខ្លួនម្តងហើយ ម្តងទៀតរបស់គាត់នោះទេ[៨៧] ។ ឯកសារតុលាការកត់ត្រាថា Lia Chun Hua មានកន្លែងស្នាក់នៅអចិន្ត្រៃយ៍ក្នុងក្រុងភ្នំពេញ តែ "បច្ចុប្បន្នកំពុងរស់នៅក្នុងរោងចក្រអារឈើក្រុមហ៊ុន Kingwood នៅឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល" ។[១០៨]

ក្នុងខែ តុលា ឆ្នាំ ២០០៦ មន្ត្រីរដ្ឋម្នាក់បានជូនដំណឹងដល់ Global Witness ថា ពួកគេបានទទួលលិខិតនាពេលថ្មីៗនេះ ដែលបានចុះហត្ថលេខាដោយ Lia Chun Hua តំណាងឱ្យក្រុមហ៊ុន Kingwood[១០៩] ។ ស្របពេលដែលព័ត៌មាននេះ ផ្តល់ឱ្យការយល់ដឹងបន្តិចបន្តួចពីស្ថានភាពនាពេលបច្ចុប្បន្នរបស់ Lia ពិតជាឱ្យដឹងថា គាត់កំពុងតែនៅក្នុងប្រទេសកម្ពុជា ហើយបន្តពាក់ព័ន្ធជាមួយប្រតិបត្តិការរបស់ក្រុមហ៊ុន ។

ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ Global Witness បានសរសេរលិខិតជូន Lia Chun Hua ក៏ដូចជា សេង គាង, ឌី ចូច និង ឃុន ថុង និងម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន Kingwood ផ្សេងទៀត ដើម្បីសួរអំពីទីកន្លែងនាពេលបច្ចុប្បន្នរបស់ Lia ។ នៅពេលបោះពុម្ពផ្សាយ Global Witness មិនបានទទួលការឆ្លើយតបណាមួយចំពោះលិខិតទាំងនេះទេ ។

សរុបមកមានមូលដ្ឋានជាច្រើនធ្វើឱ្យជឿជាក់ថាការរាយការណ៍ពីការចាប់ជំរិតរបស់ Lia Chun Hua គឺត្រឹមត្រូវហើយថា សុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ អាចកំពុងស្ថិតក្នុងគ្រោះថ្នាក់ខ្លាំង ។ ច្បាស់ណាស់ដែលថា អាជ្ញាធរដឹងច្បាស់ពីស្ថានភាព តែមិនមានបំណង ឬមិនអាចចាត់វិធានការណ៍ ។ ដោយមានទំនាក់ទំនងជិតស្និទ្ធរវាងក្រុមកាប់ឈើ និងមន្ត្រីជាន់ខ្ពស់ ស្ថានភាពនេះ ហាក់ដូចជាមិនអាចផ្លាស់ប្តូរឡើយ ដោយគ្មានសម្ពាធពីខាងក្រៅទៅលើរដ្ឋាភិបាលកម្ពុជា ។

## ២.៤ បណ្តឹងប្រជែង

បន្ទាប់ពីទទួលបានរោងចក្រក្រុមហ៊ុន Kingwood ឌី ចូច, សេង គាង និង ឃុន ថុង បានពិនិត្យមើលបំណុលដែលបានជ្រើសរើសដែលជំពាក់ម្ចាស់បំណុលក្រុមហ៊ុន Kingwood ផ្សេងទៀត ។ ពួកគេក៏អាចបានខ្ចីប្រាក់ដោយខ្លួនពួកគេផងដែរ : ប្រភពមួយជិតស្និទ្ធគ្រួសាររបស់ ហ៊ុន សែន បានប្រាប់ Global Witness ថា ប៊ុន រ៉ានី បានផ្តល់កម្ចីដល់ សេង គាង សម្រាប់ប្រតិបត្តិការក្រុមហ៊ុន Kingwood[១១០] ។ Global Witness បានសរសេរទៅកាន់ ប៊ុន រ៉ានី ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ ដើម្បីស្នើសុំយោបល់របស់គាត់ពីការបញ្ជាក់អះអាងនេះ ។ មកទល់ពេលដែលរបាយការណ៍បោះពុម្ពផ្សាយ គាត់មិនទាន់បានឆ្លើយតបនៅឡើយទេ ។

ទោះយ៉ាងណា ម្ចាស់បំណុលរបស់ក្រុមហ៊ុន Kingwood មួយដែលអភិជនឈើបដិសេធសង គឺធនាគារ Maybank ដែលបានទទួលការសងប្រាក់បន្តិចបន្តួច ឬគ្មានទាល់តែសោះ ចំពោះចំនួនប្រមាណ US$៩.៤លាន ដែលខ្លួនបានឱ្យក្រុមហ៊ុន Kingwood ខ្ចីក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០[៨៧] ។ ទំហំនៃការខាតបង់ដ៏ច្រើននេះ ជម្រុញឱ្យធនាគារបន្តដំណើរការក្តីបន្តទៀតនៅក្នុងឆ្នាំ ២០០៣ ។

ធនាគារ Maybank បានកំណត់ទិសដៅវិធានការណ៍ច្បាប់របស់ខ្លួនទៅលើនាយកក្រុមហ៊ុន Kingwood លោក Lia Chun Hua និង Lee Kwan Siang[១១១] ។ នេះបានធ្វើឱ្យមានបញ្ហាខ្លាំងដល់ជំហររបស់ក្រុមកាប់ឈើ ។ ឧទាហរណ៍ដំបូង ធនាគារបានគម្រាមពីការគ្រប់គ្រងរបស់ពួកគេទៅលើ Lia ដែលប្រឈមមុខនឹងការកោះហៅឱ្យបង្ហាញខ្លួនចំពោះមុខតុលាការ មិនឱ្យនិយាយបានពីលទ្ធភាពកាត់ទោសជាប់ពន្ធនាគារ ប្រសិនបើត្រូវបានរកឃើញថាមានកំហុស ។ ជាងនេះទៅទៀត ជ័យជម្នះសម្រាប់ Maybank នឹងត្រួសត្រាយផ្លូវឱ្យធនាគារអនុវត្តបណ្តឹងរបស់ខ្លួនទៅលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន Kingwood ដែល សេង គាង និង ឃុន ថុង រឹបអូសក្នុងខែ សីហា ឆ្នាំ ២០០២ ។

អភិជនឈើបានទាស់ទែងយ៉ាងខ្លាំងចំពោះករណីនេះ ដោយ សេង គាង តែងតាំងមេធាវីរបស់គាត់ ជេត បូរ៉ាវុធ ឱ្យតំណាងឱ្យ Lia Chun Hua ។ ក្នុងសវនាការមុនកាត់ក្តី ជេត បូរ៉ាវុធ[១១២] បានជំទាស់ថា វិធានការណ៍របស់ Maybank មិនមានសុពលភាព ដោយសារក្រុមហ៊ុន Kingwood នាពេលបច្ចុប្បន្ននេះជារបស់ សេង គាង ។ ទោះយ៉ាងណា គាត់មិនអាចផ្តល់ភស្តុតាងជាឯកសារណាមួយគាំទ្រដល់ការអះអាងនេះ ហើយការកាត់ក្តីបានបន្តទៅមុខទៀត[៨៥] ។

ប្រភពនៅក្នុងតុលាការរបស់កម្ពុជា បានជូនដំណឹង Global Witness ថា នាពេលបន្ទាប់មក អ្នកតំណាងរបស់ សេង គាង បានព្យាយាមសូកប៉ាន់ចៅក្រម ហើយនៅពេលដែលមិនបានជោគជ័យបានគម្រាមកំហែងគាត់ ។ ប្រភពទាំងនេះបញ្ជាក់ថា ការគម្រាមកំហែងទាំងនេះ ត្រូវបានធ្វើឡើងដោយចំពីគ្នាដោយ ជេត បូរ៉ារុធ និង គី តិច ជាមេធាវី ដែលបានជួយ សុខ កែវ និងក្រុមហ៊ុន Kingwood ធានាកម្ចីពីធនាគារកម្ពុជាសាធារណៈក្នុងឆ្នាំ ២០០១ ។ ប្រភពទាំងពីរចោទប្រកាន់ថា ជេត បូរ៉ារុធ និង គី តិច បានប្រាប់ចៅក្រមថា ប៊ុន រ៉ានី ភរិយារបស់ ហ៊ុន សែន នឹងបណ្តេញគាត់ចេញ ប្រសិនបើគាត់ត្រូវបានរកឃើញថាជួយដល់ Maybank[៨៨] ។ Global Witness បានសរសេរជូន ជេត បូរ៉ារុធ និង គី តិច ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ ដើម្បីស្នើសុំយោបល់របស់ពួកគេលើការចោទប្រកាន់នេះ ។មកទល់នឹងពេលរបាយការណ៍នេះបោះពុម្ពផ្សាយ គ្មាននរណាម្នាក់បានឆ្លើយតបចំពោះលិខិតទាំងនេះទេ ។

ក្នុងខែ មេសា ឆ្នាំ ២០០៤ តុលាការបានជួយដល់ Maybank ចោទប្រកាន់ Lia Chun Hua និងប្រធាន Kingwood ឈ្មោះ Lee Kwan Siang ចំពោះការបំពានលើសេចក្តីទុកចិត្ត ។Lia Chun Hua និង Lee Kwan Siang បានទទួលការកាត់ទោសកំបាំងមុខឱ្យជាប់ពន្ធនាគារប្រាំមួយខែ ពន្យារពេលរង់ចាំការបង់ប្រាក់កម្ចីរបស់ពួកគេបូកការប្រាក់ និងពិន័យ US$២៥០,០០០ ។ បន្ទាប់ពីបណ្តឹងឧទ្ធរណ៍មិនបានជោគជ័យដោយមេធាវីរបស់ សេង គាង តុលាការបានបញ្ជាក់ពីការចោទប្រកាន់ និងការទោសក្នុងខែ សីហា ឆ្នាំ ២០០៥[១០៨] ។ នេះបានត្រួសត្រាយផ្លូវឱ្យ Maybank រឹបអូសការគ្រប់គ្រងរោងចក្រ ដើម្បីទារសងបំណុលរបស់ក្រុមហ៊ុន Kingwood ។ ទោះបីជាយ៉ាងណាក៏ដោយ មកទល់ពេលនេះ អាជ្ញាធរមិនបានចាត់វិធានការណ៍ណាមួយ ដើម្បីអនុវត្តដីការបស់តុលាការនៅឡើយទេ ។

## ប្រអប់ ៤ : ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន Kingwood – ទ្រព្យសម្បត្តិរបស់ប្រជាជនកម្ពុជា ?

ក្នុងខែ សីហា ឆ្នាំ ២០០៣ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញប្រកាស (សេចក្តីប្រកាសក្រសួង) បញ្ចប់កិច្ចព្រមព្រៀងវិនិយោគរបស់ក្រុមហ៊ុន Kingwood ស្របជាមួយនឹងក្រុមហ៊ុន Mieng Ly Heng ផងដែរ[១១៣] ។ ទោះយ៉ាងណាក៏ដោយ ការលុបចោលទាំងនេះ ពាក់ព័ន្ធទៅនឹងគុណភាពអន់នៃផែនការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមរបស់សម្បទានិក ជាជាងការគ្រប់គ្រងដោយមិនស្របច្បាប់របស់ក្រុមហ៊ុន Kingwood ។

សម្រាប់ ឌី ចូច, សេង គាង និង ឃុន ថុង ការបញ្ចប់កិច្ចព្រមព្រៀងវិនិយោគរបស់ក្រុមហ៊ុន Kingwood មានផលវិបាកបន្តិចបន្តួចប៉ុណ្ណោះចំពោះការផ្គត់ផ្គង់ឈើ ដោយសារតែព្រៃឈើសម្បទាន ត្រូវបានបំផ្លិចបំផ្លាញយ៉ាងធំរួចទៅហើយ ។ ទោះយ៉ាងណាក៏ដោយ ការអនុវត្តច្បាប់ គឺស្ថិតនៅឆ្ងាយខ្លាំង ។ ការត្រួតពិនិត្យសម្បទានដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានបោះពុម្ពក្នុងឆ្នាំ ២០០០ បានសន្និដ្ឋានថា ការបញ្ចប់កិច្ចព្រមព្រៀងវិនិយោគរបស់ក្រុមហ៊ុនពាក់ព័ន្ធនឹងការលុបចោលអាជ្ញាប័ណ្ណ (ប្រមូលផល) ឈើព្រៃឈើរបស់ពួកគេ[១១៤] ។ ដោយស្ថិតក្រោមលក្ខខណ្ឌកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណឈើព្រៃឈើដើមរបស់ក្រុមហ៊ុន Kingwood ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមហ៊ុនបានព្រមព្រៀងបោះបង់ចោលនូវអាគារ និងរោងចក្រទាំងអស់ថា ខ្លួនមិនរើចេញ បន្ទាប់ពីផុតកំណត់អាជ្ញាប័ណ្ណ ។ នេះបង្ហាញថា ឥឡូវនេះរដ្ឋាភិបាលកម្ពុជា ត្រូវបានផ្តល់សិទ្ធិឱ្យរឹបអូសរោងចក្រក្រុមហ៊ុន Kingwood និងទ្រព្យសម្បត្តិដែលនៅសល់ផ្សេងទៀតជាទ្រព្យសម្បត្តិរដ្ឋ[១១៥] ។ដោយសុខកែវ ភរិយារបស់ ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកាន់កាប់បរិវេណរបស់ក្រុមហ៊ុន Kingwood ហើយបងប្រុសរបស់គាត់ ឃុន ថុង ឥឡូវនេះគ្រប់គ្រងរោងចក្រ ប្រហែលជាមិនគួរឱ្យភ្ញាក់ផ្អើលទេថា គ្មានការរឹបអូសបានកើតមានឡើង ។



សេចក្តីបង្គាប់របស់ទីស្តីការគណៈរដ្ឋមន្ត្រី លុបចោលកិច្ចព្រមព្រៀងវិនិយោគរបស់ក្រុមហ៊ុន Kingwood

## ៣. ចំការកៅស៊ូទឹរីង - មុខមាត់ថ្មីនៃការកាប់ឈើទ្រង់ទ្រាយឧស្សាហកម្មក្នុងប្រទេសកម្ពុជា

នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយកាលពីខែ ធ្នូ ឆ្នាំ ២០០១ ថា *"ប្រសិនបើក្រុមហ៊ុនកាប់ឈើនៅតែមិនស្តាប់ ដកអាជ្ញាប័ណ្ណរបស់ពួកគេចេញទៅ ។ ព្រឹកមិញនេះ ខ្ញុំបានអានកាសែតខេមបូឌាដេលី កាសែតបាននិយាយថា ក្រុមហ៊ុនជាច្រើនមិនបានស្តាប់បង្គាប់បញ្ជារបស់ក្រសួងកសិកម្ម ។ អ្នកសាកមើលទៅ ប្រសិនបើអ្នកមិនស្តាប់បង្គាប់សាកមើលទៅ ។ ប្រសិនបើខ្ញុំមិនដកសម្បទានរបស់អ្នក ហើយបិទរោងចក្ររបស់អ្នក ខ្ញុំនឹងកាត់ករបស់ខ្ញុំចោល !"*

បន្ទាប់ពីការបង្ខំឱ្យមានការបញ្ឈប់មួយរយៈនូវការកាប់ និងដឹកជញ្ជូនឈើសម្បទានឈើ លែងផ្តល់ឱ្យមធ្យោបាយសម្រាប់ជាផល-ប្រយោជន៍កាប់ឈើរបស់ពួកអ្នកមានឥទ្ធិពលទាំងនោះហើយ ។ ទោះយ៉ាងណាក៏ដោយ ជាមួយនឹងការសមគំនិតរបស់មន្ត្រីជាន់ខ្ពស់ដែលទទួលខុសត្រូវអនុវត្តការបញ្ឈប់ឧស្សាហកម្មឈើ ពាណិជ្ជករឈើដែលមានអំណាចកាន់តែច្រើនបានបន្តសកម្មភាពរបស់ពួកគេដោយស្ថិតក្រោមលក្ខណៈថ្មីៗជាច្រើន ។ការបំផ្លិចបំផ្លាញខ្លាំងបំផុត និងរកប្រាក់កម្រៃបានច្រើនបំផុតពីនេះ គឺជាការប្រើប្រាស់ការអភិវឌ្ឍន៍ចំការ - មិនថាតែជាគម្រោងអភិវឌ្ឍន៍ ដែលរៀបចំដោយរដ្ឋាភិបាល ឬសម្បទានដីសង្គមកិច្ច (ELCs) - ដែលជាលេសសម្រាប់ការកាប់ឈូសសំអាតព្រៃឈើ ។

អភិជនឈើមួយចំនួន ក៏ត្រូវបានដាក់ឱ្យទទួលយកគុណប្រយោជន៍ពីផែនការនេះ ដូចជា ឌី ចូច, សេង គាង និង ឃុន ថុង ផងដែរ ។ នៅពេលដែលរដ្ឋាភិបាលបានបញ្ឈប់ប្រតិបត្តិការសម្បទាព្រៃឈើ ក្រុមនេះបានកំណត់កន្លែងដោយខ្លួនឯងរួចជាស្រេចសម្រាប់អណ្តូងរ៉ែឈើបន្ទាប់ទៀត គឺការពិចារណាលើចំការកៅស៊ូទឹរីង ។ ទឹរីង គឺជាគំនិតផ្តួចផ្តើមអភិវឌ្ឍន៍អន់ថយមួយរបស់រដ្ឋាភិបាលកម្ពុជា ។ នេះក៏ជាឧទាហរណ៍បុរាណមួយពីវិធីនៃការផ្តល់ឱ្យទ្រព្យសម្បត្តិសាធារណៈខុស ដោយការពុករលួយ ដែលផ្តល់ប្រយោជន៍ដល់អ្នកដឹកនាំនយោបាយរបស់ប្រទេស ដោយប្រើប្រាស់ចំណាយរបស់អ្នកក្រីក្រនៅជនបទ ។

### ៣.១ សហគ្រាសលក្ខណៈគ្រួសារ

ក្នុងខែ សីហា ឆ្នាំ ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញផ្សាយការអំពាវនាវបែបកុម្មុយនីស្តមួយឱ្យមានការបង្កើត "ចំការកៅស៊ូលក្ខណៈគ្រួសារ" ថា ជាផ្នែកមួយនៃគោលនយោបាយអភិវឌ្ឍន៍ជនបទរបស់រដ្ឋាភិបាល[១១៦] ។ឆ្នាំក្រោយមកមន្ត្រីបានប្រកាសពីការបង្កើតចំការកៅស៊ូថ្មី ។ តំបន់ដែលបានកំណត់មានទំហំ ៦,២០០ហិកតា ដែលបានកាត់ចេញពីសម្បទានឈើចំនួនបី - ក្រុមហ៊ុន Colexim Enterprise[១១៧] (៣,៥៧៧ ហិកតា), ក្រុមហ៊ុន GAT International (២,១៨១ ហិកតា) និងក្រុមហ៊ុន Mieng Ly Heng (៤៤២ ហិកតា) - នៅចំណុចប្រសព្វរបស់ពួកគេក្នុងឃុំទឹរីង ក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ ។ តំបន់នេះស្ថិតនៅចំកណ្តាលព្រៃឡង់ - ជាព្រៃឈើបៃតងទំនាបធំជាងគេបំផុតរបស់អាស៊ីអាគ្នេយ៍ដីគោក និងជាផ្នែកដ៏សំខាន់មួយនៃកេរ្តិ៍មរតកធម្មជាតិរបស់ប្រទេសកម្ពុជា[១១៨] ។



ឌី ចូច (ឆ្វេង) និង សេង គាង ភរិយារបស់គាត់ (ឆ្វេងកណ្តាល) ថតជាមួយ ហ៊ុន ម៉ាណា កូនស្រីរបស់ ហ៊ុន សែន និង ម៉ឹង កុម្ភៈ ស្វាមីរបស់គាត់ ដែលជាកូនប្រុសរបស់ឧត្តមសេនីយ៍ ម៉ឹង សំផន នៃកងយោធពលខេមរភូមិន្ទ

ដោយបានចុះហត្ថលេខាលើអនុក្រឹត្យបង្កើតចំការកៅស៊ូទីរីង ក្នុងខែ សីហា ឆ្នាំ ២០០១ ហ៊ុន សែន បានសម្ពោធគម្រោងនេះដោយផ្ទាល់នៅខែដូចគ្នានេះ[១៣៧] ។ ថ្លែងសុន្ទរកថាទៅកាន់ប្រជាជនមូលដ្ឋាន គាត់បានបានបរិយាយពីទស្សនៈរបស់គាត់ ស្តីពីទីរីងថ្មី :

"ប្រសិនបើអ្នកយកជ័រ សម្បទានឈើមិនសប្បាយចិត្តទេ ។ ហើយអ្នកមិនដឹងថា ពេលណាពួកគេនឹងកាប់ដើមឈើរបស់អ្នកនោះទេ ... អនុសាសន៍ដំបូង គឺថាយើងត្រូវការផ្លាស់ប្តូរប្រជាជននៅទីនេះពីការកសិករ និងអ្នកយកជ័រដោយឆ្លូត និងដុត ... ធ្វើឱ្យកន្លែងនេះឱ្យទៅជាកន្លែង ... ផ្លាស់ប្តូរពីការប្រមូលជ័រ ការយកជ័រ .. ពីការយកជ័រទៅជាការយកកៅស៊ូវិញ" ។

ហ៊ុន សែន បានសរុបដោយការធានាផ្ទាល់ខ្លួនថា :

"ប្រសិនបើ ហ៊ុន សែន និយាយអ្វី គាត់នឹងធ្វើ ។ ខ្ញុំមិនមកបោកប្រាស់អ្នក ខ្ញុំមិនមកបោកប្រាស់អ្នកនោះទេ ។ ហើយខ្ញុំមិនដឹងពីវិធីបោកប្រាស់ប្រជាជន ។ ខ្ញុំមិនដឹងពីវិធីបោកប្រាស់ប្រជាជននោះទេ ហ៊ុន សែន មិនដឹងពីវិធីបោកប្រាស់ប្រជាជននោះទេ ។ ហ៊ុន សែន សូមនិយាយដោយស្មោះ ។ នោះ គឺអញ្ចឹង ។[១៣៨] "

រដ្ឋាភិបាលបានប្រគល់ការគ្រប់គ្រងបរិវេណចំនួន ៦,២០០ ហិកតា ឱ្យទៅក្រុមហ៊ុនចំការកៅស៊ូជប់[១៣៩] ដែលជាក្រុមហ៊ុនរបស់រដ្ឋ ដែលគ្រប់គ្រងចំការកៅស៊ូដ៏ធំក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ដោយយោងតាមការិយាល័យស្នងការជាន់ខ្ពស់សិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានឱ្យដឹងថា "ចំការកៅស៊ូជប់ មានកំណត់ត្រាអន់ពីការអនុវត្តតាមសិទ្ធិមនុស្ស និងសិទ្ធិកម្មករ"[១៤០] ។ ក្នុងទីរីង ក្រុមហ៊ុនបានទទួលអំណាចឱ្យធ្វើផលិតកម្មកៅស៊ូ ទ្រង់ទ្រាយឧស្សាហកម្មលើដី ៤,៣៥៩ហិកតា ដោយ ១,៨៤១ហិកតា អាចទទួលបានសម្រាប់គ្រួសារក្នុងមូលដ្ឋាន ក្នុងមួយក្បាលដីបីហិកតា ។ មន្ត្រីបានជម្រុញឱ្យគ្រួសារដាំកៅស៊ូ ហើយអនុក្រឹត្យដែលបានចុះហត្ថលេខាដោយ ហ៊ុន សែន បានចែងថា ជប់ នឹងផ្តល់ឱ្យពួកគេនូវជំនួយបច្ចេកទេសពីប្រាំមួយឆ្នាំទៅដប់ឆ្នាំ ដែលដើមកៅស៊ូននឹងឈានទៅកាន់ដំណាក់-កាលចាស់[១៣៧] ។



ហ៊ុន សែន ចង្អុលបង្ហាញ

## ប្រអប់ ៥ : ការយកជ័រ

ជ័ររាវដែលយកចេញពី *ឈើទាល* និងពូជដើមឈើ ឪតេរ៉ូកាផ្សេងទៀត គឺជាអនុផលព្រៃឈើ ដែលបានប្រមូលផល និងធ្វើពាណិជ្ជកម្មយ៉ាងទូលំទូលាយបំផុតក្នុងប្រទេសកម្ពុជា ហើយជាប្រភពចំណូលសម្រាប់ប្រជាជនដ៏ពិបាកនឿយហត់ ១០០,០០០នាក់ នៅក្នុង និងជុំវិញតំបន់ព្រៃឈើ [១៣០] ។ ជ័រនេះ ត្រូវបានប្រើប្រាស់សម្រាប់ភ្លើងបំភ្លឺ បិទទូកកុំឱ្យជ្រាបទឹក និងសម្រាប់ធ្វើថ្នាំលាបពណិ និងថ្នាំលាបឱ្យរលោង [១៣១] ។

ការយកជ័រពាក់ព័ន្ធទៅនឹងការចោះប្រហោងមួយក្នុងដើមឈើចាស់ៗ ហើយបន្ទាប់មក ដុតស្មៅ ឬមែកឈើមួយក្តាប់តូចក្នុងប្រហោងនេះរៀងរាល់ពីរ-បីថ្ងៃ ដើម្បីជួយធ្វើឱ្យមានលំហូរជ័រ ។ រយៈពេលមួយឆ្នាំ អ្នកយកជ័រប្រមូលបានជ័រប្រមាណ ២០,០០០-តោន តាមវិធីនេះទូទាំងប្រទេសកម្ពុជា ។ ភស្តុតាងដែលអាចមានបង្ហាញថា ការយកជ័រមិនធ្វើឱ្យប៉ះពាល់ដល់ដើមឈើនោះទេ ដែលអាចបន្តយកជ័ររយៈពេលជាច្រើនទសវត្សរ៍[១៣០] ។

ស្របពេលដែលកសិកម្មជាទម្រង់សកម្មភាពសេដ្ឋកិច្ចខ្ពស់ជាងគេសម្រាប់ប្រជាជនកម្ពុជានៅជនបទ ភាគច្រើនបំផុត ការយកជ័រជាច្រើន ក៏ជាប្រភពចំណូលបន្ទាប់បន្សំដ៏សំខាន់មួយ ដើម្បីទិញស្រូវក្នុងពេលខ្វះខាតផងដែរ ។ ការស្រាវជ្រាវដែលបានធ្វើឡើងក្នុងឆ្នាំ ២០០៤ ក្នុងខេត្តព្រះវិហារ និងខេត្តកំពង់ធំ បានឱ្យដឹងថា គ្រួសារជាច្រើនទាញយកចំណូលរបស់ពួកគេស្ទើរតែមួយភាគបីពីការយកជ័រ [១៣២] ។

សកម្មភាពរបស់ក្រុមហ៊ុនកាប់ឈើ ផ្តល់ការគម្រាមកំហែងដោយផ្ទាល់ដល់ការចិញ្ចឹមជីវិតរបស់អ្នកយកជ័រ[១៣៣] ។ ដើមឈើដែលប្រជាជននៅជនបទយកជ័រ គឺជាប្រភេទពូជគុណភាពពាណិជ្ជកម្មដែលក្រុមហ៊ុនឈើយកសម្រាប់ប្រើប្រាស់ក្នុងផលិតកម្មក្តារបន្ទះ និងឈើស្តើងៗ ។ កំណត់ត្រាពីការប្រមូលផលរបស់សម្បទានិកឈើក្នុងអំឡុងពេលរដូវកាប់ឈើលើកចុងក្រោយ (២០០០-២០០១) មុនពេលរដ្ឋាភិបាលបានបញ្ឈប់ប្រតិបត្តិការរបស់ពួកគេបញ្ជាក់ពីបញ្ហានេះយ៉ាងច្បាស់ ។ ក្រុមហ៊ុនសម្បទានមួយបានបញ្ជាក់ថា ៨០% នៃការប្រមូលផលរបស់ខ្លួន រួមមាន ប្រភេទពូជឈើផលិតជ័រសំខាន់ៗជាច្រើន[១៣៤] ។ កំណត់ត្រាប្រមូលផលមួយផ្សេងទៀតបង្ហាញថា៨៩% នៃដើមឈើដែលខ្លួនកាប់ គឺជាប្រភេទពូជនេះ[១៣៥] ។

មាត្រា ១៧ (ឆ) នៃក្រឹត្យច្បាប់ឆ្នាំ ១៩៨៨ ស្តីពីវិធានអនុវត្តលើព្រៃឈើចែងថា ខុសច្បាប់ក្នុងការកាប់ដើមឈើ ដែលប្រជាជនកំពុងយកជ័រ ។ ច្បាប់នេះត្រូវបានគ្របដណ្តប់ដោយច្បាប់ព្រៃឈើឆ្នាំ ២០០២ មាត្រា ២៩ ដែលពង្រីកការការពារនេះទៅជា "ដើមឈើពូជដែលប្រជាជនយកជ័រ" ។ ទោះយ៉ាងណា ក្រុមហ៊ុនកាប់ឈើបានបំពានច្បាប់ទាំងនេះជានិច្ច ។ អ្នកយកជ័រដែលកំពុងរស់នៅក្នុង និងជុំវិញសម្បទានកាប់ឈើ ក្នុងខេត្តមណ្ឌលគីរី បានរាយការណ៍ពីការបាត់បង់ដើមឈើរបស់ពួកគេប្រមាណ ២០-៣០% ទៅឱ្យប្រតិបត្តិការប្រមូលផលរបស់ក្រុមហ៊ុន[១៣៦] ។ ផលប៉ះពាល់នៃគម្រោងដាំដើមកៅស៊ូទីរីងទៅលើគ្រួសារក្នុងព្រៃឡង់កាន់តែធ្ងន់ធ្ងរឡើងៗ ។



**អ្នកយកជ័រក្នុងព្រៃឈើព្រៃឡង់** (រូបភាពរបស់ Andrew McDonald)



**ឈើទាល - ដើមឈើយកជ័រ**

## ប្រអប់ ៦ : ព្រៃឡង់នៅផ្លូវបំបែក

ការកាប់ឈើទ្រង់ទ្រាយឧស្សាហកម្មក្នុងតំបន់ត្រូពិកជាធម្មតាមានគោលដៅលើព្រៃឈើទំនាប ជាជាងតំបន់ខ្ពង់រាប ដោយសារតំបន់នេះមានការងាយស្រួលចេញចូល និងនាំមកនូវបរិមាណឈើខ្ពស់ជាង ។ ផលវិបាករបស់អាស៊ីអាគ្នេយ៍ គឺការបាត់បង់ ឬការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់ព្រៃឈើប្រភេទនេះ [១១៩] ។

ទេសភាពព្រៃឡង់ក្នុងភាគខាងជើងប្រទេសកម្ពុជា គឺជាតំបន់ដែលនៅជិតគ្នាធំបំផុតទៅនឹងព្រៃឈើបៃតង និងពាក់កណ្ដាលបៃតង ដែលនៅមានសល់នៅក្នុងអាស៊ីអគ្នេយ៍ដីគោក ។ ដោយមានទីតាំងនៅភាគខាងលិចទន្លេមេគង្គ ព្រៃនេះគ្របដណ្ដប់ផ្ទៃដីប្រមាណជា ៥២៥០ គីឡូម៉ែត្រការ៉េ [១២០] ។

សារៈសំខាន់របស់ព្រៃឡង់ គឺត្រូវបានបង្ហាញក្នុងការសិក្សាជាច្រើនពីការគ្រប់គ្រងព្រៃឈើក្នុងប្រទេសកម្ពុជា យ៉ាងហោចណាស់មានក្នុងរបាយការណ៍ក្រុមអធិការកិច្ចរបស់ធនាគារពិភពលោក ឆ្នាំ ២០០៦ និងការត្រួតពិនិត្យវិស័យព្រៃឈើដោយឯករាជ្យ ឆ្នាំ ២០០៤ ។ ព្រៃឡង់ ក៏ត្រូវបានបញ្ចូលក្នុងបញ្ជីតំបន់បណ្ដោះ-អាសន្ន ដែលបានស្នើសម្រាប់ស្ថានភាពជាកេរ្តិ៍មរតកពិភពលោករបស់យូណេស្កូផងដែរ [១២១] ។ ទោះយ៉ាងណាក៏ដោយ នាពេលបច្ចុប្បន្ននេះ ព្រៃឡង់មិនស្ថិតក្រោមប្រភេទនៃរបបគ្រប់គ្រងការពារណាមួយឡើយ ។

ការអង្កេតស្រាវជ្រាវដែលបានធ្វើឡើងទៅលើតំបន់ព្រៃឡង់ បង្ហាញថា កេរ្តិ៍មរតកធម្មជាតិផ្សេងៗ និងពិសេសមួយនេះ កំពុងស្ថិតក្នុងការប្រថុយគ្រោះថ្នាក់ និងត្រូវការការថែរក្សា ។ ការស្រាវជ្រាវឆ្នាំ ២០០៤ បានរកឃើញប្រភេទព្រៃឈើផ្សេងៗប្រាំពីរ ដែលរួមមានព្រៃឈើបៃតងដែលរីកលូតលាស់លើកដំបូងដោយកម្រ និងព្រៃឈើវាលភក់បៃតង[១២២] ។ ព្រៃឡង់ ក៏ជាកន្លែងរស់នៅរបស់ប្រភេទពូជសត្វព្រៃកម្រ ដូចជា ដំរី គោព្រៃ (gaur) គោព្រៃ (banteng) ខ្លា និងខ្លាឃ្មុំខ្មៅអាស៊ី [១២៣] ។

ព្រៃឡង់មានសារៈសំខាន់ខ្លាំងណាស់ដល់ការរស់នៅរបស់ប្រជាជនប្រមាណ ២៥៦,០០០នាក់ ដែលកំពុងរស់នៅក្នុង ៣៤០ភូមិក្នុង និងជុំវិញព្រៃឈើ ។ សម្រាប់សហគមន៍ទាំងនេះ ព្រៃឈើផ្ដល់ឱ្យការចិញ្ចឹមជីវិតមិនត្រឹមតែតាមរយៈការយកជ័រប៉ុណ្ណោះទេ ថែមទាំងតាមរយៈការផ្ដល់ជាសម្ភារៈសំណង់ ឱសថ និងអាហារផងដែរ[១២០] ។ ព្រៃឈើក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរក្នុងផ្នែកវប្បធម៌ ដោយសារមានដំបូក និងដើមឈើដែលមានព្រលឹងជាច្រើន ដែលមានសារៈសំខាន់ ជាពិសេសសម្រាប់ក្រុមជនជាតិភាគតិច ដូចជា គួយជាដើម[១២៤] ។ ជាងនេះទៅទៀត ព្រៃឈើដូចជាព្រៃឡង់ ផ្ដល់ឱ្យនូវការជួយគ្រប់គ្រងការបែងចែកទឹកដ៏សំខាន់ដល់ប្រជាជនជនបទរបស់ប្រទេសកម្ពុជាទាំងមូលគួរឱ្យកត់សំគាល់ គឺតាមរយៈការគ្រប់គ្រងលំហូរទឹករបស់ព្រៃឈើទៅឱ្យតំបន់កសិកម្ម[១២៥] ។

ព្រៃឡង់ គឺស្ថិតនៅចំកណ្ដាលសកម្មភាពសម្បទានឈើក្នុងទសវត្សរ៍កន្លងមក[១២០] ។ ទោះបីជាមានការខកខានរបស់សម្បទានិករបស់ប្រទេសកម្ពុជាទាំងអស់ ក្នុងការបំពេញតាមតម្រូវការបង្កើតផែនការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមបានគ្រប់គ្រាន់ ក៏សម្បទានឈើចំនួនបួន ដែលគ្របដណ្ដប់លើព្រៃឡង់ជាច្រើននៅតែបន្តមាន[១២៤] ។

ស្របពេលដែលសម្បទានទាំងនេះ បានអសកម្មភាពដ៏ធំចាប់ពីការបញ្ឈប់ឆ្នាំ ២០០២ ទៅលើប្រតិបត្តិការរបស់ខ្លួន ការកាប់ឈើទ្រង់ទ្រាយឧស្សាហកម្មក្នុងព្រៃឡង់ បានបន្តតាមរយៈចំការកៅស៊ូទីរីង ដែលបានបង្ហាញក្នុងជំពូកនេះ ។ ក្នុងឆ្នាំ ២០០៦ រដ្ឋាភិបាលបានផ្ដល់យ៉ាងហោចណាស់សម្បទានដីសេដ្ឋកិច្ចថ្មីមួយក្នុងព្រៃឡង់ ហើយនាពេលបច្ចុប្បន្ននេះ មន្ត្រីកំពុងរៀបចំផែនការ ដើម្បីកែប្រែចំការកៅស៊ូរាប់ម៉ឺនហិកតាឱ្យកាន់តែច្រើនជាងនេះទៀត[១២៦] ។



មើលពីប៉ែកខាងកើតព្រៃឈើព្រៃឡង់ទៅកាន់ទន្លេមេគង្គ

ស្របពេលដែលផលចំណេញសេដ្ឋកិច្ចរយៈពេលខ្លីនៃការកាប់ឈើកាន់តែច្រើននៅព្រៃឡង់ ស្ថិតក្នុងភាពគ្មានការសង្ស័យក្នុងការទាក់ទាញមន្ត្រីកម្ពុជា ចំណាយផ្នែកជីវចម្រុះ ការចិញ្ចឹមជីវិត និងការគ្រប់គ្រងជម្រាលទឹកនឹងមានធ្ងន់ធ្ងរ [១២៧] ។ជាងនេះទៅទៀត ការបញ្ចូលការវាយតម្លៃយ៉ាងហ្មត់ចត់លើសេដ្ឋកិច្ចនៃការផ្លាស់ប្តូរបរិយាកាសនាពេលថ្មីៗនេះ ដែលការព្យាយាមយ៉ាងខ្លាំង ដើម្បីដោះស្រាយការផ្លាស់ប្តូរបរិយាកាស ត្រូវតែបញ្ចូលការទប់ស្កាត់ការបំផ្លិចបំផ្លាញព្រៃធម្មជាតិដែលមានស្រាប់ សង្កត់ធ្ងន់ទៅលើករណីបញ្ចុះបញ្ចូលដែលមានរួចហើយឱ្យមានវិធានការណ៍អន្តរជាតិរួមគ្នាដើម្បីថែរក្សាព្រៃឡង់និងទេសភាពព្រៃឈើដែលនៅសេសសល់ផ្សេងទៀតរបស់ប្រទេសកម្ពុជា [១២៨] ។

ដំណើរការនេះ ត្រូវបានធ្វើឡើងយ៉ាងរហ័សតាមរយៈការអង្កេតស្រាវជ្រាវដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ ក្នុងខែវិច្ឆិកា ឆ្នាំ ២000 ។ ក្រុមការងារអង្កេតស្រាវជ្រាវនេះ បានចាត់ថ្នាក់តំបន់ទីរឹង ជាដីដែលមានចំនួនព្រៃឈើមានតម្លៃតិចតួចប៉ុណ្ណោះ នៅពេលដែលតាមការពិតភាគច្រើននៃផ្ទៃដី ៦,២00ហិកតា ត្រូវបានគ្របដណ្តប់ដោយព្រៃឈើ [១២៩] ។



ទីតាំងព្រៃឡង់ ប្រទេសកម្ពុជា

រដ្ឋាភិបាលបានបង្កើតចំការ មិនដូចជាសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់ឱ្យក្រុមហ៊ុនឯកជននោះទេ តែជាគម្រោងអភិវឌ្ឍន៍ដឹកនាំដោយរដ្ឋដែលចែងដោយអនុក្រឹត្យ ។ អនុក្រឹត្យ គឺជាឧបករណ៏ច្បាប់ចងភ្ជាប់ ដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី តែមិនមែនជាកម្មវត្ថុអនុម័តដោយរដ្ឋសភាជាតិរបស់ប្រទេសកម្ពុជានោះទេ ។ អនុក្រឹត្យស្តីពីការប្រើប្រាស់ផ្ទៃដីរដ្ឋជាក់លាក់មានលក្ខណៈមិនធម្មតាឡើយ ទោះបីជាមិនធ្លាប់មានពីមុនមកក៏ដោយ ។ ការចេញអនុក្រឹត្យមួយផ្តោតជាពិសេសទៅលើទីរឹងបានបង្ហាញពីសារៈសំខាន់ ដែលនាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ផ្សេងទៀត ដែលពាក់ព័ន្ធនឹងគម្រោងនេះ ។



ព្រៃឡង់ ប្រទេសកម្ពុជា


វាលព្រៃបៃតងដ៏កម្រក្នុងព្រៃឡង់

### ៣.២ "អត្ថប្រយោជន៍នៃការផ្លាស់ប្តូរ"

ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងសុន្ទរកថាក្នុងសភាជាតិ ឆ្នាំ ២០០២ ថា "*ប្រសិនបើតំបន់នេះ [ទីរីង] អាចចូលរួមក្នុងសេដ្ឋកិច្ចជាតិ ហើយទោះយ៉ាងណា ព្រៃឈើគង់តែនឹងបាត់បង់ ហេតុអ្វីបានយើងត្រូវទុក ? យើងត្រូវផ្លាស់ប្តូរជាបន្ទាន់ទៅកាន់ការប្រើប្រាស់នេះ [កៅស៊ូ] ដែលមានប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់ ។ នេះ គឺជាអត្ថប្រយោជន៍នៃការផ្លាស់ប្តូរ*" ។

មកទល់ថ្ងៃនេះ ទីរីងមិនទាន់បង្កើតបានកៅស៊ូណាមួយនៅឡើយទេ ទោះយ៉ាងណាក៏ដោយ ទីរីងបាននាំប្រយោជន៍ឈើជាច្រើនតាមរយៈការកាប់ឈូសសំអាតព្រៃឈើរាប់ពានហិកតា ។ វលកដំបូងនៃការកាប់ឈើក្នុងខែក្រោយៗបន្ទាប់ពីការសម្ពោធចំការ ត្រូវបានធ្វើឡើងដោយសម្បទានិកក្រុមហ៊ុន GAT ក្រុមហ៊ុន Colexim និងក្រុមហ៊ុន Mieng Ly Heng ។ ដូចដែលបានបង្ហាញរួចមកហើយ សេង គាង និង ឌី ចូច មានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយក្រុមហ៊ុន Mieng Ly Heng ដែលអាចពង្រីកទៅជាកម្មសិទ្ធិពិតប្រាកដមួយ ។ ដោយការអនុវត្តដែលគ្មាននរណាគ្រប់គ្រងលើច្បាប់ ក្រុមហ៊ុនទាំងបីបានកាប់រំលំដើមច្បោះជាច្រើនពាន់ដើមដែលជារបស់គ្រួសារក្នុងមូលដ្ឋាន[១៤១] ។

ក្នុងខែ ឧសភា ឆ្នាំ ២០០២ រដ្ឋាភិបាលបានដាក់ឱ្យដូចដើមវិញនូវការបញ្ឈប់ការដឹកជញ្ជូនឈើ ។ខែក្រោយមករដ្ឋាភិបាលបានលុបចោលសម្បទានឈើពីរ ដែលធ្វើឡើងដោយក្រុមហ៊ុនGAT International ។ ចាប់ពីពេលនេះទៅ ឌី ចូច, សេង គាង និង យុន ថុង បានទទួលខុសត្រូវតែឯងលើការកាប់ឈើក្នុងទីរីង ។នៅអំឡុងពេលដូចគ្នានេះ ពួកគេចាប់ផ្តើមធ្វើការដោយស្ថិតក្រោមឈ្មោះ ក្រុមហ៊ុន Seng Keang Import Export Company[១៤២] ។

ក្នុងខែតុលា ឆ្នាំ២០០២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរបស់ ចាន់ សារុន បានចេញលិខិតមួយប្រគល់ "ការអនុញ្ញាតជាគោលការណ៍ឱ្យប្រមូលឈើគ្រប់ប្រភេទទាំងអស់ក្នុងចំការកៅស៊ូទីរីង ខេត្តកំពង់ធំ" ឱ្យក្រុមហ៊ុនSeng Keang Import Export Co.,Ltd.[១៤៣] ។ តាមចំណេះដឹងប្រសើរបំផុតរបស់ Global Witness សេចក្តីសម្រេចរបស់ក្រសួងមិនបានអនុវត្តតាមដំណើរការដេញថ្លៃជាចំហ និងមិនបានប្រកាសជាសាធារណៈនោះទេ ។ ការខ្វះខាតតម្លាភាពនេះ ផ្តល់ឱ្យនូវការរាំងបន្តិចតួចប៉ុណ្ណោះឱ្យវិស័យសាធារណៈកម្ពុជា ដែលដឹងរួចជាស្រេចហើយថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថាមានអំពើពុករលួយយ៉ាងខ្លាំង[១៤៤] ។ ក្នុងលិខិតមួយទៅកាន់ឧបនាយករដ្ឋមន្ត្រី សុខ អាន ក្នុងខែ មិនា ឆ្នាំ ២០០៦ ចាន់ សារុន បានពន្យល់ពីសេចក្តីសម្រេចរបស់គាត់ក្នុងប្រការដូចខាងក្រោមនេះ :

"ព្រៃឈើត្រូពិករបស់ប្រទេសកម្ពុជា តែងតែមានប្រភេទដើមឈើផ្សេងៗ : ឈើប្រណិត ឈើកម្រិតលេខមួយ ឈើកម្រិតលេខពីរ ឈើកម្រិតលេខបី និងប្រភេទឈើផ្សេងទៀត ។ នៅពេលដែលមានការឈូសសំអាតព្រៃឈើ ជាការសំខាន់ប្រមូលដើមឈើទាំងនេះសម្រាប់វាស់វែង បង់ពន្ធ និងប្រើប្រាស់ធនធានឈើក្រៅពីការដុតដែលបណ្តាលឱ្យបាត់បង់ថវិកាជាតិ និងប៉ះពាល់បរិស្ថានធម្មជាតិ" ។

ការបារម្ភរបស់ ចាន់ សារុន ដើម្បីចៀសវាងការចំណាយឈើរបស់ទីរីងឥតប្រយោជន៍ គឺអាចនិយាយបានយ៉ាងល្អ តែកើតឡើងប្លែកពីការជជែកវែកញែកដែលគាត់ធ្វើនៅកន្លែងផ្សេងទៀត នូវលិខិតតែមួយថា "មុនពេលចេញអនុក្រឹត្យបង្កើតចំការកៅស៊ូទីរីង យើងបានបង្កើតគណៈកម្មការ ដើម្បីធ្វើការស្រាវជ្រាវជាមុនរួចជាស្រេចលទ្ធផលពីការសិក្សានេះបានបង្ហាញថា មានចំនួនឈើមានតម្លៃតិចតួចប៉ុណ្ណោះក្នុងតំបន់នេះ ។[១៤៥]"

សេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីចំពោះទីរីង គឺមានការផ្ទុយខ្លាំងបំផុត ដែលធ្វើឱ្យយល់ខុសដោយចេតនាអាក្រក់បំផុត ។ នៅខែ តុលា ឆ្នាំ ២០០២ ឌី ចូច, សេង គាង និង យុន ថុង មានកំណត់ត្រាតាមដានពីការបំពានកាលពីប៉ុន្មានឆ្នាំមុន ។ សេចក្តីសម្រេចរបស់ ចាន់ សារុន ផ្តល់ឱ្យអ្នកទាំងបីនូវលិខិតអនុញ្ញាតផ្តល់ការរាំងបន្តការកាប់ឈើខុសច្បាប់របស់ពួកគេ ធ្វើឱ្យគាត់បំពានលើមាត្រា ១០០ នៃច្បាប់ព្រៃឈើរបស់ប្រទេសកម្ពុជា ដែលចែងថា "សកម្មភាពណាមួយ ដែលអនុវត្តដោយមន្ត្រីអាជ្ញាធរមូលដ្ឋាន នាយប៉ូលីស កងយោធពលខេមរភូមិន្ទ ឬអាជ្ញាធរផ្សេងទៀត ដែលអនុញ្ញាតដោយផ្ទាល់ ឬដោយប្រយោលឱ្យមានការធ្វើអាជីវកម្មព្រៃឈើ ឬសកម្មភាពផ្សេងទៀតផ្ទុយនឹង ខ ចែងនៃច្បាប់នេះ ... នឹងត្រូវជាប់ពន្ធនាគារពីមួយទៅប្រាំឆ្នាំ និងពិន័យដប់លានរៀល ទៅមួយរយលានរៀល [US$២,៥០០ ទៅ US$២៥,០០០]" ។សកម្មភាពរបស់រដ្ឋមន្ត្រី ក៏មានតម្លៃដូចគ្នាដូចកំណត់ដោយក្រុមព្រហ្មទណ្ឌអ៊ុនតាក់ (អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា) ផងដែរ ។ មកទល់ថ្ងៃនេះ អាជ្ញាធរយុត្តិធម៌របស់ប្រទេសកម្ពុជា មិនបានស៊ើបអង្កេតសកម្មភាពរបស់រដ្ឋមន្ត្រីចំពោះទីរីងនោះទេ



**អ្នកកាប់ឈើមកពីក្រុមហ៊ុន GAT International បង្កើតវលកឈូសសំអាតព្រៃឈើដំបូងក្នុងទីរីង**



សេង កុកហ៊ាង តំណាងក្រុមហ៊ុនរបស់ សេង គាង ក្នុងទីរីង និងអ្នកយាមរបស់ក្រុមហ៊ុន

ទោះយ៉ាងណាក៏ដោយ Global Witness ជឿជាក់ថាមានមូលដ្ឋានបញ្ចុះបញ្ចូលឱ្យធ្វើដូច្នេះ ។

សរុបមកពេលដែលសម្បទានិកឈើរបស់ប្រទេសកម្ពុជាប្រឈមមុខនឹងរយៈពេលសម្ងំស្ងៀមដោយបង្ខំ ដែលឥឡូវនេះមានរយៈពេលជាងប្រាំឆ្នាំមកហើយនោះ ឌី ចូច, សេង គាង និង ឃុន ថុង បានធានាក្នុងការទទួលបានភ្លាមនូវរោងចក្រកែច្នៃឈើធំបំផុតមួយក្នុងចំណោមរោងចក្រជាច្រើនរបស់ប្រទេស ហើយនិងជាប្រភពថ្មីមួយដែលផ្គត់ផ្គង់រោងចក្រផងដែរ ។

### ៣.៣ ការលាងឈើកខ្វក់

សេង គាង, ឌី ចូច និង ឃុន ថុង បានតែងតាំងជាអ្នកតំណាងរបស់ពួកគេក្នុងទីរីង គឺ សេង កុកហ៊ាង ប្អូនប្រុសរបស់ សេង គាង ដែលជាមន្ត្រីម្នាក់ក្នុងកងពលតូចលេខ ៧០ របស់កងយោធពលខេមរភូមិន្ទដ៏មានឥទ្ធិពល[១៤៦] ។

សេងកុកហ៊ាងត្រូវបានស្គាល់ថាជា "តាកៅប្រាំ" ឬលោក៩៥-៩៥ គឺជាលេខរបស់គាត់ក្នុងលំដាប់លេខវិទ្យុទាក់ទង ដែលប្រើប្រាស់ដោយកូនចៅរបស់គាត់ ។ សេង កុកហ៊ាង ពីមុនធ្លាប់ធ្វើការឱ្យក្រុមហ៊ុន Mieng Ly Heng ហើយបានធ្វើការផ្លាស់ប្តូរដោយគ្មានកំហុសពីការកាប់ឈើបែបការគ្រប់គ្រងសម្បទានព្រៃឈើ ទៅជាការកាប់ឈើបែបការអភិវឌ្ឍន៍ចំការវិញ[១៤៧] ។

ដោយមានកាតព្វកិច្ចផ្គត់ផ្គង់ដល់រោងចក្រក្រុមហ៊ុន Kingwood សេង កុកហ៊ាង បានបង្ហាញខ្លួនគាត់យ៉ាងឆាប់រហ័ស ដោយមិនត្រូវបានរារាំងដោយបរិវេណតំបន់ទីរីង ដែលមានកម្រិតក្រីក្រនោះឡើយ[១៤៨] ។ ក្នុងអំឡុងពេលស៊ើបអង្កេតដល់កន្លែងក្នុងខែកញ្ញានិងតុលាឆ្នាំ២០០៣ Global Witness បានរកឃើញអ្នកកាប់ឈើកំពុងកាប់ប្រហែលជាងកន្លះគីឡូម៉ែត្រខាងក្រៅព្រំប្រទល់ចំការ ។ដោយបរិយាយពីការពង្រីកប្រតិបត្តិការចំការខុសច្បាប់នេះ អ្នកតំណាងប្រចាំការរបស់ក្រុមហ៊ុន



ឈើដែលបានចាត់ប្រភេទថាជា "អុស" ក្នុងទីរីង ឆ្នាំ ២០០២

ចំការកៅស៊ូជប់ បានរៀបរាប់ថា "ខ្ញុំមិនដឹង ... ម៉្យាងវិញទៀត ខ្ញុំមិនត្រូវបានឱ្យដឹងការងារច្រើនណាស់ណានោះទេ"[១៤៩] ។

ការកាប់ឈើនៅក្នុងព្រំប្រទល់ចំការរបស់ សេង កុកហ៊ាង ពាក់ព័ន្ធនឹងការដកចេញគម្របព្រៃឈើទាំងអស់ ។ ទោះយ៉ាងណាក៏ដោយ ការកាប់ឈើនៅក្រៅបរិវេណ ផ្តោតទៅលើចំនួនមុខចូលសមរម្យបំផុតសម្រាប់រោងចក្រក្តារបន្ទះក្រុមហ៊ុន Kingwood : *ឈើទាល* (ឈើយកជ័រ) *ផ្ចឿក* និងប្រភេទពូជកម្រិតពាណិជ្ជកម្មផ្សេងទៀត ។ ដោយបានកាប់រំលំដើមឈើក្រុមរបស់ សេង កុកហ៊ាង បន្ទាប់មកបានយកឈើចូលក្នុងព្រំប្រទល់ចំការ ដែលពួកគេអាចបង្ហាញថា ជាផលិតផលរបស់ដំណើរការផ្ទេរដីដែលបានទទួលការអនុញ្ញាត[១៤៨] ។ រូបមន្តរបស់ទីរីង-ការឈូសសំអាត-កាប់រំលំព្រៃឈើមានតម្លៃ ដែលបានយល់ព្រមស្របច្បាប់ - ផ្តល់ឱ្យនូវទំហំសម្រាប់ការលាងឈើកាប់ខុសច្បាប់ដោយមិនកំណត់ ។

### ៣.៤ ការប្រមូលអុស

ជាមួយគម្រោងដាំដើមកៅស៊ូដែលផ្តល់ការគាំទ្រនយោបាយពីកម្រិតខ្ពស់បំផុត ក្រុមកាប់ឈើអាចលួចដោយខុសច្បាប់នូវដើមច្បោះ និងដើមឈើរបស់អ្នកភូមិដែលនៅខាងក្រៅព្រំប្រទល់ចំការដោយគ្មានទោសពៃរ៍ ។ ទោះយ៉ាងណាក៏ដោយ ក្នុងបរិបទនៃការបញ្ឈប់ការដឹកឈើថ្នាក់ជាតិ ក្រុមនេះបានប្រើប្រាស់វិធីសាស្ត្រប្រយ័ត្នប្រយែងកាន់តែខ្លាំងឡើងចំពោះការយកឈើទៅកាន់រោងចក្រក្រុមហ៊ុន Kingwood ។ ការស៊ើបអង្កេតដោយបុគ្គលិក Global Witness ក្នុងខែ មករា ឆ្នាំ ២០០៣ បានបង្ហាញថា ការផ្គត់ផ្គង់ឈើរបស់រោងចក្រមកពីទីរីងតែក្រោយពីមេឃងងឹតប៉ុណ្ណោះ ជាមធ្យមពី៦-៧ឡានក្នុងមួយយប់[១៤៨] ។ ស្របពេលនេះ ក៏សូមអរគុណដល់លិខិតអនុញ្ញាតបន្លំ ដែលផ្តល់ដោយរដ្ឋបាលព្រៃឈើ ការដឹកកំណាត់ឈើប្រវែងពីរម៉ែត្រចំនួន៦០ ម៣ ដោយក្លែងលក្ខណៈខាងក្រៅថាជា "អុស"[១៥០] ។ក្នុងការបង្ហាញរបស់ការិយាល័យស្នងការជាន់ខ្ពស់សិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានឱ្យដឹងថា :

"អ្នកតំណាងពិសេសឱ្យអ្នកតំណាងពិសេសសិទ្ធិមនុស្សរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជា Peter Leuprecht បានទៅកាន់ឃុំទីរីង ក្នុងខែ កក្កដា ឆ្នាំ ២០០៣... នៅពេលជួបជាមួយមន្ត្រីរដ្ឋបាលព្រៃឈើក្នុងមូលដ្ឋាន គាត់បានធ្វើសាក្សីដោយផ្ទាល់ខ្លួនពីការដឹកជញ្ជូនដើមឈើធំៗប្រាំឡាន ដែលរួមមានទាំងឈើយកជ័រផងដែរ ។ នៅពេលដែលគាត់បានសួរពីបញ្ហានេះ គាត់ត្រូវបានបង្ហាញនូវលិខិតអនុញ្ញាតដឹកអុស ។"[១៤០]

លិខិតអនុញ្ញាតដឹកអុស បានផ្តល់ឱ្យមិនត្រឹមតែលេសដឹកឈើជាឯកសារប៉ុណ្ណោះទេ ថែមទាំងសមត្ថភាពសម្រាប់ការលួចពន្ធផងដែរ ។ ស្របពេលដែលអត្រាសួយសារសម្រាប់ *ឈើទាល* កម្រិតលេខពីរ និង *ឈើផ្ចឿក* ដែលបានដឹកចេញពីទីរីងមានចំនួន US$៥៤ ក្នុងមួយម៉ែត្រគូប អត្រាសម្រាប់អុសគឺត្រឹមតែ US$ ១ ប៉ុណ្ណោះ ។ ដោយផ្អែកតាមដំណើររឿងពីបុគ្គលិកក្នុងខេត្តកំពង់ធំ និងការស៊ើបអង្កេតរបស់Global-Witness លើឡានដែលទៅដល់រោងចក្រក្រុមហ៊ុន Kingwood ក្នុងឆ្នាំ២០០៣បង្ហាញថាក្រុមហ៊ុន Seng Keang Company បានដឹកជញ្ជូនឈើកម្រិតលេខពីរតិចបំផុត ២០,០០០ម៣ ចេញពីទីរីងក្នុងឆ្នាំនោះតែមួយឆ្នាំគត់[១៥១] ។នេះបង្ហាញថាក្នុងឆ្នាំ២០០៣ ក្រុមហ៊ុនគួរតែបានផ្តល់ឱ្យយ៉ាងហោចណាស់ សួយសារចំនួន US$១,០០០,០០០ ដល់រតនាគារ



ការកែច្នៃដើមឈើជា "អុស"



អុសកំពុងដឹកជញ្ជូន

ប្រទេសកម្ពុជា ។ ទោះយ៉ាងណាក៏ដោយ ក្នុងឆ្នាំ ២០០៦ ចាន់ សារុន បានបញ្ជាក់ថា ក្នុងរយៈពេលបីឆ្នាំនេះ ក្រុមហ៊ុន Seng Keang Company បានបង់ឱ្យរដ្ឋាភិបាលនូវសួយសារឈើសរុបតិចជាង US$៦០០,០០០ ។ ចម្ងល់ពីពន្ធចំនួនប៉ុន្មានដែលក្រុមកាប់ឈើ គួរតែបានបង់ ត្រូវបានពិនិត្យកាន់តែលំអិតក្នុងផ្នែក ៤.៦[១៤៩] ។

ដោយផ្តល់យោបល់ទៅលើការកាប់ឈើជុំវិញទីរឹងក្នុងខែ កញ្ញា ឆ្នាំ ២០០៣ មន្ត្រីម្នាក់នៅក្នុងមន្ទីររុក្ខាប្រមាញ់ខេត្តកំពង់ចំបានបញ្ជាក់ថា "ក្រសួងកសិកម្មបានផ្តល់អាជ្ញាប័ណ្ណឱ្យអ្នកស្រី សេង គាង ប្រមូលកំណាត់ឈើសម្រាប់ធ្វើអុសតាំងពីចុង ឆ្នាំ២០០២ មកម្ល៉េះ"[១៥០] ។ស្រប ពេលនេះដែរ ទី សុគន្ធ ប្រធានរដ្ឋបាលព្រៃឈើដែលជាកូនប្រសាររបស់ ឃុន ថុង បានប្រកាសថា "គ្មានការដឹកឈើទៀតទេ ។ ប្រជាជនមួយចំនួនប្រើប្រាស់ឈើជាអុស ។ ប្រសិនបើមានកំណាត់ឈើនៅខាងក្រៅចំការ យើងនឹងចាត់វិធានការណ៍បំបាត់ ។ គ្មានការធ្វើអាជីវកម្មឈើទៀតទេ ។ អាចមានការឈូសសំអាតសម្រាប់ធ្វើស្រែ ។" គាត់បានបដិសេធថាធ្លាប់ស្គាល់ សេង គាង និង ឌី ចូច[១៥១] ។

ដោយសរសេរលិខិតមួយទៅកាន់ក្រុមការងារគ្រប់គ្រងធនធានធម្មជាតិ ដែលជាម្ចាស់ជំនួយអន្តរជាតិនៅក្នុងខែតែមួយនេះ ចាន់ សារុន ជាប្អូនថ្លៃរបស់ ឃុន ថុង បានអះអាងថា "មកទល់ថ្ងៃនេះ ចំពោះការដឹកជញ្ជូនឈើដែលបាននិយាយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តអនុវត្តការបញ្ឈប់បម្រាមធ្វើអាជីវកម្ម និងការដឹកជញ្ជូនឈើឱ្យមានប្រសិទ្ធិភាព" [១៥២] ។ បុគ្គលិករបស់ សេង គាង បានជូនដំណឹងដល់ដៃគូអាជីវកម្មក្នុងឆ្នាំ ២០០៤ ថា ក្រុមនេះកំពុងបន្តទទួលបានលិខិតអនុញ្ញាតដឹកអុសពីរដ្ឋបាលព្រៃឈើ [១៥៣] ។

### ៣.៥ អត្ថប្រយោជន៍បន្ថែមទៀត

ក្នុងខែ កញ្ញា ឆ្នាំ២០០៤ ប៉ុន្មានសប្តាហ៍បន្ទាប់ពីការបង្កើតរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនថ្មីមួយ ហើយនិងការតែងតាំងជាថ្មីរបស់គាត់ជារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាន់ សារុន បានចេញ*ប្រកាស*មួយផ្តល់សិទ្ធិឱ្យក្រុមហ៊ុន Seng Keang Company បង្កើតរោងចក្រនៅក្នុងភូមិខែស័ក្នុងទម្រង់សម្រាប់ធ្វើរោងចក្រឈើ និងក្តារបន្ទះ[១៥៤] ។*ប្រកាស*នេះផ្ទុយនឹងអនុក្រឹត្យឆ្នាំ១៩៩៩ស្តីពីវិធានការណ៍រឹតបន្តឹងវិស័យវិនិយោគ ដែលហាមប្រាមការវិនិយោគបន្ថែមក្នុងការកែច្នៃឈើមូល[១៥៥] ។*ប្រកាស*ក៏បានបំពានផងដែរ ទៅលើច្បាប់ព្រៃឈើ ឆ្នាំ ២០០២ មាត្រា ៣០ ដែលចែងថា គ្មានរោងចក្រកែច្នៃណាមួយ អាចត្រូវបានបង្កើតឡើងក្នុងចម្ងាយប្រាំគីឡូម៉ែត្រពីព្រៃបម្រុងអចិន្ត្រៃយ៍បានឡើយ ។ ច្បាប់ព្រៃឈើក៏ចែងបន្ថែមថា "ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចផ្តល់ឱ្យការលើកលែងចំពោះការហាមប្រាម (ទាំងនេះ) ប្រសិនបើការសិក្សាដោយរដ្ឋបាលព្រៃឈើអាចបង្ហាញថា គុណប្រយោជន៍ពីការលើកលែងនេះនឹងមិនបណ្តាលខូចខាតឬមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមកម្រិតតូច" ។ ប្រកាសរបស់ ចាន់ សារុន មិនបានធ្វើការសំអាងណាមួយលើការសិក្សាបែបនេះ ហើយមន្ត្រីរដ្ឋបាលព្រៃឈើដែលមានមូលដ្ឋាននៅទីរឹង បានជូនដំណឹងដល់Global Witness ក្នុងឆ្នាំ ២០០៥ ថា គ្មានការសិក្សាណាមួយត្រូវបានធ្វើឡើងឡើយ[១៥៦] ។

ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចជឿជាក់បាន និងច្បាស់លាស់បង្ហាញពីការកាប់ឈើបំផ្លិចបំផ្លាញ និងខុសច្បាប់ ដោយក្រុមហ៊ុន Seng Keang Company ។ ទោះយ៉ាងណាក៏ដោយ ត្រឹមពាក់កណ្តាលឆ្នាំ២០០៤ ទីរឹងបានទាក់ទាញចំណាប់អារម្មណ៍រួចទៅហើយ ចំពោះការបំផ្លាញបរិស្ថាន ការបាត់បង់ចំណូលគ្រួសារ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ និងការបំភិតបំភ័យ ដែលកំពុងត្រូវបានធ្វើទៅលើប្រជាជនរបស់ខ្លួន ។ Global Witness អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ និងអ្នកកាសែត មិនរាប់បញ្ចូលអ្នកស្រុកក្នុងមូលដ្ឋានខ្លួនឯងផង បានបង្ហាញដល់អាជ្ញាធរនូវភស្តុតាងយ៉ាងច្រើនពីអ្វីដែលកំពុងកើតឡើង[១៥៧] ។ ដោយសន្មតថា ចាន់ សារុន កំពុងអនុវត្តតួនាទីក្រសួងរបស់គាត់បានយ៉ាងមានសមត្ថភាព គាត់ប្រាកដជាបានដឹងយ៉ាងពេញលេញពីព័ត៌មាននេះ ។ ក្នុងគ្រប់លទ្ធភាពទាំងអស់ គាត់គ្រាន់តែបានជ្រើសរើសយកបដិសេធប៉ុណ្ណោះ ។



ប្រកាសចុះហត្ថលេខាដោយ ចាន់ សារុន អនុញ្ញាតឱ្យក្រុមហ៊ុន Seng Keang Company សាងសង់រោងចក្រកែច្នៃឈើក្នុងភូមិខែស័



រោងចក្រអារឈើរបស់ក្រុមហ៊ុន Seng Keang Company និងរោងចក្រផលិតឈើបន្ទះក្នុងភូមិខែស័ ខែ វិច្ឆិកា ឆ្នាំ ២០០៥

ក្នុងឆ្នាំ ២០០៦ រដ្ឋមន្ត្រីបានការពារសេចក្ដីសម្រេចចិត្តរបស់គាត់ក្នុងលក្ខខណ្ឌដូចខាងក្រោមនេះ :

"ការអនុញ្ញាតរបស់យើងឱ្យក្រុមហ៊ុនSeng Keang Company ដើម្បីបង្កើតរោងចក្រអារឈើក្នុងទីរីង គឺស្របតាមច្បាប់ព្រៃឈើ ដោយសារ (រោងចក្រអារឈើ) មិនស្ថិតនៅក្នុងព្រំដែនព្រៃឈើ ប៉ុន្តែស្ថិតក្នុងកណ្ដាលតំបន់អភិវឌ្ឍន៍ចំការកៅស៊ូទីរីង [១៤៥] ។"

ការសំអាងនេះ មិនអាចជឿបានឡើយ ដោយសារតែតំបន់ចំការកៅស៊ូ ត្រូវបានចងភ្ជាប់គ្រប់ផ្នែកទាំងអស់ដោយព្រៃឡង់ ហើយរោង-ចក្រអារឈើរបស់ក្រុមហ៊ុនSeng Keang Company នៅចម្ងាយមិនដល់មួយគីឡូម៉ែត្រពីព្រៃ ដែលជាបរិវេណភាគខាងកើតរបស់ចំការ ។

ការអនុញ្ញាតរបស់ ចាន់ សារុន បង្កើតឱ្យមានចម្ងល់បន្ថែមទៀតពីរបៀបដែលគាត់សម្រុះសម្រួលការអះអាងជម្លោះរបស់គាត់ទៅលើទីរីង និងអ្នកដែលទទួល "គុណប្រយោជន៍ពីការផ្លាស់ប្ដូរ" ។ រដ្ឋមន្ត្រីបានបញ្ជាក់ថា មានឈើមានតម្លៃតិចតួចនៅក្នុងទីរីង ទោះយ៉ាងណា-ក៏ដោយ គាត់បានជ្រើសរើសអនុញ្ញាតឱ្យសាងសង់រោងចក្រឈើអារ និងក្ដារបន្ទះដែលមានសង្វាក់ផលិតកម្មមិនតិចជាងបួន ។តើកន្លែងណាដែលគាត់បានរំពឹងទុកថា ក្រុមហ៊ុន Seng Keang Company នឹងទទួលបានឈើរបស់ក្រុមហ៊ុន ?

ជាថ្មីម្ដងទៀត ចាន់ សារុន ទំនងជាបានបំពានមាត្រា ១០០ នៃច្បាប់ព្រៃឈើ ។ ទោះយ៉ាងណាក៏ដោយ ស្របពេលដែលមានភាពខុសច្បាប់ស្ទើរតែជាក់ច្បាស់យ៉ាងនេះទៅហើយនោះ វិធានការណ៍របស់រដ្ឋមន្ត្រី គឺកំពុងតែស្របជាមួយវប្បធម៌មិនយោបាយទាំងស្រុង ដែលការិយាល័យរដ្ឋត្រូវបានដឹងថា ជាការផ្ដល់អាជ្ញាប័ណ្ណ ដើម្បីគេចផុតពីច្បាប់ ជាជាងការទទួលខុសត្រូវអនុវត្ត ។

នៅត្រីមាសចុងក្រោយនៃឆ្នាំ ២០០៤ ក្រុមហ៊ុន Seng Keang Company បានដំណើរការសាងសង់រោងចក្រ និងរោងចក្រផលិតក្ដារបន្ទះដែលបំពាក់ដោយគ្រឿងម៉ាស៊ីនថ្មីនាំចូលពីប្រទេសចិន[១៥៨] ។ ពិធីសម្ពោធរោងចក្រ ត្រូវបានផ្ដល់កិត្តិយសដោយមន្ត្រីជាន់ខ្ពស់មកពីភ្នំពេញ[១៥៩] ។ សេង កុកហ៊ាង ទទួលខុសត្រូវចាត់ចែងរោងចក្រ ហើយនៅចុងឆ្នាំ ២០០៤ ក្រុមហ៊ុនកំពុងដំណើរការកាប់ឈើច្បោះរបស់អ្នកភូមិជាច្រើននៅខាងក្រៅព្រំប្រទល់ចំការ[១៦០] ។

## ៣.៦ ឈើចាស់ៗ និងការបាត់បង់ការចងចាំរបស់ម្ចាស់ជំនួយ

ក្នុងចុងឆ្នាំ ២០០៤ ប្រតិបត្តិការរបស់ ឌី ចូច, សេង គាង និង ឃុន ថុង បានទទួលការជម្រុញបន្ថែមទៀត នៅពេលដែលលែងហាមប្រាមជាបណ្ដោះអាសន្នចំពោះការបញ្ឈប់ការដឹកជញ្ជូនឈើ ដែលបានអនុញ្ញាតឱ្យពួកគេប្រើប្រាស់ឈើ ដែលនៅបន្សល់ក្នុងចំការកៅស៊ូទីរីង ដោយសម្បទានិកឈើក្រុមហ៊ុន Colexim Enterprise ។ ក្រុមហ៊ុន Colexim Enterprise បានទទួលយកតួនាទីដឹកនាំក្នុងដើមខែ ដើម្បីធ្វើប្រតិបត្តិការឈូសសំអាតក្នុងទីរីង ហើយដោយយោងតាមកំណត់ត្រារបស់ខ្លួន "ប្រមូលបាន" ឈើចំនួន ៣,៣៩៥ [១៦១] ។បន្ទាប់ពីមានការបញ្ចូលនូវការបញ្ចប់ជាបណ្ដោះអាសន្នឈើចំនួន ២,៨១២ នៃឈើទាំងនេះបន្សល់ទុកនៅក្បែរផ្លូវទៅកាន់ចំការ ។ អធិការកិច្ចរបស់ Global-Witness ទៅលើឈើទាំងនេះបានបង្ហាញថា យ៉ាងហោចណាស់ចំនួន ៥០% មានប្រហោងយកជ័រ ដែលអាចប្រាប់ថា ក្រុមហ៊ុនបានកាប់ដោយខុសច្បាប់[១៦២] ។

ការប្រមូលឈើចាស់ៗ ត្រូវបានបង្កើតឡើងយ៉ាងល្អ ជាការគ្របបិទបាំងប្រតិបត្តិការកាប់ឈើខុសច្បាប់ក្នុងប្រទេសកម្ពុជា ហើយ ហ៊ុន សែន បានហាមប្រាមការអនុវត្តនេះនៅក្នុងឆ្នាំ ១៩៩៩ ។ ដោយមិនខ្វល់ ក្រុមហ៊ុនColexim បានបញ្ចុះបញ្ចូលយ៉ាងយូរសុំការអនុញ្ញាតដឹកជញ្ជូនឈើចេញពីទីរីងទៅកាន់រោងចក្ររបស់ខ្លួននៅតាមផ្លូវជាតិលេខ ៥ [១៦៣] ។ ក្នុងឆ្នាំ ២០០៣ ក្រុមហ៊ុនបានដាក់ជូនសំណើផ្លូវការទៅកាន់រដ្ឋាភិបាល ដោយការជម្រុញដោយស្ងាត់ស្ងៀមរបស់ធនាគារពិភពលោក[១៦៤] ។ ស្របពេលជាមួយគ្នានេះដែរ ចាន់ សារុន បានសុំការគាំទ្រពីក្រុមការងារគ្រប់គ្រងធនធានធម្មជាតិ (WGNRM) នៃម្ចាស់ជំនួយអន្តរជាតិសម្រាប់ការលើកលែងការបញ្ឈប់ការដឹកជញ្ជូនឈើ ។ WGNRM បានឆ្លើយតបដោយសំបុត្រពីរទៅកាន់រដ្ឋមន្ត្រី ដោយបាននិយាយថា :

"ការដឹកជញ្ជូនឈើដែលបានស្នើ មិនអាចកាត់ផ្ដាច់ចេញពីប្រភពដើមនៃឈើឡើយ ។ការយល់ដឹងរបស់យើងចំពោះការអភិវឌ្ឍន៍ចំការកៅស៊ូទីរីង គឺកំពុងមានបញ្ហាខ្លាំងណាស់... សហគមន៍ជាច្រើនត្រូវបានផ្លាស់ទីកន្លែង ហើយបាត់បង់ការចិញ្ចឹមជីវិតដែលបានបង្កើតឡើងរបស់ពួកគេ ... ការព្រួយបារម្ភចម្បងរបស់យើង គឺថាការដឹកឈើដែលបានទទួលការអនុញ្ញាតណាមួយ មិនត្រូវបង្កើតឱ្យមានឱកាសសម្រាប់ដឹកឈើដែលបានកាប់ខុសច្បាប់ថ្មី [sic] ឬការដឹកឈើដែលបានកាប់រំលំដោយខុសច្បាប់ឡើយ ។ ដោយសារហេតុផលនេះហើយ ដែលក្រុមការងារបានជម្រុញក្នុងឆ្នាំ ២០០២... ឱ្យមាននូវការបញ្ឈប់ការដឹកឈើ[១៦៥] ។"

"យើងក៏ឃើញមានទិដ្ឋភាពបរិស្ថាន (សំណើក) ក៏ដូចជាបញ្ហាសង្គមរបស់គម្រោងទីរីង ដែលភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងគំនិតបង្កើនការដឹកជញ្ជូនដោយមានការគ្រប់គ្រង និងការលក់ឈើពីតំបន់គម្រោងផងដែរ ។ ទោះបីជាមានការអះអាងដែលអ្នកបានផ្ដល់ឱ្យក៏ដោយ យើងនៅតែមិនអាចយល់ព្រមចំពោះការដឹកឈើទាំងអស់នេះ[១៦៦] ។"

ទោះយ៉ាងណាក៏ដោយ នៅពេលដែល ចាន់ សារុន បានជម្រុញឱ្យមានការធ្វើដឹកឈើបន្តទៀត នៅឯកិច្ចប្រជុំក្រុមពិគ្រោះផ្ដល់យោបល់ក្នុងខែ ធ្នូ ឆ្នាំ២០០៤ ម្ចាស់ជំនួយបានសម្រេចចិត្តផ្ដល់ការគាំទ្ររបស់ពួកគេលើផែនការរបស់ពួកគេ ។ ក្នុងរយៈពេលចន្លោះនេះ គ្មានអ្វីផ្លាស់ប្ដូរនោះទេ ស្ថិតនៅពីក្រោយការធ្វើឱ្យកាន់តែយ៉ាប់នូវស្ថានភាពក្នុងទីរីង ដោយសារប្រតិបត្តិការរបស់ក្រុមហ៊ុន Seng Keang Company បានពង្រីក ហើយអ្នកយកជ័រកាន់តែច្រើនបានបាត់បង់ដើមឈើរបស់ពួកគេ ។ ក្នុងខែ មករា ឆ្នាំ ២០០៥ សម្បទានិកចាប់ផ្ដើមដឹកឈើយ៉ាងច្រើន ភាគច្រើននៃឈើទាំងនេះជាដើមច្បោះ ដែលបានកាប់រំលំដោយខុសច្បាប់ ។ការគាំទ្ររបស់ម្ចាស់ជំនួយ បានក្លាយទៅជាភស្ដុតាងចម្បងរបស់ ចាន់ សារុន ចំពោះការបញ្ចប់នូវការបញ្ឈប់ការដឹកឈើ [១៤៥] ។

ស្របជាមួយក្រុមហ៊ុន Colexim អ្នកទទួលប្រយោជន៍មួយក្នុងចំណោមអ្នកទទួលប្រយោជន៍ជាច្រើន គឺក្រុមហ៊ុន Seng Keang Company ពេលនោះការដឹកឈើដែលបានបន្តក្នុងខែមករា ឆ្នាំ២០០៥ បានទិញឈើជាច្រើនពាន់ដើមក្នុងទីរីង ក្នុងតម្លៃUS$ ២១៦,៣៩៧[១៦៧] ។ ក្រុមនេះបានដំណើរការយកឈើទាំងនេះ ទៅកាន់រោងចក្រក្រុមហ៊ុន Kingwood តាមឡាន មុនពេលផ្ទុកម្តងទៀតទៅក្នុងកប៉ាល់ និងលក់ទៅឱ្យរោងចក្រអារឈើបន្តទៀតនៅខាងក្រោមទន្លេមេគង្គ[១៦៨] ។

តំណាងរបស់ម្ចាស់ជំនួយ ដែលពីមុនបានបង្ហាញពីការបារម្ភពីការដឹកឈើដែលបានស្នើឡើងពីទីរីង មិនបានលើកឡើងពីបញ្ហាបន្ថែមទៀតពីប្រភពឈើ ឬគំនិតអនុញ្ញាតឱ្យក្រុមហ៊ុនដែលមានការសង្ស័យនេះ ទាញយកប្រយោជន៍ពីសកម្មភាពខុសច្បាប់ទាំងនេះឡើយ ។



ឈើចាស់ៗ : ពីទីរីងទៅកាន់រោងចក្រក្រុមហ៊ុន Kingwood និងផ្សេងទៀត ខែ កុម្ភៈ ឆ្នាំ ២០០៤

ទាំងក្រុមហ៊ុនរបស់ប្រទេសស្វីស SGS ដែលបានគ្រប់គ្រងជាអ្នកត្រួតពិនិត្យផ្លូវការនូវកិច្ចខិតខំប្រឹងប្រែងដោះស្រាយបទល្មើសព្រៃឈើ បន្ទាប់ពីការដក Global Witness ចេញ ក៏មិនមានចម្លើយអ្វីដែរ ។ SGS បានជូនដំណឹងដល់ Global Witness ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ ថា " SGS មិនត្រូវបានស្នើសុំឱ្យស៊ើបអង្កេត ឬផ្តល់ទស្សនៈណាមួយពាក់ព័ន្ធនឹងប្រភពដើមនៃឈើទាំងនេះ ដែលត្រូវបានប្រមូលផលបានយ៉ាងប្រសើរមុនពេលចាប់ផ្តើមចុះកិច្ចសន្យាជាមួយ SGS" ។ SGS ត្រូវបានជូនដំណឹងដោយក្រុមម្ចាស់ជំនួយថា ពួកគេបានសម្រេចឱ្យមានការដឹកឈើ ដោយមានលក្ខខណ្ឌថា ត្រូវបានគ្រប់គ្រងព្យាយាម និងធានាថា គ្មានឈើស្រស់ ឬឈើបន្ថែមទៀត អាចចូលទៅក្នុងចង្វាក់ផ្គត់ផ្គង់បានឡើយ[១៦៩] ។"

## ៤. ការវិភាគប្រតិបត្តិការកាប់ឈើខុសច្បាប់

សូមអរគុណដល់គម្រោងចំការកៅស៊ូជប់ និងលិខិតអនុញ្ញាតដែលផ្តល់ដោយ ចាន់ សារុន, ឌី ចូច, សេង គាង និង ឃុន ថុង បានរៀបចំបង្កើតនៅចំកណ្តាលព្រៃឡង់ ដែលជាធនធានព្រៃឈើដ៏មានតម្លៃបំផុតរបស់ប្រទេសកម្ពុជា ។ មិនទំនងដែលពួកគេអាចជ្រើសរើសទីតាំងដែលប្រសើរជាងនេះ សម្រាប់សកម្មភាពរបស់ពួកគេឡើយ ហើយទីរីងបានក្លាយជាមជ្ឈមណ្ឌលប្រតិបត្តិការកាប់ឈើខុសច្បាប់ដ៏ធំបំផុតយ៉ាងពិតប្រាកដក្នុងប្រទេសកម្ពុជា ។ ផ្នែកនេះរៀបរាប់ពីលទ្ធផលស៊ើបអង្កេតរបស់ Global Witness ទៅក្នុងសមាសភាពសំខាន់ៗរបស់ប្រតិបត្តិការនេះ ។




ឈើដូចគ្នានេះ ត្រូវបានផ្ទុកក្នុងទូកនៅរោងចក្រ Kingwood និងត្រូវបានលក់ទៅកាន់រោងចក្រអារឈើនៅខាងក្រោមទន្លេមេគង្គ ដែលរួមមានទាំងរោងចក្រអារឈើរបស់ ឃុន ថុង តាមផ្លូវជាតិលេខ ២ ផងដែរ (បង្ហាញនៅខាងលើ)

## ៤.១ សមត្ថភាពកែច្នៃ

ចាប់ពីពេលបង្កើតរោងចក្រថ្មីក្នុងភូមិខែសឹក្នុងទីរីង នៅចុងឆ្នាំ ២០០៤ ក្រុមកាប់ឈើបានកាត់បន្ថយការដឹកជញ្ជូនឈើរបស់ខ្លួនទៅកាន់ក្រុមហ៊ុនរោងចក្រ Kingwood ក្នុងខេត្តកណ្តាល ។ ជំនួសមកវិញ ក្រុមហ៊ុនបានចាប់ផ្តើមកែច្នៃឈើទៅជាសន្លឹកឈើស្តើងៗនៅតំបន់ជាច្រើន មុនពេលដឹកទៅកាន់រោងចក្រសម្រាប់តម្លើងជាក្តារបន្ទះ[១៥៨] ។ នេះអាចបង្ហាញពីលំអៀងចំពោះជម្រើសជាក់ស្តែងកាន់តែតិចចំពោះការដឹកជញ្ជូនឈើខុសច្បាប់ជាបន្តបន្ទាប់ ដែលថ្លែងដោយ Global-Witness អង្គការសហប្រជាជាតិ និងអ្នកផ្សេងទៀត ។ ស្របពេលជាមួយគ្នានេះដែរ ក្រុមនេះបានចាប់ផ្តើមសង្កត់ធ្ងន់កាន់តែខ្លាំងទៅលើការកែច្នៃ និងការធ្វើពាណិជ្ជកម្មឈើអារ ។

ពេលដែលរោងចក្រថ្មីនៅខែសឹ ក្លាយជាមជ្ឈមណ្ឌលសម្រាប់សកម្មភាពកែច្នៃទាំងនេះ ក្រុមនេះក៏បានទាញយកប្រយោជន៍ពីតំបន់បន្ថែមទៀតក្នុងខេត្តកំពង់ធំ និងកំពង់ចាមផងដែរ ។ ក្នុងខេត្តកំពង់ធំ ការទាញយកប្រយោជន៍ទាំងនេះ រួមមាន រោងចក្រអារឈើក្បែរកំពង់ថ្ម ដែលអ្នកស្រុកក្នុងតំបន់នោះអះអាងថា ឌី ចូច បានទិញប្រមាណ US$១០,០០០ ក្នុងដើមឆ្នាំ ២០០៥[១៧០] ។

ក្រុមកាប់ឈើក៏បានទទួលកម្មសិទ្ធិលើរោងចក្រ អ៊ែល ដារ៉ា ដែលនៅក្បែរនោះផងដែរ ។ ប្រជាជនជាច្រើនដែលត្រូវបានសម្ភាសន៍នៅមូលដ្ឋានរបស់ អ៊ែល ដារ៉ា ក្នុងខែ ឧសភា ឆ្នាំ ២០០៥ បានបង្ហាញថា ឌី ចូច បានគ្រប់គ្រងក្រុមហ៊ុនក្នុងខែ មិនា នាឆ្នាំនោះ ។ កម្មកររបស់ អ៊ែល ដារ៉ា បានប្រាប់ Global Witness ពួកគេកំពុងផលិតក្តារស្តើងៗ សម្រាប់ប្រើប្រាស់នៅរោងចក្រក្រុមហ៊ុន Kingwood[១៧១] ។ ការអង្កេតស្រាវជ្រាវតាមអាកាសទៅលើតំបន់នោះ ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៥ និងខែ កញ្ញា ឆ្នាំ ២០០៦ បានបង្ហាញថា រោងចក្រកំពុងបន្តកែច្នៃឈើមូល ទៅជាបន្ទះឈើស្តើងៗ ។



រោងចក្រអារឈើក្បែរកំពង់ថ្ម ដែលត្រូវបានរាយការណ៍ថាបានទិញដោយ ឌី ចូច ខែ វិច្ឆិកា ឆ្នាំ ២០០៥



រោងចក្រក្តារបន្ទះ អ៊ែល ដារ៉ា ខែ មិនា ឆ្នាំ ២០០៣

ក្នុងខេត្តកំពង់ចាម ក្រុមនេះបានគ្រប់គ្រងការកែច្នៃឈើទៅជាបន្ទះឈើស្តើងៗនៅរោងចក្រក្នុងស្រុកចំការអណ្តូងដែលត្រូវបានស្គាល់ថាជារោងចក្រលេខ II ។ កម្មករនៅរោងចក្រលេខ II បានប្រាប់ Global Witness ក្នុងខែឧសភា ឆ្នាំ២០០៤ ថាពួកគេកំពុងកែច្នៃឈើពីព្រៃធម្មជាតិទៅជាសន្លឹកឈើបន្ទះសម្រាប់ផលិតក្តារបន្ទះនៅ Kingwood[១៧១] ។

នៅក្បែររោងចក្រ Kingwood, Global Witness បានរកឃើញថា ក្រុមនេះកំពុងប្រើប្រាស់តំបន់ពីរបន្ថែមទៀត សម្រាប់ផ្នែកនៃដំណើរការផលិតក្តារបន្ទះ[១៧២] ។

ស្របពេលជាមួយគ្នានេះដែរ រោងចក្រអារឈើដែលគ្រប់គ្រងដោយ ឃុន ថុង នៅតាមផ្លូវជាតិលេខ ២ នៅតែមានសកម្មភាពយ៉ាងខ្លាំង ។ អ្នកស៊ើបអង្កេតបានទៅកាន់កន្លែងនោះក្នុងខែ មេសា ឆ្នាំ ២០០៥ បានឃើញថា រោងចក្រកំពុងកែច្នៃឈើបេងប្រមាណ ១០០ម$^{៣}$ (កម្រិតឈើប្រណិតប្រភេទពូជដែលត្រូវការពារ) ឈើទាល (ឈើច្បោះ) និងផ្ចៀក ។ ឈើទាំងអស់នេះ ត្រូវបានផ្ទេរពីរោងចក្រ Kingwood តាមទន្លេមេគង្គ និងទន្លេបាសាក់ ។ ខែបន្ទាប់មក អ្នកស៊ើបអង្កេតបានឃើញមន្ត្រីរដ្ឋបាលព្រៃឈើ ទៅកាន់រោងចក្រអារឈើជាមួយឡានយោធាធំមួយ ដែលផ្ទុកដោយឈើប្រណិត និងឈើលេខមួយ ។ ឈើនេះត្រូវបានកាប់ដោយខុសច្បាប់ក្នុងខេត្តពោធិសាត់[១៥៨] ។

### ៤.២ ការគាំទ្ររោងចក្រ

រូបភាពតាមផ្កាយរណបបង្ហាញថា នៅខែ មករា ឆ្នាំ ២០០៥ ធនធានព្រៃឈើក្នុងចំការកៅស៊ូទឹករឹងមានទាំងអស់ ប៉ុន្តែត្រូវបានកាប់ ។ ការសម្ភាសន៍ជាមួយអ្នកកាប់ឈើ មន្ត្រី និងអ្នកស្រុកក្នុងតំបន់ជាមួយការស៊ើបអង្កេតពីតំបន់កាប់ឈើ និងការដឹកជញ្ជូនតាមឡាន បង្ហាញថា ប្រសិនបើមិនមែនមុននេះទេ ចាប់ពីចុងឆ្នាំ ២០០៤ ការកាប់ឈើដោយក្រុមហ៊ុន សេង គាង ផ្តោតជាចម្បងលើព្រៃឈើនៅខាងក្រៅព្រំប្រទល់ចំការ[១៧៣] ។ ពេញមួយឆ្នាំ ២០០៥ អ្នកស៊ើបអង្កេតរបស់ Global Witness បានរកឃើញភស្តុតាងរបស់អ្នកកាប់ឈើ សេង កុកហ៊ាង ដែលធ្វើប្រតិបត្តិការតាមស្រុកសណ្តាន់ និងស្រុកសន្ទុក ម្យ៉ាងវិញទៀត តំបន់ព្រៃឡង់ធ្លាក់ទៅក្នុងសម្បទានក្រុមហ៊ុន Colexim ក្រុមហ៊ុន GAT ក្រុមហ៊ុន Mieng Ly Heng និងក្រុមហ៊ុន Pheapimex-Fuchan ។ (សម្រាប់ក្រុមហ៊ុន Colexim របាយការណ៍តាមដានរបស់ខ្លួន និងទំនាក់ទំនងរបស់ខ្លួនជាមួយក្រុមហ៊ុន Seng Keang Company ត្រូវបានរៀបរាប់ក្នុងប្រអប់ទី ៧) ។

ជាមួយនឹងរោងចក្រ Kingwood រោងចក្ររបស់ក្រុមហ៊ុន Seng Keang Company ក្នុងភូមិខែសី បានកែច្នៃជាចម្បងលើ *ឈើទាល* (ឈើយកជ័រ) *ផ្ចៀក* និងប្រភេទពូជកម្រិតពាណិជ្ជកម្មផ្សេងទៀត ដែលសមរម្យធ្វើជាបន្ទះឈើ និងឈើសំណង់[១៧៤] ។ រោងចក្រក៏មានមុខងារជាកន្លែងចែកចាយឈើដែលអ្នកកាប់ឈើបានកាប់ជាកំណាត់ក្តារ ឬម៉ៃតាប (*may tap*) (ឈើជ្រុង) ក្នុងព្រៃ ដោយប្រើប្រាស់រណារអារ ។ ឈើអារនេះ រួមមានមិនត្រឹមតែឈើកម្រិតពាណិជ្ជកម្មប៉ុណ្ណោះទេ តែរួមទាំងប្រភេទពូជប្រណិត ដូចជា *បេង នាងនួន* និង*ធ្នង់* ផងដែរ ។ ក្នុងដើមឆ្នាំ ២០០៥ ឈើប្រណិតជាច្រើននេះ មកពីព្រៃជុំវិញភ្នំជីក្នុងសម្បទានរបស់ក្រុមហ៊ុន Pheapimex-Fuchan ភាគខាងកើតទឹករឹង[១៧០] ។

Global Witness ក៏បានបង្ហាញភស្តុតាងពីក្រុមកាប់ឈើបងសំណាញ់របស់ខ្លួនបន្ថែមលើខេត្តកំពង់ធំ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីរក្សាការផ្គត់ផ្គង់ដល់រោងចក្រកែច្នៃរបស់ខ្លួន ។ ក្នុងខែ ឧសភា ឆ្នាំ ២០០៤ អ្នកស៊ើបអង្កេតបានរកឃើញប្រតិបត្តិការកាប់ឈើទ្រង់ទ្រាយធំក្នុងសម្បទានព្រៃឈើក្រុមហ៊ុន Timas Resources នៅចុងភាគខាងត្បូងព្រៃឡង់ ក្នុងខេត្តកំពង់ចាម ។ អ្នកកាប់ឈើបាននិយាយថា ពួកគេកំពុងធ្វើការឱ្យនាយទាហានយោធភូមិភាគ II សាត ចាន់ថា[១៨៩] និង អ៊ុយ គា[១៩០] ហើយថាពួកគេកំពុងកាប់ឈើសម្រាប់រោងចក្រ Kingwood[១៩១] ។ ជាងពីរឆ្នាំក្នុងការបញ្ឈប់ការកាប់ឈើក្នុងសម្បទានឈើ សកម្មភាពទាំងនេះ គឺច្បាស់ណាស់មានលក្ខណៈខុសច្បាប់ ។







ការប្រៀបធៀបគម្របព្រៃឈើក្នុង និងជុំវិញទឹករឹងតាមដែលឃើញតាមផ្កាយរណបក្នុងឆ្នាំ ២០០១ និង ២០០៥ ។ ផ្នែកខាងឆ្វេងដៃខាងលើនៃរូបភាពតាមផ្កាយរណបឆ្នាំ ២០០៥ បង្ហាញពីការកាប់បំផ្លាញព្រៃឈើខាងក្រៅព្រំប្រទល់ចំការកៅស៊ូ ។

## ប្រអប់ទី ៧ : ក្រុមហ៊ុន Colexim–ក្រុមហ៊ុនសម្បទានគំរូរបស់ប្រទេសកម្ពុជា

*"ចំណុចមានតម្លៃបំផុតគឺ យើងនឹងអាចក្លាយជាក្រុមហ៊ុនគំរូ... ក្រុមហ៊ុន Colexim អាចជាក្រុមហ៊ុនគំរូប្រសើរបំផុតសម្រាប់រាល់ក្រុមហ៊ុនសម្បទានទាំងអស់ក្នុងប្រទេសកម្ពុជា ហើយបន្ទាប់មកយើងសង្ឃឹមថា ពួកគេនឹងព្យាយាមអស់ពីលទ្ធភាពធ្វើតាមក្រុមហ៊ុន Colexim ។"*[១៦៣]

ក្រុមហ៊ុន Colexim គ្រប់គ្រងសម្បទានឈើ ១៤៧,១៨៧ ហិកតា ដែលគ្របដណ្តប់ភាគខាងលិចតំបន់ព្រៃឡង់ ។ ម្ចាស់ក្រុមហ៊ុន គឺក្រុមហ៊ុនជប៉ុនឈ្មោះ Okada សេដ្ឋីកម្ពុជាឈ្មោះ ឧកញ៉ា សូ សុវណ្ណ[១៧៥] និងរដ្ឋាភិបាលកម្ពុជា[១៧៦] ។ ក្រុមហ៊ុនColexim មានកំណត់ត្រាដែលបានកត់ត្រាទុកយ៉ាងល្អពីការកាប់ឈើខុសច្បាប់ និងការប្រើហិង្សាប្រឆាំងប្រជាជនក្នុងមូលដ្ឋាន[១៧៧] ។ ក្នុងឆ្នាំ ១៩៩៧ អ្នកយាមរបស់ខ្លួនម្នាក់បានសម្លាប់អ្នកយកជ័រ ដែលព្យាយាមបញ្ឈប់ក្រុមហ៊ុន Colexim ពីការកាប់ដើមច្បោះរបស់អ្នកភូមិ[១៧៨] ។

ការអង្កេតស្រាវជ្រាវរបស់ Global Witness ក្នុងអំឡុងឆ្នាំ ២០០៣ និងឆ្នាំ ២០០៤ បានរកឃើញថាការកាប់រំលំ និងការដុតដោយខុសច្បាប់ បានបំផ្លិចបំផ្លាញព្រៃឈើយ៉ាងហោចណាស់ ១,០០០ ហិកតាជុំវិញមូលដ្ឋានកាប់ឈើជំរុំលេខ ៩៩ របស់ក្រុមហ៊ុន Colexim ក្នុងឃុំមានឫទ្ធិ ។ អាជីវកម្មកសិកម្ម គឺការទិញដី និងការដាំសណ្តែកសៀង និងដំណាំផ្សេងទៀត ។ អ្នកស្រុកក្នុងតំបន់បានចោទអ្នកម៉ៅការរបស់ក្រុមហ៊ុន Colexim ឈ្មោះ ចេង សារ៉ាត់[១៧៩] និង ស្វាយ សារ៉ាត់[១៨០] ពីការសម្របសម្រួលការកាប់ឈើ និងលក់ដីដោយមានការឃុបឃិតពីរដ្ឋបាលព្រៃឈើ និងមន្ត្រីឃុំ[១៨១] ។

ក្នុងខែមិថុនាឆ្នាំ២០០៥ទីប្រឹក្សាដែលបានជួលដោយធនាគារពិភពលោក ដើម្បីធ្វើការពិនិត្យលើផែនការគ្រប់គ្រងព្រៃឈើប្រកបដោយចេរភាព និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមរបស់សម្បទានិកបានធ្វើការអង្កេតស្រាវជ្រាវតាមអាកាសនូវតំបន់ដូចគ្នា និងបានធ្វើកំណត់សំគាល់ដូចខាងក្រោម :

"ការដណ្តើមយកដី ការកែច្នៃព្រៃឈើ : ជាក់ស្តែងព្រៃឈើទាំងអស់ ដែលត្រូវបានប្រមូលផលដោយ (ក្រុមហ៊ុន Colexim) ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ២០០០ (ប្រមាណ ១៨,៨០០ហិកតា) ឥឡូវនេះត្រូវបានរំខាន ទន្ទ្រាន កែច្នៃ ទ្រង់ទ្រាយធំរួចជាស្រេច ឬប្រហែលជានឹងត្រូវឈូសសំអាត ។"[១៨២]

គួរឱ្យចម្លែកដែលក្រុមហ៊ុន Colexim មិនដឹងពីការបំផ្លិចបំផ្លាញនេះ ។ ប្រសិនបើក្រុមហ៊ុនមិនទទួលខុសត្រូវដោយផ្ទាល់នោះ ការធ្វេសប្រហែសរបស់ខ្លួន គឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការលុបចោលកិច្ចសន្យាសម្បទានរបស់ខ្លួន ។

ក្នុងអំឡុងឆ្នាំ ២០០៥ និង ២០០៦, Global Witness បានបង្កើតការស្រាវជ្រាវជាថ្មីទៅលើការកាប់ឈើខុសច្បាប់ក្នុងសម្បទានរបស់ក្រុមហ៊ុនColexim ។ ប្រជាជនក្នុងមូលដ្ឋានបានផ្តល់ឱ្យនូវរឿងរ៉ាវលំអិតពីកាប់ឈើយកជ័រខុសច្បាប់ដែលពួកគេអះអាងថាត្រូវបានសម្របសម្រួលដោយអ្នកម៉ៅការរបស់ក្រុមហ៊ុន Colexim ឈ្មោះស្វាយ សារ៉ាត់ នៀក សុខណៃ[១៨៣] និងងិន វ៉ាន់ថៃ[១៨៤] រួមជាមួយនឹង សេង កុកហ៊ាង ។ នៅពេលកាប់ ពួកគេបានអះអាងថា ឈើកំពុងត្រូវបានដឹកជញ្ជូនពីសម្បទានទៅកាន់រោងចក្ររបស់ក្រុមហ៊ុន Seng Keang Company ក្នុងទីរីង[១៨៥] ។ បុគ្គលិកនៅរោងចក្រក្តារបន្ទះអ៊ែល ដារ៉ា ជិតកំពង់ថ្មបានប្រាប់ Global Witness ក្នុងខែ កញ្ញា ឆ្នាំ ២០០៥ ថា ពួកគេក៏បានទទួលឈើពីជំរុំលេខ ៩៩ របស់ក្រុមហ៊ុន Colexim ផងដែរ[១៨៦] ។

Global Witness បានបង្កើតការអង្កេតស្រាវជ្រាវតាមអាកាសពីតំបន់ជំរុំលេខ ៩៩ ក្នុងខែ កញ្ញា ឆ្នាំ ២០០៦ ហើយបានរកឃើញថា អ្វីដែលគឺជាការឈូសសំអាតទ្រង់ទ្រាយតូចក្នុងព្រៃ បានលាតសន្ធឹងទៅកាន់វាលរាបទទេស្អាតប្រមាណ ៥,០០០-៦,០០០ ហិកតា[១៨៧] ។

ក្នុងខែ ធ្នូ ឆ្នាំ ២០០៦, Global Witness បានទទួលអនុស្សារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្ទៃក្នុងដែលបានសរសេរសម្រាប់ ចាន់ សារុន ដែលពាក់ព័ន្ធបំណុលជំពាក់ដោយក្រុមហ៊ុន Colexim ចំពោះធនាគារ Union Commercial Bank និងម្ចាស់បំណុលផ្សេងទៀត ។ អនុស្សារណៈនេះ សំដៅទៅលើផែនការព្រឹទ្ធសមាជិកគណបក្សប្រជាជននិងសេដ្ឋី លី យ៉ុងផាត់ ដើម្បីទិញដីមួយចំនួនរបស់ក្រុមហ៊ុន Colexim[១៨៨] ។

ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ Global Witness បានសរសេរទៅកាន់ លី យ៉ុងផាត់ ដើម្បីសួរគាត់ថា តើដីពាក់ព័ន្ធជាផ្នែកមួយរបស់សម្បទានឈើរបស់ក្រុមហ៊ុន Colexim ក្នុងព្រៃឡង់មែនដែរ ឬទេ ។ នៅពេលបោះពុម្ពផ្សាយរបាយការណ៍នេះ លី យ៉ុងផាត់ មិនបានឆ្លើយតបនៅឡើយទេ ។



**ការដុតព្រៃ - សម្បទានរបស់ក្រុមហ៊ុន Colexim ខែ មិនា ឆ្នាំ ២០០៣**

## ៤.៣ អ្នកផ្គត់ផ្គង់

*"ក្នុងការឆ្លើយតបទៅកាន់ការអះអាងពីការកាប់ឈើខុសច្បាប់ទ្រង់ទ្រាយធំចម្ងាយ ៥-១០ ខាងក្រៅតំបន់ចំការកៅស៊ូ : ក្នុងករណីនេះ ដោយយោងតាមរដ្ឋបាលព្រៃឈើក្នុងតំបន់ដែលប្រយុទ្ធប្រឆាំងបទល្មើសព្រៃឈើ ការរំលោភទ្រង់ទ្រាយតូច (ការកាប់ដោយសម្ងាត់ ការអារឈើ និងការដឹកជញ្ជូនដោយរទេះគោ ឬរទេះសេះ) អាចកើតឡើងម្តងម្កាលក្នុងតំបន់ព្រៃឈើ ។ ការរបំពានទាំងនេះ ត្រូវបានធ្វើឡើងដោយប្រជាជនដែលរស់នៅក្នុង និងក្បែរព្រៃឈើ ដើម្បីផ្គត់ផ្គង់ការចិញ្ចឹមជីវិតរបស់ពួកគេ ជាពិសេសក្នុងអំឡុងពេលរាំងស្ងួត និងដើម្បីប្រើប្រាស់ផលិតផលឈើសម្រាប់ការសាងសង់របស់រដ្ឋក្នុងមូលដ្ឋានចាំបាច់ ។ស្របពេលជាមួយគ្នានេះដែរ មន្ត្រីមានសមត្ថកិច្ចមកពីរដ្ឋបាលព្រៃឈើក្នុងតំបន់ បានពង្រឹងការអនុវត្តច្បាប់ ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងបទល្មើសព្រៃឈើជាបន្តបន្ទាប់ ។"* ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិយាយ ។

អ្នកផ្គត់ផ្គង់ឈើឱ្យប្រតិបត្តិការរបស់ក្រុមហ៊ុន Seng Keang Company ក្នុងទីរីង រួមមានក្រុមសំខាន់ៗបី :

១. ក្រុមបុគ្គលិកទទួលប្រាក់ខែតូចមួយដែលធ្វើការឱ្យ សេង កុក-ហ៊ាង ដែលគ្រប់គ្រងប្រតិបត្តិការកាប់ឈើ ។ បុគ្គលិកម្នាក់ៗទាំងនេះ បានទទួលប្រាក់ខែមូលដ្ឋានរហូតដល់ US$២២០ ក្នុងមួយខែ[១៩២] ។

២. ក្រុមកាប់ឈើពេញម៉ោងដែលបានបង់ប្រាក់ US$១៥-US$២៥ សម្រាប់ការកាប់ឈើមួយម៉ែត្រគីប ។ សេង កុកហ៊ាង បានផ្តល់ឱ្យកម្មករទាំងនេះនូវឧបករណ៍កាប់ និងការការពារ ហើយបញ្ជូនយានយន្តផ្ទាល់របស់ខ្លួន ដើម្បីប្រមូលឈើពីតំបន់កាប់ ។ ក្នុងឆ្នាំ ២០០៥ គាត់ប្រើប្រាស់ឡានចំនួនប្រាំសម្រាប់គោលបំណងនេះ[១៩២] ។

៣. ពាណិជ្ជករឈើដែលផ្គត់ផ្គង់ឱ្យរោងចក្រដោយឥតជាប់កិច្ចសន្យា ។ ពាណិជ្ជករទាំងនេះ ទទួលខុសត្រូវស្វែងរកឧបករណ៍ផ្ទាល់ខ្លួនរបស់ពួកគេ ហើយបង់ឱ្យមន្ត្រីពុករលួយ ។ ពួកគេមិនអាចពឹងផ្អែកលើជំនួយរបស់ សេង កុកហ៊ាង ឡើយ ប្រសិនបើពួកគេជួបប្រទះការពិបាក ។ម្យ៉ាងវិញទៀត ក្រុមហ៊ុនសេងគាងបានបង់ពួកគេថ្លៃជាងក្នុងមួយម៉ែត្រគីប ចំពោះឈើកែច្នៃដែលបានផ្តល់ឱ្យរោងចក្រ ។ ក្នុងឆ្នាំ ២០០៥ បានចំណាយឱ្យអ្នកផ្គត់ផ្គង់ប្រភេទនេះ ប្រមាណ US$១៥០ ក្នុងមួយម៉ែត្រគីបចំពោះឈើលេខ I និង US$៧៥-US$១០០ សម្រាប់កម្រិតលេខ II ។ ពាណិជ្ជករឈើទាំងនេះ ជាធម្មតាប្រើប្រាស់ឡានកូរ៉េតូចៗ ឬជួលរទេះគោ (មួយៗអាចដឹកបាន ១-១.២៥ម$^{៣}$) ដើម្បីដឹកឈើទៅកាន់រោងចក្រ[១៩២] ។

កម្មករដែលធ្វើការឱ្យពាណិជ្ជករឈើ ស្ថិតនៅខាងក្រោមស្ថានភាពតាមឋានានុក្រម ។ ភាគច្រើនមកក្នុងឋានៈជាកម្មករចំណាកស្រុកមកពីតំបន់ផ្សេងៗ ជួនកាលរស់នៅក្នុងព្រៃជាច្រើនសប្តាហ៍នៅពេលប្រតិបត្តិការកាប់ឈើ ។ អ្នកកាប់ឈើ ដែលបានសម្ភាសន៍ដោយ Global Witness ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៥ បាននិយាយថា និយោជករបស់ពួកគេ កងរាជអាវុធហត្ថដែលផ្គត់ផ្គង់ឈើឱ្យ សេង កុកហ៊ាង បានចំណាយឱ្យពួកគេ US$៣០-US$៥០ ក្នុងម្នាក់សម្រាប់មួយខែដោយផ្អែកតាមចំនួនឈើដែលពួកគេបានកាប់ និងកែច្នៃ[១៩៣] ។



ការកាប់ដើមឈើយកដំរទៅជាកំណាត់ក្តារ ចម្ងាយប៉ុន្មានគីឡូម៉ែត្រភាគខាងត្បូងព្រំដែនចំការកៅស៊ូទីរីង ខែ តុលា ឆ្នាំ ២០០៣
រូបតូច : សៀវភៅបញ្ជាទិញរបស់អ្នកកាប់ឈើនៅតំបន់កាប់ឈើខាងក្រៅព្រំដែនចំការ ខែ វិច្ឆិកា ឆ្នាំ ២០០៥

ចំនួនប្រជាជន និងម៉ាស៊ីនពិតប្រាកដពាក់ព័ន្ធមានការពិបាកប៉ាន់ស្មានណាស់ ទោះយ៉ាងណា ក្នុងពាក់កណ្តាលឆ្នាំ ២០០៥ អ្នករស់នៅទីរីងម្នាក់ ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមហ៊ុន Seng Keang Company បានប្រាប់ Global Witness ថា មានរណារអារចំនួន ៥២ នៅក្នុងតែឃុំទីរីងមួយគត់[១៩៤] ។ ក្នុងឆ្នាំដូចគ្នានេះ សកម្មជនសហគមន៍ព្រៃឈើបានកត់ត្រាថា មានរណារអារចំនួន ១៣១ និងរោងចក្រចល័ត ១២ នៅក្នុងឃុំទាំងអស់នៃស្រុកសណ្តាន់[១៩៥] ។



## ៤.៤ ការដឹកជញ្ជូន



បុគ្គលិករបស់ក្រុមហ៊ុន Seng Keang Company ម្នាក់ ដែលថាខ្លួនគាត់ជាអ្នកគ្រប់គ្រងការដឹកជញ្ជូនរបស់ក្រុមហ៊ុនបានប្រាប់ Global Witness ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៥ ថា ក្រុមហ៊ុនបានកំពុងប្រើប្រាស់ក្រុមដែលមានឡានប្រាំ និងដឹកឈើពី ៣-៤ ឡាន ចេញពីទីរីងរៀងរាល់ថ្ងៃ[១៩៦] ។ការរាយការណ៍នេះស៊ីគ្នាជាមួយការអង្កេតស្រាវជ្រាវដោយផ្ទាល់របស់ Global Witness ពីសកម្មភាពជុំវិញរោងចក្រអារឈើរបស់ សេង គាង ក្នុងទីរីង ។

ឡានជាច្រើនដែលប្រើប្រាស់ដោយក្រុមហ៊ុន Seng Keang Company ជារបស់កងពលតូចលេខ ៧០ ដែលជាកងយោធាដ៏មានឥទ្ធិពល ដែល សេង កុកហ៊ាង ជានាយយោធា[១៩៧] ។ ការជួយដឹកជញ្ជូនឈើរបស់កងពលតូចលេខ ៧០ គឺជាប្រតិបត្តិការទូទាំងប្រទេស ដែលត្រូវបានរៀបរាប់លំអិតក្នុងជំពូក IV ។ ឡានពណ៌បៃតងយោធាកង់ ១០ របស់កងពល ជាធម្មតាពាក់ផ្លាកលេខកងយោធពលខេមរ-ភូមិន្ទ ហើយជាច្រើនមានផ្លាកលេខ‘70’ នៅខាងមុខកញ្ចក់ ។ អ្នកស៊ើបអង្កេតរបស់ Global Witness បានតាមដានឡានទាំងនេះ ពីព្រៃឡង់ទៅកាន់រោងចក្រ Kingwood ហើយបានប្រមូលដំណើររឿងពីការសហការរបស់កងឯកភាពនេះ ជាមួយក្រុមហ៊ុន Seng Keang Company ពីទាហានរបស់កងពលតូចលេខ ៧០ ពាណិជ្ជករឈើ និងប្រជាជនក្នុងតំបន់[១៩៨] ។



ឡានដែលស្រដៀងឡានទាំងឡាយ ដែលប្រើប្រាស់ដោយកងពលតូចលេខ ៧០ ដែលដឹកឈើពីទីរីង ទៅកាន់រោងចក្រ Kingwood នាពេលយប់ ឆ្នាំ ២០០៥

## ៤.៥ ទីផ្សារ

ក្រុមហ៊ុន Seng Keang Company ផ្គត់ផ្គង់ឈើពាណិជ្ជកម្ម និងប្រណិតមួយចំនួនដែលខ្លួនកាប់ដោយខុសច្បាប់ក្នុងព្រៃឡង់ទៅកាន់ទីផ្សារក្នុងស្រុករបស់ប្រទេសកម្ពុជា ។ Global Witness បានប្រមូលព័ត៌មានពីប្រភពផ្សេងៗ ដែលនិយាយថា ទោះយ៉ាងណាក៏ដោយចំណែកសំខាន់ជាច្រើន អាចត្រូវបានប្រើប្រាស់នៅខាងក្រៅប្រទេស :

- ការផ្គត់ផ្គង់ឈើពីព្រៃឡង់ ធ្វើឱ្យផលិតកម្មទ្រង់ទ្រាយឧស្សាហកម្មក្តារបន្ទះនៅរោងចក្រ Kingwood អាចបន្តបាន ។ ដូចបានបង្ហាញក្នុងប្រអប់ទី ៨ មានការបង្ហាញជាច្រើន ដែលផលិតផលទាំងនេះភាគច្រើន កំពុងត្រូវបាននាំចេញទៅប្រទេសចិន ។
- ដូចបានរៀបរាប់លំអិតក្នុងជំពូក IV កងពលតូចលេខ ៧០ ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការជួញដូរឈើទៅកាន់ប្រទេសវៀតណាម[១៩៩] ។ កងឯកភាពនេះ អាចកំពុងដឹកជញ្ជូនបានយ៉ាងប្រសើរនូវឈើដែលបានកាប់ដោយក្រុមហ៊ុន Seng Keang Company ក្នុងព្រៃឡង់កាត់តាមព្រំប្រទល់ភាគខាងកើតរបស់ប្រទេសកម្ពុជា ។
- ប្រភពដ៏ល្អជាច្រើនបានប្រាប់ Global Witness ឌី ចូច ពាក់ព័ន្ធក្នុងការនាំឈើប្រណិតចេញដោយខុសច្បាប់ក្នុងកុងទែន័រនាំចេញតាមកំពង់ផែសមុទ្រភាគខាងត្បូងរបស់ប្រទេសកម្ពុជា[២០០] ។ Global Witness បានសរសេរទៅទៅកាន់ ឌី ចូច ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៧ ដើម្បីសុំយោបល់របស់គាត់ចំពោះការចោទប្រកាន់នេះ ប៉ុន្តែមិនបានទទួលការឆ្លើយតបទេ ។



ក្រុមហ៊ុន Seng Keang Company ផ្គត់ផ្គង់ឈើប្រណិតឱ្យទីផ្សារក្នុងស្រុករបស់ប្រទេសកម្ពុជា និងក្រៅប្រទេស

## ប្រអប់ទី ៨ : ការនាំឈើចេញដែលមិនអាចមើលឃើញរបស់ប្រទេសកម្ពុជា

*បន្ទាប់ពីការបញ្ឈប់ឆ្នាំ ២០០២ ទៅលើកាប់ឈើក្នុងសម្បទាន និងការដឹកជញ្ជូនឈើ រោងចក្រ Kingwood គឺជារោងចក្រតែមួយគត់ ដែលបន្តប្រតិបត្តិការ ។*

ចាប់ពីឆ្នាំ ២០០១ រោងចក្ររបស់ Kingwood បានចាប់ផ្តើមផលិតក្តារបន្ទះប្រភេទថ្មី ដោយប្រើប្រាស់ឈើចម្រុះពីព្រៃធម្មជាតិ និងឈើពីដើមកៅស៊ូចាស់ៗដែលដាំក្នុងចំការ[២០១] ។ សង្វាក់ផលិតកម្មនេះ បានបន្តបន្ទាប់ពីមានការគ្រប់គ្រងរបស់ក្រុមហ៊ុនក្នុង ខែសីហា ឆ្នាំ ២០០២ ដោយ ឌី ចូច, សេង គាង និង យុន ចុង[២០២] ។ ចាប់ពីឆ្នាំ ២០០៤ ក្រុមហ៊ុន Seng Keang Company ក៏បានចាប់ផ្តើមផលិតសន្លឹកឈើស្តើងៗនៅតំបន់ជាច្រើនជុំវិញព្រៃឡង់ និងដឹកជញ្ជូនទៅកាន់រោងចក្រ Kingwood សម្រាប់តម្លើងជាក្តារបន្ទះសម្រេច ។

ការស៊ើបអង្កេតដោយ Global Witness រវាងឆ្នាំ ២០០២ និង ២០០៦ បានរកឃើញថាក្រុមហ៊ុន សេង គាង គឺជាក្រុមហ៊ុនតែមួយគត់ក្នុងប្រទេសកម្ពុជា ដែលផលិតក្តារបន្ទះ ឬបន្ទះឈើស្តើងៗជាទ្រង់ទ្រាយឧស្សាហកម្ម ។ ក្រុមហ៊ុននេះ ក៏ក្លាយជាផលិតករនាំមុខគេនៃឈើអារក្នុងរយៈពេលដូចគ្នានេះផងដែរ ។

រដ្ឋាភិបាលជម្រុញឱ្យមានការនាំចេញក្តារបន្ទះផលិតដោយ Kingwood ...

ក្នុងខែមេសា ឆ្នាំ ២០០៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំពិពណ៌ពាណិជ្ជកម្ម ដើម្បីជម្រុញការនាំចេញផលិតផលកម្ពុជា ។ ពិពណ៌រួមមានគំរូក្តារបន្ទះបីប្រភេទផ្សេងគ្នាដែលទាំងអស់នោះ មានដាក់ស្លាកថា "ធ្វើពីឈើកៅស៊ូ" ។ ក្នុងកិច្ចសម្ភាសន៍ដាច់ដោយឡែក មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពីររូបបានប្រាប់ Global Witness ថា ក្តារបន្ទះនេះមកពី "រោងចក្ររបស់ ហ៊ុន ចូច នៅស្រុកមុខកំពូល តាមផ្លូវជាតិលេខ ៦" គឺរោងចក្រ Kingwood ។ មន្ត្រីម្នាក់ក្នុងចំណោមមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបរាប់ថា ក្តារបន្ទះត្រូវបានធ្វើឡើងពីឈើកៅស៊ូ ១០០% ស្របពេលដែលអ្នកផ្សេងទៀត បាននិយាយថា ជាការលាយចម្រុះគ្នានៃឈើកៅស៊ូ និងឈើចម្រុះ[២០៣] ។ ជាការពិតណាស់ សាច់ និងសរសៃបន្ទះឈើដែលប្រើប្រាស់ក្នុងគំរូក្តារបន្ទះស្រដៀងនឹងឈើកម្រិតពាណិជ្ជកម្មជាជាងឈើដើមកៅស៊ូ ។

ប៉ុន្តែគ្មានការនាំចេញក្តារបន្ទះ និងឈើអារត្រូវបានកត់ត្រាទុកក្នុងស្ថិតិរដ្ឋាភិបាលផ្លូវការនោះទេ ។

បន្ទាប់ពីការបញ្ឈប់ការកាប់ឈើក្នុងសម្បទានចាប់ពីឆ្នាំ ២០០២ តួលេខរដ្ឋាភិបាលកម្ពុជាផ្លូវការ សន្មតថា ការនាំចេញឈើបានដាំក្បាលចុះ ។ ស្ថិតិដែលបានបោះពុម្ពដោយរដ្ឋបាលព្រៃឈើបង្ហាញថា គ្មានការនាំចេញក្តារបន្ទះក្នុងឆ្នាំ ២០០៣ និង ២០០៤ ទេ[២០៤] ។ ពាណិជ្ជកម្មឈើអារ ហាក់បីដូចជាបានបញ្ចប់តាំងពីដើមដោយគ្មានការនាំចេញត្រូវបានកត់ត្រារវាងឆ្នាំ ២០០០ និង ២០០៤[២០៤] ។ រដ្ឋាភិបាលកម្ពុជា មិនបានបោះពុម្ពស្ថិតិនាំចេញឈើណាមួយសម្រាប់ឆ្នាំ ២០០៥ និង ២០០៦ នោះទេ ។ Global Witness បានសរសេរទៅកាន់រដ្ឋបាលព្រៃឈើ ដើម្បីស្នើសុំសំណុំតួលេខទាំងនេះ ប៉ុន្តែមិនទាន់បានទទួលការឆ្លើយតបនៅឡើយទេ ។

ទោះយ៉ាងណាក៏ដោយ ការនាំចូលផលិតឈើកម្ពុជា បន្តចុះបញ្ជីដោយប្រទេសផ្សេងៗ ...

តួលេខពាណិជ្ជកម្មអន្តរជាតិ មាននូវរូបភាពផ្សេងគ្នាពីការនាំចេញឈើកម្ពុជា[២០៥] ។ តួលេខទាំងនេះបង្ហាញថា រវាងឆ្នាំ ២០០៣ និងចុងឆ្នាំ ២០០៦ ប្រទេសចិនបាននាំចូលពីប្រទេសកម្ពុជានូវក្តារបន្ទះ សរុបចំនួន ២៨,០០០ម$^{៣}$ មានតម្លៃស្មើនឹង US$១៦ លាន ។ ពួកគេក៏បង្ហាញផងដែរថា ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៥ ប្រទេសកម្ពុជា នាំក្តារបន្ទះចេញក្នុងបរិមាណតិចជាងទៅកាន់ប្រទេសអូស្ត្រាលី សិង្ហបុរី តៃវ៉ាន់ និងកន្លែងផ្សេងទៀត ។

តួលេខឈើអារមានខ្ពស់ជាង - ១៥០,០០០ម$^{៣}$ ត្រូវបាននាំចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិន ក្នុងរវាងឆ្នាំ ២០០៣ និងឆ្នាំ ២០០៧ ក្នុងតម្លៃនាំចូលប្រមាណ US$៣៤ លាន[២០៥] ។

...ដោយមានការព្រួយបារម្ភការពាក់ព័ន្ធនឹងរតនាគារកម្ពុជា ។

ទាំងការនាំចេញក្តារបន្ទះ និងឈើអារពីប្រទេសកម្ពុជា ត្រូវបានជាប់ពន្ធ ១០% នៃតម្លៃរបស់ឈើ ហើយកំហាតសរុបចំពោះរដ្ឋាភិបាលកម្ពុជាទៅលើការនាំចេញក្តារបន្ទះ មិនបានបង់ពន្ធទៅកាន់ប្រទេសចិនរវាងពីឆ្នាំ ២០០៣ និង ២០០៦ អាចមានចំនួនរហូតដល់ US$១.៥ លាន[២០៦] ។ ការខាតបង់ទៅលើឈើអារមិនបានចុះបញ្ជី ហាក់បីដូចជាទ្វេដងលើតួលេខនេះ ។

Global Witness មិនអាចនិយាយដោយច្បាស់លាស់ថា ប៉ុន្មានភាគរយនៃការនាំចេញទាំងនេះ ពាក់ព័ន្ធនឹងក្រុមហ៊ុន Seng Keang Company នោះទេ ។ ទោះយ៉ាងណាក៏ដោយ ក្នុងឋានៈជាផលិតករក្តារបន្ទះ និងបន្ទះឈើដែលមានសកម្មភាពក្នុងប្រទេសកម្ពុជាជាទ្រង់ទ្រាយឧស្សាហកម្មដែលបានស្គាល់តែមួយគត់នាពេលនោះ ទំនងណាស់ដែលក្រុមហ៊ុននេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងពាណិជ្ជកម្មក្តារបន្ទះដែលមានតម្លៃរាប់លានដុល្លារនេះ ។ ដោយសារតែប្រហែលជាអ្នកដំណើរការរោងចក្រអារឈើធំបំផុតក្នុងប្រទេស មានការជឿជាក់ខ្លាំងថា ក្រុមហ៊ុនទទួលខុសត្រូវចំពោះចំណែកដ៏ធំនៃពាណិជ្ជកម្មឈើអារផងដែរ ។

## ក- ឈើអារ













## ខ- ក្តារបន្ទះ















## គ- ការនាំឈើជាប់ពន្ធពីប្រទេសកម្ពុជាទៅប្រទេសចិន និងប្រាក់ចំណូលដែលបានខាតបង់ប៉ាន់ស្មានសម្រាប់រដ្ឋាភិបាលកម្ពុជា : ២០០៣ - ២០០៦

ប្រាក់ចំណូលពន្ធប៉ាន់ស្មាន ដែលត្រូវបង់សម្រាប់រដ្ឋាភិបាលកម្ពុជា ចំពោះការនាំចេញឈើអារ និងក្តារបន្ទះទៅកាន់ប្រទេសចិន ២០០៣ - ២០០៦



US$4.5m

ចំណូលពន្ធដែលបានអះអាងប្រមូលដោយរដ្ឋាភិបាលកម្ពុជា (US $) សម្រាប់ការនាំចេញឈើអារ និងក្តារបន្ទះទៅកាន់ប្រទេសចិន ២០០៣ - ២០០៦

US$0

សំគាល់ ១ : ផលិតផលដែលបានបង្ហាញក្នុងតួលេខនេះ បង្ហាញពីការនាំចូលឈើ ដែលបានប្រកាសយ៉ាងច្រើនសម្បើមរបស់ប្រទេសចិនពីប្រទេសកម្ពុជា

សំគាល់ ២ : ទិន្នន័យឆ្នាំ ២០០៦ ត្រូវបានប៉ាន់ស្មាននៅទីនេះ ដោយគុណចំនួនសរុបសម្រាប់ខែទាំងដប់មួយដំបូងនៃឆ្នាំ ២០០៦ ជាមួយនឹង ១២,១១

សំគាល់ ៣ : ទំនិញឈើអារ ត្រូវបានគណនាដោយប្រើប្រាស់កូដ HS សម្រាប់ឈើអារ និងឈើអារ n.e.s. (មិនបញ្ជាក់ពីទីកន្លែងច្បាស់លាស់) ។ឈើអារn.e.s បង្ហាញពីឈើមិនមែនប្រភេទស្រល់ និងអាចរួមមានឈើអារតំបន់ត្រូពិកផងដែរ

សំគាល់ ៤ : ដោយផ្អែកតាមលំហូរពាណិជ្ជកម្មទ្វេភាគី វាមានហេតុផលសន្មតថា តម្លៃឯកតានៃឈើក្នុងប្រទេសកម្ពុជានឹងមានថោកជាងប្រមាណ ១០% នៃតម្លៃឈើដូចគ្នាក្នុងប្រទេសចិន ។ ចំណូលពន្ធដែលត្រូវបង់ឱ្យរដ្ឋាភិបាលកម្ពុជា ត្រូវបានប៉ាន់ស្មានដោយប្រើប្រាស់តួលេខមុនចំនួន ៩០% នៃតម្លៃឈើនាំចូលដែលបានប្រកាសក្នុងប្រទេសចិន

### ៤.៦ ទិន្នផល និងចំណូលហិរញ្ញវត្ថុ

ដោយសារតែសញ្ញាណខុសច្បាប់នៃសកម្មភាពរបស់ក្រុមហ៊ុន Seng Keang Company គ្មានស្ថិតិផ្លូវការដែលអាចជឿជាក់បានណាទៅលើចំនួនឈើ ដែលក្រុមហ៊ុនបានកាប់ក្នុងព្រៃឡង់នោះទេ ។ ទោះយ៉ាងណាក៏ដោយ Global Witness បានចងក្រងទិន្នន័យទៅលើប្រតិបត្តិការរបស់ក្រុម ដែលធ្វើឱ្យមានការប៉ាន់ស្មានពីទិន្នផលគ្របដណ្ដប់លើរយៈពេលនេះ ចាប់តាំងពីក្រុមហ៊ុនបានបង្កើតរោងចក្ររបស់ខ្លួននៅភូមិខែសី នៅចុងឆ្នាំ ២០០៤ ។

***តើឈើចំនួនប៉ុន្មានដែលក្រុមហ៊ុន Seng Keang Company បានកែច្នៃនៅរោងចក្ររបស់ខ្លួននៅទីរឹង ?***

ប្រជាជនដែលរស់នៅក្បែរផ្លូវឆ្ពោះទៅកាន់ទីរឹងដែល Global - Witness បានសម្ភាសន៍ក្នុងឆ្នាំ ២០០៥ និង ២០០៦ បានបញ្ជាក់ថារយៈពេល ២៤ម៉ ពួកគេតែងឃើញ និងឮឡានដែលបានផ្ទុករួចរបស់ក្រុមកាប់ឈើពីពីរទៅបីចេញពីចំការ[១៨៥] ។អ្នកគ្រប់គ្រងការដឹកជញ្ជូនរបស់ក្រុមហ៊ុន Seng Keang Company បានប្រាប់ Global Witness ក្នុងខែវិច្ឆិកា ឆ្នាំ ២០០៥ ថា ក្រុមហ៊ុនកំពុងដឹកជញ្ជូនឈើអារជាមធ្យមបីទៅបួនឡានក្នុងមួយថ្ងៃ[១៨៦] ។ យានយន្តរបស់ក្រុមហ៊ុន Seng Keang Company និមួយៗដឹកយ៉ាងហោចណាស់ឈើកែច្នៃ ៦០ម$^{៣}$ [១៥៨] ។

ការប៉ាន់ស្មានទាំងនេះ រវាងឈើពីពីរទៅបួនឡានក្នុងមួយថ្ងៃស្របតាមការអង្កេតស្រាវជ្រាវសកម្មភាពឡានរបស់ Global - Witness ក្នុងរយៈពេលដូចគ្នានេះ ។ដោយសន្មតថាក្រុមហ៊ុនប្រើប្រាស់ជាមធ្យមនូវឡានចំនួនបីក្នុងមួយថ្ងៃ នេះស្ដែងថា ទិន្នផលឈើអារមាន ១៨០ម$^{៣}$ ក្នុងមួយថ្ងៃ ៤៦៨០ម$^{៣}$ ក្នុងមួយខែ និងលើសពី ៥៦,០០០ម$^{៣}$ ក្នុងមួយឆ្នាំ[v] ។

***តើនេះស្មើទៅនឹងចំនួនឈើដែលបានប្រើប្រាស់ដែរឬទេ ?***

អត្រាកែច្នៃអន្តរជាតិតាមបទដ្ឋានសម្រាប់ឈើមូល ដែលបានកែច្នៃជាឈើអារ គឺ ១.៨ ម៉្យាងវិញទៀត ត្រូវការឈើ ១.៨ម$^{៣}$ ដើម្បីផលិតជាឈើអារមួយម៉ែត្រគីប[២០៧] ។ ជាក់ស្ដែង ចំនួនដ៏ច្រើននៃឈើរបស់ក្រុមហ៊ុន Seng Keang Company ត្រូវបានកែច្នៃក្នុងព្រៃដោយប្រើប្រាស់រណារអារ និងហើយហេតុនេះ កែច្នៃមានប្រសិទ្ធិភាពតិចជាង ។ ទោះយ៉ាងណាក៏ដោយ ដោយប្រើប្រាស់អត្រាកែច្នៃ ១.៨ យើងអាចប៉ាន់ស្មានជាធម្មតាពីការប្រើប្រាស់ឈើរបស់ក្រុមនេះថាមានឈើមូលប្រមាណ ៣២៤ម$^{៣}$ ក្នុងមួយថ្ងៃ ៨៤២៤ម$^{៣}$ ក្នុងមួយខែនិងលើសពី ១០០,០០០ម$^{៣}$ ក្នុងមួយឆ្នាំ[v] ។

មានតម្លៃគួរឱ្យកត់ចំណាំថា ចំនួននេះលើសច្រើនខ្លាំងពីអ្វីដែលសម្បទានិកឈើត្រូវបានអនុញ្ញាតឱ្យកាប់ ។ ឧទាហរណ៍ និយោជកពីមុនរបស់ ឌី ចូច, សេង គាង និង ឃុន ថុង ត្រូវបានផ្ដល់សិទ្ធិឱ្យប្រមូលផលអតិបរមា ៣៥,០០០ម$^{៣}$ ក្នុងមួយឆ្នាំ[៨០] ។

ក្នុងខែ មិនា ឆ្នាំ ២០០៦ ចាន់ សារុន បានផ្ដល់ការវាយតម្លៃរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពីសកម្មភាពកាប់ឈើរបស់ក្រុមហ៊ុន សេង គាង ក្នុងតំបន់នេះ :

"មកទល់ចុងឆ្នាំ ២០០៥ ក្រុមហ៊ុន Seng Keang Company បានប្រមូលព្រៃឈើ និងអនុផលពីចំការកៅស៊ូទីរឹង ដែលបានឈូសសំអាតក្នុងចំនួនសរុប ១២,២០៤.៦៩៦ម$^{៣}$ នៃឈើមូលនិងឈើប្រភេទចម្រុះ និងដើមឈើតូចៗ និងអុសចំនួន ២,០២៣ ស្ទែរ"[vi] ។[១៨៥]

ស្របពេលដែលមានការជាក់លាក់គួរឱ្យស្ងើចសរសើរនេះ តួលេខទាំងនេះមានទាបខ្លាំងណាស់ ដោយគិតថា ក្រុមហ៊ុន Seng Keang Company បានចាប់ផ្ដើមប្រតិបត្តិការផ្លូវការក្នុងទីរឹងក្នុងខែ តុលា ឆ្នាំ ២០០២ ។ ការគណនារបស់ ចាន់ សារុន ទៅលើចំនួនឈើសរុបដែលក្រុមហ៊ុនបានយកចេញក្នុងរយៈពេលជាងបីឆ្នាំនេះ គឺស្មើនឹងចំនួនឈើដែលរោងចក្ររបស់ខ្លួនក្នុងទីរឹងកែច្នៃរៀងរាល់ ៣៨ ថ្ងៃធ្វើការ ។



**សកម្មភាពខាងក្នុងរោងចក្រ**
**ក្រុមហ៊ុន** Seng Keang Company
**ខែ កញ្ញា និង វិច្ឆិកា ឆ្នាំ ២០០៥**

[v] ដោយផ្អែកលើ ៥២ សប្ដាហ៍ ដែលមានថ្ងៃធ្វើការប្រាំមួយថ្ងៃក្នុងមួយឆ្នាំ ។

[vi] ស្ទែរ គឺជាឯកតាដែលត្រូវបានប្រើប្រាស់ ដើម្បីវាស់វែងចំនួនឈើដែលបានប្រមូល និងស្មើទៅនឹងមួយម៉ែត្រគីប ។

***តើមានចំណូលហិរញ្ញវត្ថុដល់ក្រុមហ៊ុន Seng Keang Company និងរដ្ឋចំនួនប៉ុន្មាន ?***

Global Witness បានប្រមូលទិន្នន័យជាច្រើនពីចំណាយរបស់ក្រុមហ៊ុន Seng Keang Company ក្នុងការកាប់ឈើ ដឹកជញ្ជូនឈើ បង់ឱ្យកម្មករ និងសូកមន្ត្រី តែគ្មានតួលេខពីចំណាយ និងចំណេញសុទ្ធទាំងមូលរបស់ក្រុមនេះទេ ។ ទោះយ៉ាងណាក៏ដោយ ច្បាស់ថាចំណូលពីការកាប់ឈើ និងប្រតិបត្តិការកែច្នៃឈើរបស់ក្រុមហ៊ុនមានច្រើន ។ ដោយត្រូវបានគណនាតម្លៃឈើអារកម្រិត II ដែលមានតម្លៃ US$២៣៥ ក្នុងមួយម៉ែត្រគីបក្នុងភ្នំពេញឆ្នាំ ២០០៦ នោះលទ្ធផលប្រចាំឆ្នាំរបស់ក្រុមហ៊ុន Seng Keang Company ពីឈើកែច្នៃពីទីរីង នឹងមានតម្លៃប្រមាណ US$១៣ លាន[២០៨] ។

តួលេខនេះ មិនរាប់បញ្ចូលបរិមាណឈើជាច្រើនដែលក្រុមហ៊ុន Seng Keang Company បានកែច្នៃជាបន្ទះឈើ និងក្តារបន្ទះដែលមានតម្លៃច្រើនជាងឈើអារទៀត ។ក៏មិនគិតពីឈើប្រណិត និងកម្រិតលេខ I ដែលមានតម្លៃថ្លៃជាងដែលក្រុមនេះបានកាប់ និងបានលក់ហើយនិងចំណូលកាន់តែខ្ពស់ ដែលក្រុមហ៊ុននឹងបានទទួលពីផលិតផលឈើណាមួយ ដែលខ្លួនបាននាំចេញ ។

ដោយយោងតាម ចាន់ សារុន បានឱ្យដឹងថា រវាងពីចំណុចដែលក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការជាផ្លូវការក្នុងទីរីង និងចុងឆ្នាំ ២០០៥ ក្រុមហ៊ុនរបស់ សេង គាង បានបង់ពន្ធជូនរដ្ឋចំនួន US$៥៩៤,៩៨៧.៩២ និង ៨,៤៩៦,៦០០រៀល ម៉្យាងទៀត និយាយដោយខ្លី គឺ US$៦០០,០០០ [១៤៥] ។ ក្នុងចម្ងល់ដែលបានដឹងពាក់ព័ន្ធនឹងចំនួនដែលក្រុមហ៊ុន Seng Keang Company បានបង់ពន្ធមានលក្ខណៈជាទ្រឹស្តី ដោយសារចំនួនដើមឈើដ៏ច្រើនដែលក្រុមហ៊ុនបានកាប់ដោយខុសច្បាប់ មិនគួរត្រូវបានកាប់រំលំក្នុងតំណែងទីមួយនោះទេ ។ ទោះយ៉ាងណាក៏ដោយ វាបង្ហាញពីការខាតបង់ទាំងមូលចំពោះ



**ឡានផ្ទុកពេញនៅក្បែរបរិវេណក្រុមហ៊ុន** Seng Keang Company
**ខែ មិនា ឆ្នាំ ២០០៦**

ប្រទេសកម្ពុជា ប្រសិនបើតាមបែបហិរញ្ញវត្ថុ នៅពេលដែលគិតថាការយកពន្ធលើការប្រើប្រាស់ឈើមូលប្រចាំឆ្នាំចំនួន ១០០,០០០ម[៣] របស់ក្រុមនេះនូវកម្រិតសួយសារ ដែលកំណត់លើឈើកម្រិតលេខ II - US$៥៤ ក្នុងមួយម៉ែត្រគីប - នឹងមានចំណូលសុទ្ធដល់រតនាគារចំនួន US$៥.៤ លានក្នុងមួយឆ្នាំ ។



**ស្តុកឈើរបស់ក្រុមហ៊ុន** Seng Keang Company **ក្នុងភូមិខែស៍ ខែ វិច្ឆិកា ឆ្នាំ ២០០៥**

## ការបំផ្លិចបំផ្លាញព្រៃឈើ និងរចនាសម្ព័ន្ធចាត់តាំងក្នុងអំពើពុករលួយ




អង្គការលេខ និង សម្ព័ន្ធភាព ក្រុមកាប់ឈើ
ក្រុមហ៊ុន Kingwood
Maybank V. Kingwood
Lia Chun Hua
Lee Kwan Siang
POLICE

## ៥. ដីស្រោបរ៉ែជនបទ

តំណាងរបស់ក្រុមហ៊ុន Seng Keang Company ក្នុងទីរីង សេង កុកហ៊ាង បានប្រើប្រាស់ការភ្ជាប់ទំនាក់ទំនងគ្រួសារ ការសូកសំណូក ការគម្រាមកំហែង និងសកម្មភាពហិង្សា ដើម្បីបង្កើតការគ្រប់គ្រងផ្ទាល់ខ្លួនក្នុងតំបន់នេះ ។ ប្រជាជនក្នុងតំបន់ដែលសម្ភាសន៍ដោយ Global Witness បានស្គាល់គាត់ពីដើមមកថាជា "សាច់ញាតិរបស់ ហ៊ុន សែន" ហើយមើលឃើញទំនាក់ទំនងនេះជាមួយនាយករដ្ឋមន្ត្រីថាជាប្រភពអំណាចដ៏អស្ចារ្យ[១៨៥] ។កងរាជអាវុធហត្ថនិងប៉ូលីសត្រូវបានផ្តល់កម្រៃដោយការទិញអំណាច តាមរយៈការបង់ចំណាយប្រចាំខែឱ្យមន្ត្រីទាំងនោះ[២០៩] ។ ជាងនេះទៅទៀត សេង កុកហ៊ាង បានជួលជនប្រដាប់អាវុធពីម្ភៃទៅសាមសិបនាក់ ភាគច្រើននៃពួកគេមកពីជួរកងយោធពលខេមរភូមិន្ទ[២១០] ។ កងជីវពលផ្ទាល់ខ្លួននេះ បានជួយគាត់មើលគួប្រឆាំងក្នុងតំបន់ និងអ្នកមកពីក្រៅដែលទៅកាន់ទីរីង[២១១] ។

### ៥.១ ការលួចកាប់ដើមច្បោះ

កិច្ចសម្ភាសន៍ជាមួយអ្នកកាប់ឈើ និងការទៅមើលតំបន់កាប់ឈើក្នុងព្រៃឡង់ បានឱ្យដឹងថា ដើមឈើទាលផ្តល់ជ័រ មានយ៉ាងហោចណាស់ ៥0% នៃឈើកែច្នៃក្នុងរោងចក្រក្រុមហ៊ុន Seng Keang Company ក្នុងភូមិខែស៏[២១២] ។

ដោយប្រើអស់ការផ្គត់ផ្គង់ឈើយកជ័រ និងឈើផ្សេងទៀតដែលមានក្នុងចំការ សេង កុកហ៊ាង ក៏ផ្តោតទៅលើព្រៃឈើដែលនៅជុំវិញ ។ នៅចុងឆ្នាំ ២០០៥ Global Witness បានរកឃើញក្រុមកាប់ឈើរបស់គាត់កំពុងកាប់ចម្ងាយប្រាំបីគីឡូម៉ែត្រពីបរិវេណចំការ ។ ហេតុនេះអ្នករកជ័របានបន្តបាត់បង់ដើមឈើរបស់ពួកគេ និងចំណូលដែលដើមឈើទាំងនេះបានផ្តល់ឱ្យ[២១៣] ។ អ្នកយកជ័រក្នុងភូមិទំអនៅជាយចំការបានប្រាប់ Global Witness ក្នុងឆ្នាំ ២០០៦ ថា កាលពីមុនគ្រួសារទាំង ១០០ ដែលរស់នៅទីនោះ បានកាន់កាប់ដើមច្បោះពី ២០០-៣០០ ក្នុងមួយគ្រួសារ ។ ឥឡូវនេះមានតែ ៥-៦ គ្រួសារប៉ុណ្ណោះមានដើមឈើដែលនៅសល់[២១៤] ។ក្នុងភូមិរំចេក ឃុំសុខចិត្ត អ្នកភូមិបានរាយការណ៍ពីការបាត់បង់ដើមច្បោះចំនួន ៨០០ ទៅឱ្យក្រុមកាប់ឈើរបស់ សេង កុកហ៊ាង ក្នុងតែពាក់កណ្តាលឆ្នាំ ២០០៥[១៧០] ។

ដោយយោងតាមអ្នកយកជ័រ ក្រុមហ៊ុន Seng Keang Company ពេលខ្លះនឹងបង់ឱ្យពួកគេនូវសំណងសម្រាប់ការកាប់ឈើរបស់ពួកគេ ។ ទោះយ៉ាងណាក៏ដោយ ចំនួនសរុបពាក់ព័ន្ធមានលក្ខណៈចំអកមើលងាយ – ពី US$១.២៥ - US$១២.៥ សម្រាប់ដើមឈើដែលឈើរបស់ដើមនេះ អាចលក់បានចំនួនរហូតដល់ US$១,000 ក្នុងក្រុងភ្នំពេញ[២១៥] ។ សេង កុកហ៊ាង និងអ្នកដែលធ្វើការឱ្យគាត់បានផ្តល់សំណងទាំងនេះតាមលក្ខណៈ "យក ឬមិនយក" ។ តាមអ្នកភូមិម្នាក់បាននិយាយថា : "លោក ៩៥ [សេង កុកហ៊ាង] មានអំណាចបំផុត ពីព្រោះគាត់គម្រាមកំហែងអ្នកយកជ័រ ដោយនិយាយទៅកាន់ពួកគេថា "អញនឹងកាប់ដើមឈើរបស់ឯងទោះបីជាឯងលក់មកឱ្យអញ ឬអត់ក៏ដោយ... មានតែលោក ៩៥ ប៉ុណ្ណោះ ហ៊ាននិយាយបែបនេះ ។"[២១៦]

### ៥.២ ការដោះស្រាយជាមួយការខ្វែងយោបល់

ចាប់តាំងពីដំណាក់កាលដំបូងនៃគម្រោងចំការកៅស៊ូទីរីង ប្រជាជនក្នុងតំបន់ដែលព្យាយាមការពារព្រៃឈើ បានជួបការគម្រាមកំហែងពីអ្នកកាប់ឈើ ។ របាយការណ៍មួយស្តីពីចំការដែលបានបោះពុម្ពក្នុងខែវិច្ឆិកាឆ្នាំ២០០៤ដោយការិយាល័យស្នងការជាន់ខ្ពស់សិទ្ធិមនុស្ស



**ទាហាននៅខាងក្រៅបរិវេណក្រុមហ៊ុន** Seng Keang Company **ក្នុងភូមិខែស៏ ខែ វិច្ឆិកា ឆ្នាំ ២០០៥**